ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Court Suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Nov-2012, 14:32
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ឧទ្ធរណ៍លើបណ្តឹងសាទុក្ខ - អៀង ធីរិទ្ធ

**សាធារណៈ:**

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧/អវតក-អជសង/អជតក

**ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២**

**ម៉ោង ០៩:៤៣នាទី**

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រីម ជាប្រធាន
ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត
*(Judge Agnieszka KLONOWIECKA-MILART)*
ចៅក្រម ម៉ុង មន្នីចរិយា
ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ
*(Judge Chandra Nilhal JAYASINGHE)*
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម ផ្លូរិន ម៉ុមបា
*(Judge Florence Mumba)*
ចៅក្រម យ៉ា ណារិន
ចៅក្រម ស៊ិន រិទ្ធ (បម្រុង)

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ
លោក ផន ធឿន
លោកស្រី អាន់នី ម៉ារី ប៊ឺន
*(Ms.Annie-Marie BURNS)*
លោកស្រី ស៊ីលា ផេលេន
*(Ms.Sheila PAYLAN)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក អេនឌ្រូ ខេលី *(Mr.Andrew CAYLEY)*
កញ្ញា សុង ឆវ័ន្ត
លោក អាប់ឌុលឡាក់ ថារីក
*(Mr. Abdulhak Tarik)*

**ជនជាប់ចោទ៖**

លោកស្រី អៀង ធីរិទ្ធ

**មេធាវីការពារជនជាប់ចោទ អៀង ធីរិទ្ធ:**

លោក ផាត់ ពៅស៊ាង
លោកស្រី ដាយអាណា អេលីស
*(Ms. Diana Ellis)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត *(Ms. Elisabeth SIMONNEAU-FORT)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី បេនី យេ *(Ms.Beini YE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម គង់ ស្រ៊ឹម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ផ្លូរិន ម៉ុមបា | អង់គ្លេស |
| ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡូត | អង់គ្លេស |
| ចៅក្រម សោម សិរីវឌ្ឍ | ខ្មែរ |
| ចៅក្រម ម៉ុង មន្នីចរិយា | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោកស្រី ដាយអាណា អេលីស | អង់គ្លេស |
| លោក ផាត់ ពៅស៊ាង | ខ្មែរ |
| លោកស្រី អៀង ធីរិទ្ធ | ខ្មែរ |
| លោកស្រី អៀង វិជីដា (អាណាព្យាបាល អៀង ធីរិទ្ធ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:៤៧:៥៣]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

បន្ទាប់ពីបានទទួលសារណាបណ្តឹងសាទុក្ខភ្លាមៗរួចមក ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសបើកសវនាការដើម្បីផ្តល់ឱកាសដល់ភាគី ក៏ដូចជាអង្គជំនុំជម្រះផ្ទាល់ ដើម្បីពិភាក្សាជាសាធារណៈលើបណ្តឹងសាទុក្ខនេះ ដែលភាគីបានធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេច ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ លើការវាយតម្លៃឡើងវិញ អំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ក្នុងសំណុំរឿងលេខ ០០២ -- ១៩ -- ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧-អ.វ.ត.ក-អ.ជ.ស.ដ ដែលមានជនជាប់ចោទ អៀង ធីរិទ្ធ។

[០៩:៥០:០២]

ខ្ញុំសូមរំឭកថា សវនាការនេះគឺក្នុងគោលបំណងពិភាក្សាលើបញ្ហា ថាតើគប្បីដាក់លក្ខខណ្ឌទៅលើការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដែរឬយ៉ាងណា? ចំណែកបញ្ហាដទៃទៀតដូចជា ភាពពុំមានសម្បទាខាងបញ្ញាស្មារតីក្នុងការចូលរួមសវនាការ និងការឃុំខ្លួនជនជាប់ចោទជាដើម ពុំត្រូវបានលើកមកពិភាក្សាក្នុងកិច្ចដំណើរការនីតិវិធីនេះទេ។

សមាសភាពអង្គជំនុំជម្រះតុលាការកំពូលនាថ្ងៃនេះមាន៖

១) ខ្ញុំចៅក្រម -- ខ្ញុំ គង់ ស្រ៊ីម ប្រធានុំ, ២) ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ, ៣) ចៅក្រម សោម សិរិវឌ្ឍ, ៤) ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត, ៥) ចៅក្រម ម៉ុង មុន្និចរិយា, ៦) ចៅក្រម ផ្លូរិនស៍ ម៉ុមបា, ៧) ចៅក្រម យ៉ា ណារិន, ៨) និងចៅក្រមបម្រុងលោក ស៊ិន រិទ្ធ។ ក្រឡាបញ្ជីលោក ស៊ា ម៉ៅ, លោកស្រី អានី ម៉ារី និងលោក ផន ធឿន។

លោក្រឡាបញ្ជី តើភាគី និងមេធាវីមានវត្តមានគ្រប់ចំនួនដែរឬទេ?

[០៩:៥១:៣៨]

**ក្រឡាបញ្ជី៖**

សូមជម្រាបប្រសាសន៍ឯកឧត្តមប្រធានអង្គជំនុំជម្រះសវនាការទាំងមូល វត្តមានរបស់ភាគីគឺមានគ្រប់ចំនួន ដូចជាតំណាងសហព្រះរាជអាជ្ញាមាន កញ្ញា សុង ឆវ័ន្ត តំណាងសហព្រះរាជអាជ្ញាជាតិ និងមានលោក អាន់ឌ្រូ ខេលី ជាសហព្រះរាជអាជ្ញាអន្តរជាតិ។ ជនជាប់ចោទមានវត្តមាននៅទីនេះគឺលោកស្រី អៀង ធីរិទ្ធ និងអ្នកអាណាព្យាបាលរបស់គាត់ អ្នកអាណាព្យាបាលទូទៅរបស់គាត់គឺលោកស្រី អៀង វិជីដា។ រីឯសហមេធាវីការពារក្តីជនជាប់ចោទមានលោក ផាត់ ពៅស៊ាង មានលោកស្រី ដាយអាណា អេលីស ជាមេធាវីការពារក្តីជនជាប់ចោទ អៀង ធីរិទ្ធ និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានលោក ពេជ អង្គ និងមានលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត មានវត្តមាន។

បាទ សូមជម្រាបប្រសាសន៍លោកប្រធានអង្គសវនាការទាំងមូល។

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមកត់សម្គាល់ថា ដើម្បីជួយសម្រួលដល់ជនជាប់ចោទនៅក្នុងករណីនេះ អង្គជំនុំជម្រះតម្រូវឲ្យមានសន្តិសុខសវនាការពីររូប ដើម្បីជួយសម្រួលដល់ជនជាប់ចោទ។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចជាថ្មី ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ។ បន្តផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងសំណុំរឿង០០២ ដោយឥតកំណត់រយៈពេល។ បង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ជាបន្ទាន់។ រំឭកដល់ជនជាប់ចោទនូវលក្ខខណ្ឌមួយចំនួនស្របតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង។

<u>អំពីបណ្តឹងសាទុក្ខ</u>

សេចក្តីសម្រេចនេះត្រូវបានភាគីនៃរឿងក្តីធ្វើបណ្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូល៖

[០៩:៥៣:៥៧]

១) សហព្រះរាជអាជ្ញាបានដាក់សំណើសុំផ្អាកការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ និងបណ្តឹងសាទុក្ខភ្លាមៗនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២។ ប្រធានអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេច ដោយបដិសេធសំណើសុំរបស់សហព្រះរាជអាជ្ញា ហើយបង្គាប់ឲ្យដោះលែងជនជាប់

ចោទ អៀង ធីរិទ្ធ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២។

សហមេធាវីការពារក្តីបានដាក់សំណើសុំឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតបង្អង់ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២។

សហព្រះរាជអាជ្ញាបានដាក់សារណាបន្ថែមរបស់ខ្លួននៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២។

សហមេធាវីការពារក្តីបានដាក់សារណាតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២។

ជនជាប់ចោទ លោកស្រីនៅក្នុងនីតិវិធីនេះត្រូវបានចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់អ្នកមិនទាន់បានរកឃើញ។ លោកស្រីមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់និងសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន និងនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការជំនុំជម្រះ លោកស្រីមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

ជាបន្តសូមអញ្ជើញលោកចៅក្រមអានរបាយការណ៍!

**ចៅក្រម សោម សិរិវឌ្ឍៈ**

របាយការណ៍បណ្តឹងសាទុក្ខអនុលោមតាមវិធាន១០៨(៥) នៃវិធានផ្ទៃក្នុង។ ដោយមានការចាត់តាំងរបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូល និងក្នុងនាមជាចៅក្រមរបាយការណ៍សម្រាប់បណ្តឹងសាទុក្ខនេះ យើងចៅក្រមរបាយការណ៍សូមអានរបាយការណ៍ដែលបានលើកឡើងអំពីបញ្ហាអង្គហេតុពាក់ព័ន្ធ ហើយនិងចំណុចសំខាន់ៗនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការវាយតម្លៃឡើងវិញ អំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ដែលត្រូវបានប្តឹងសាទុក្ខមកអង្គជំនុំជម្រះតុលាការកំពូល។

[០៩:៥៦:២៦]

ក) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

សេចក្តីសម្រេចដែលរងការជំទាស់នេះបានតម្កល់ជាថ្មីថា “ជនជាប់ចោទអៀង ធីរិទ្ធ មិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ជនជាប់ចោទទទួលបានការព្យាបាលបន្ថែមពីអ្នកជំនាញ”។ ដោយហេតុថាពុំមានក្តីសង្ឃឹមសមហេតុផលណាមួយសម្រាប់ជនជាប់ចោទ ក្នុងការទទួលបាននូវសម្បទាខាងបញ្ញាស្មារតីឡើងវិញនាពេលអនាគតនោះ ទើបអង្គជំនុំជម្រះ

សាលាដំបូងប្រកាសបន្តផ្អាកកិច្ចដំណើរការនីតិវិធីដោយមិនកំណត់រយៈពេល។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ខ្លួនពុំមានយុត្តាធិការលើជនជាប់ ដោយសារខ្លួនពុំមានមូលដ្ឋានច្បាប់ច្បាស់លាស់ក្នុងការដាក់លក្ខខណ្ឌដោយបង្ខំ ឬដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដល់ជនជាប់ចោទ បន្ទាប់ពីត្រូវបានដោះលែង។ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដោះលែងជនជាប់ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ។

[០៩:៥៧:៣៣]

ខ) ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ សាលាដំបូងរាជធានីភ្នំពេញបានជ្រើសតាំងលោកស្រី អៀង វិជីតា ដែលត្រូវជាកូនរបស់ជនជាប់ចោទជាអ្នកអាណាព្យាបាលទូទៅ។

គ) អំពីបណ្តឹងសាទុក្ខធ្វើឡើងដោយសហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញាលើកឡើងថា "អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដែលបានផ្អាកយុត្តាធិ-ការរបស់ខ្លួនលើជនជាប់ និងថា ការដោះលែងនេះគប្បីស្ថិតក្រោមលក្ខខណ្ឌនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ជាពិសេសសហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះដាក់នូវលក្ខខណ្ឌចំនួន ៦ចំណុចដូចខាងក្រោម៖

១) បង្គាប់ឱ្យជនជាប់ស្នាក់នៅក្នុងលំនៅដ្ឋានជាក់លាក់មួយដែលសហមេធាវីការពារក្តីរបស់ខ្លួនត្រូវប្រាប់ពីអាសយដ្ឋាននោះ។

២) បង្គាប់ឱ្យបង្ហាញខ្លួនមួយសប្តាហ៍ម្តង ដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីផ្លូវការដែលចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូងត្រួតពិនិត្យពីសុវត្ថិភាព។

៣) បង្គាប់ឱ្យជនជាប់ចោទប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណ។

៤) មិនត្រូវទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយនឹងជនជាប់ចោទដទៃទៀត លើកលែងប្តីរបស់ខ្លួន គឺ អៀង សារី ហើយនិងសាក្សី អ្នកជំនាញ ឬជនរងគ្រោះណាមួយដែលនឹងត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៥) មិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ។

៦) ត្រូវស្ថិតក្រោមការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ៦ខែម្តង ដោយអ្នកអនុវត្តផ្នែកវេជ្ជសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងបានចាត់តាំង។

[០៩:៥៩:២២]

ឃ) សារណាតបរបស់មេធាវីការពារក្តី

មេធាវីការពារក្តីលើកឡើងថា ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងក្រោមលក្ខខណ្ឌដោយបង្ខំ ពុំមានយុត្តិកម្មផ្លូវច្បាប់ និងពុំមែនជាគោលបំណងសមស្របសម្រាប់ការផ្អាកកិច្ចដំណើរការនីតិវិធីដោយមិនកំណត់រយៈពេល ដោយសារតែពុំមានក្តីសង្ឃឹមសមហេតុផលណាមួយដល់ជនជាប់ចោទក្នុងការជំនុំជម្រះ និងសមត្ថភាពអាចចងចាំ អាចយល់ ឬគោរពតាមលក្ខខណ្ឌដោយបង្ខំលើរូបគាត់។ បន្ថែមលើនេះទៀត មេធាវីការពារក្តីជំទាស់ថា ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅនេះ នឹងមិនបានជួយដល់ការអនុវត្តលក្ខខណ្ឌដោយបង្ខំនោះទេ ដោយសារតួនាទីនេះ ពុំមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជម្រះពិនិត្យសម្រេច។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២

ចៅក្រម សោម សិរីវឌ្ឍ, ចៅក្រម អាកនីស្កា ក្លូឈ្វីកកា មីឡូត

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្ត សូមអញ្ជើញសហព្រះរាជអាជ្ញា ធ្វើសេចក្តីសន្និដ្ឋានអំពីបណ្តឹងសាទុក្ខរបស់ខ្លួន!

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។

ថ្ងៃនេះសហព្រះរាជអាជ្ញានឹងធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់លើបណ្តឹងសាទុក្ខ ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីអំពីការដោះលែងជនជាប់ចោទអៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌ។

[១០:០១:១៤]

**ប្រធានអង្គជំនុំ៖**

លោកស្រី ស្តាប់អត់ឮទេ។ និយាយឲ្យឮៗបន្តិចបាទ!

**កញ្ញា សុង ឆវ័ន្ត៖**

អស់លោក លោកស្រីចៅក្រមជាទីគោរព!

អស់លោក លោកស្រីបានបង្គាប់ឲ្យនាងខ្ញុំធ្វើសេចក្តីសន្និដ្ឋានលើទឡ្ហីករណ៍ទី៣ និងទី៤ នៃបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា--

**លោកស្រី ដាយអាណា អេលីសៈ**

សូមអភ័យទោសលោកប្រធាន។ ខ្ញុំសូមទោសដែលត្រូវរំខានខាងព្រះរាជអាជ្ញា ប៉ុន្តែយើងយល់ថា បញ្ហានៅពេលព្រឹកនេះ គឺការបញ្ចេញមតិ និងការចោទសួរទៅលើលោកស្រី អៀង ធីរិទ្ធ។ ខ្ញុំលើកយកចំណុចទាំងអស់នេះ ព្រោះថា ខ្ញុំបានជួបជាមួយកូនស្រីរបស់គាត់នៅព្រឹកនេះ យើងយល់ថា វាជាការលំបាកមែនទែនចំពោះលោកស្រី អៀង ធីរិទ្ធ ក្នុងការ -- ដោយសារជំហររបស់គាត់ នៅពេលដែលគាត់ត្រូវអង្គុយអស់រយៈពេលយូរ។

[១០:០២:១៣]

ដូច្នេះ ខ្ញុំគិតថា វាៗពិបាកសម្រាប់គាត់ ដែលគាត់ត្រូវមកអង្គុយឲ្យបានយូរលើសពីរាប់សិបនាទី។ ដូច្នេះយើងយល់ថា គួរតែចោទសួរលោកស្រី ប្រសិនបើភាគីនានាចង់សាកសួរ មុនពេលដែលលើកនូវសារណានានា។ ដូច្នេះ នេះគឺជាការព្រួយបារម្ភរបស់ខ្ញុំ ព្រោះថាប្រសិនបើយើងមិនធ្វើដូច្នេះទេ យើងប្រហែលជាមិនអាចទទួលបាននូវគោលបំណង ដូចដែលយើងចង់បាននោះឡើយ។ ព្រោះគាត់អាចថានឹងមិនមានស្មេរ -- ស្ថិតស្មេរបានយូរ ប្រសិនបើឲ្យគាត់អង្គុយដោយយូរនោះ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំចង់ដឹងដែរថា តើខាងលោកស្រី -- ខាងជនជាប់ចោទអាចអង្គុយបន្តទៅទៀតបាន ឬក៏យ៉ាងណា? ហើយសូមលោកមេធាវីសួរគាត់ឲ្យបានច្បាស់លាស់មើល៍!

[១០:០៣:២៤]

*(មេធាវីការពារក្តីប្រឹក្សាជាមួយជនជាប់ចោទ)*

[១០:០៥:០៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីសូមអញ្ជើញ!

**លោកស្រី ដាយអាណា អេលីសៈ**

លោកប្រធានខ្ញុំសូមអភ័យទោសចំពោះអ្វីដែលបានកើតឡើង។ បញ្ហាលំបាកដែលយើងជួបប្រទះគឺថា យើងពិបាកក្នុងការឲ្យលោកស្រី អៀង ធីរិទ្ធ យល់អំពីបញ្ហានេះ ព្រោះថានៅព្រឹកនេះខ្ញុំបាននិយាយ

ជាមួយនឹងលោកស្រី អៀង វិជីដា ដើម្បីសាកសួរអំពីការសម្របសម្រួលនានា ដែលត្រូវជួយដល់លោកស្រី អៀង ធីរិទ្ធ ក្នុងការឆ្លើយតប ហើយខ្ញុំគេបានជម្រាបប្រាប់ខ្ញុំថា ដូចជាមាន -- គឺថាលោកស្រី អៀង ធីរិទ្ធ មិនអាចអង្គុយឲ្យបានយូរនោះទេ។ លោកស្រី អៀង ធីរិទ្ធ មានបញ្ហាផ្នែករូបរាងកាយ ប្រសិនបើគាត់ត្រូវអង្គុយយូរគាត់ទាមទារឲ្យបានសម្រាក ឬក៏ឲ្យបានគេង។

[១០:០៦:០៣]

ដោយសារហេតុផលទាំងអស់នេះហើយ ទើបខ្ញុំគិតថា លោក លោកស្រីចៅក្រម ប្រសិនបើចង់ឲ្យបានសម្រេចគោលដៅល្អនោះ គួរតែចោទសួរគាត់នៅពេលដំបូងតែម្តង គឺថាចាប់ផ្តើមសួរគាត់ភ្លាមៗតែម្តង។

[១០:០៦:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៦:៤១]

**ប្រធានអង្គជំនុំ៖**

បាទ ដើម្បីសម្រួលដល់ជនជាប់ចោទ ដែលគាត់មិនអាចអង្គុយយូរបាន ខ្ញុំគិតថា សូមខាងផ្នែកសន្តិសុខសវនាការ លោកស្រីទាំងពីរនាក់សូមអាចអញ្ជើញជនជាប់ចោទឲ្យទៅនៅក្នុងបន្ទប់រង់ចាំដែលយើងបានរៀបចំរួចហើយ។

អ៊ីចឹងលោកស្រីមេធាវីមានយោបល់យ៉ាងម៉េចដែរ?

**លោកស្រី ដាយអាណា អេលីស៖**

មិនមានបញ្ហាអ្វីទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

--*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**អ្នកបកប្រែ៖**

សូមគោរពលោកប្រធាន មីក្រូហ្វូនរបស់លោកប្រធានអត់ទាន់បើក។ សូមអធ្យាស្រ័យ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

យើងយល់ឃើញថា គឺមានមធ្យោបាយដើម្បីជួយសម្រួលដល់ជនជាប់ចោទ ដូច្នេះជនជាប់ចោទគាត់អាចសម្រាក អាចទម្រេត ឲ្យបានស្រួលនៅពេលដែលគាត់តាមដានកិច្ចដំណើរការនីតិវិធី ព្រោះថា

គាត់មិនត្រូវបានគេឃុំខ្លួននោះឡើយ។ ដូច្នេះការដែលយកគាត់ទៅដាក់បន្ទប់ឃុំខ្លួនខាងក្រោមហ្នឹងគឺសម្រាប់តែជនជាប់ចោទតែប៉ុណ្ណោះ។ ហើយជន -- លោកស្រី អៀង ធីរិទ្ធ មិនមានបញ្ហានោះឡើយ។

[១០:០៨:២៦]

**លោកស្រី ដាយអាណា អេលីស៖**

យើងគិតថា បន្ទប់ខាងក្រោមនុ៎ងមិនមែនជាបន្ទប់ឃុំខ្លួនទេ វាគ្រាន់តែជាបន្ទប់រង់ចាំ ឬក៏បន្ទប់ដើម្បីសម្រាកតែប៉ុណ្ណោះ។ ដូច្នេះយើងអរគុណចំពោះអង្គជំនុំជម្រះដែលបានជួយសម្រួលដល់យើង។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាបន្តគឺ សូមអញ្ជើញសហព្រះរាជអាជ្ញាបន្តធ្វើសេចក្ដីសន្និដ្ឋាន។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការជាថ្មីម្ដងទៀត មួយសាទៀត។

ថ្ងៃនេះសហព្រះរាជអាជ្ញានឹងធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ លើបណ្ដឹងសាទុក្ខប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌ។

លោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព! អស់លោក លោកស្រីបានបង្គាប់ឲ្យយើងខ្ញុំធ្វើសេចក្ដីសន្និដ្ឋានទៅលើទឡ្ហីករណ៍ទី៣ និងទី៤ នៃបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២។ ហើយនៅពេលនេះ ខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្ញុំជាបីផ្នែក។

ផ្នែកទី១ ខ្ញុំនឹងនិយាយដោយយោងយ៉ាងសង្ខេបខ្លីទៅដល់ការរកឃើញនានារបស់អង្គជំនុំជម្រះសាលាដំបូងខាងផ្នែកអង្គហេតុ ដែលមានផលប៉ះពាល់ទៅលើបញ្ហាផ្សេងៗដែលមាននៅចំពោះមុខអស់លោក លោកស្រីចៅក្រម។

ផ្នែកទី២ ខ្ញុំនឹងធ្វើសេចក្ដីសន្និដ្ឋានទៅលើចំណុចទី៣ នៃបណ្ដឹងសាទុក្ខ គឺការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង លើលក្ខខណ្ឌចំនួន៦ដែលបានស្នើដោយដាក់កម្រិតទៅលើការដោះលែងអៀង ធីរិទ្ធ។ រីឯផ្នែកទី៣ ខ្ញុំនឹងធ្វើការលើកឡើងអំពីទឡ្ហីករណ៍ទី៤នៃបណ្ដឹងសាទុក្ខ ការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង លើលក្ខខណ្ឌដែលថា លក្ខខណ្ឌកម្រិតទាំងនោះ គឺមិនមានប្រសិទ្ធភាពអនុវត្ត

ឬមិនអាចអនុវត្តបាន។

នៅត្រង់កថាខណ្ឌទី២៤ នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបានថែងអំពីការរកឃើញរបស់ខ្លួនថា "វាមានភាពចុះខ្សោយខាងសតិបញ្ញារបស់ អៀង ធីរិទ្ធ"។ ជាសង្ខេបអង្គជំនុំជម្រះបានរកឃើញថា អៀង ធីរិទ្ធ ទទួលរងនូវស្ថានភាពជំងឺវង្វេងស្មារតី ដែលភាគច្រើន គឺដូចជាជំងឺអាល់ហ្សៃមើ។ ជំងឺនេះបានបណ្តាលឲ្យមានការបាត់បង់ការចងចាំក្នុងរយៈពេលខ្លី និងរយៈពេលវែងដែលបានរារាំង អៀង ធីរិទ្ធ ពុំអាចយល់ដឹងគ្រប់គ្រាន់នូវការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីឲ្យបានពេញលេញ និងដើម្បីឲ្យគាត់អាចប្រាប់ទៅមេធាវីការពារក្តីរបស់គាត់ឲ្យបានគ្រប់គ្រាន់ និងអាចចូលរួមនៅក្នុងកិច្ចការពារខ្លួនរបស់គាត់ឲ្យមានប្រសិទ្ធភាពបាននោះ។

[១០:១១:២២]

អង្គជំនុំជម្រះសាលាដំបូង ក៏បានធ្វើការកត់សម្គាល់ផងដែរថា អៀង ធីរិទ្ធ ទំនងជាមិនមានលទ្ធភាពអាចផ្តល់សក្ខីកម្មបាននៅពេលសវនាការ។

សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី មិនមានបញ្ហាអ្វីទេជាមួយនឹងការរកឃើញទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលបានលេចចេញពីការរកឃើញទាំងនេះ គឺថា អៀង ធីរិទ្ធ មិនបានបាត់បង់លទ្ធភាពខាងសតិបញ្ញាទាំងស្រុងនោះទេ។ ជាឧទាហរណ៍ ខណៈដែលសតិបញ្ញាស្មារតីរបស់គាត់បានចុះខ្សោយ អង្គជំនុំជម្រះមិនបានរកឃើញថា អៀង ធីរិទ្ធ មិនមានលទ្ធភាពអាចធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលនៅជុំវិញខ្លួនគាត់ ឬអាចយល់បាននូវសេចក្តីណែនាំរបស់គាត់បាននោះឡើយ ដូចដែលខ្ញុំនឹងធ្វើការបង្ហាញនៅខាងក្រោមនេះ៖

ការនេះ គឺទាក់ទងទៅនឹងបញ្ហានៃភាពដែលអាចធ្វើបាន និងការដែលដាក់ឲ្យអនុវត្តកើតនូវវិធានការកម្រិតនានាដែលបានស្នើឡើង។

រីឯបញ្ហាស្តីពីការវិវត្តអាចធ្វើឲ្យប្រសើរឡើងខាងបញ្ហាស្មារតីនោះ ការរកឃើញរបស់អង្គជំនុំ-ជម្រះគឺមានលក្ខណៈសមស្របផងដែរ។ នៅត្រង់កថាខណ្ឌទី២៤ អង្គជំនុំជម្រះបានរកឃើញថា វាដូចជាគ្មានការរំពឹងសមហេតុផលដែលថា ការធ្លាក់ចុះខាងផ្នែកបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ អាចត្រូវបានធ្វើឲ្យប្រសើរឡើងបានឡើយ។ និយាយម្យ៉ាងទៀត គឺគេមិនអាចផាត់ចេញទាំងស្រុងនូវលទ្ធភាពនៃការវិលត្រឡប់វិញបានឡើយ។ ការនេះបានឆ្លុះបញ្ចាំងនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យមានលទ្ធភាព នៅក្នុងបន្តធ្វើកិច្ចដំណើរការនីតិវិធីដែលមានកំណត់នៅក្នុងកថាខណ្ឌទី២៨។

[១០:១៣:១១]

អង្គជំនុំជម្រះបានបង្គាប់ឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អៀង ធីរិទ្ធ រហូតដល់មានការបង្គាប់របស់អង្គជំនុំជម្រះឲ្យបន្តកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ។ ក្រោយមកទៀត អង្គជំនុំជម្រះបានថ្លែងនៅត្រង់កថាខណ្ឌទី២៩ថា "ខ្លួនមានចេតនា និងពិគ្រោះយោបល់ជារៀងរាល់ឆ្នាំជាមួយអ្នកជំនាញ ដើម្បីបញ្ជាក់អំពីលទ្ធភាពនៃការរកឃើញការព្យាបាលតាមផ្នែកវេជ្ជសាស្ត្រថ្មីដែលបានតាមយោបល់អ្នកជំនាញថា នឹងអាចជួយស្តារសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទឲ្យចូលរួមសវនាការវិញបាន"។

ផ្នែកនៃសេចក្តីសម្រេចទាំងនេះរបស់អង្គជំនុំជម្រះសាលាដំបូង គឺមានសារៈសំខាន់នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ ដោយហេតុថា ផ្នែកទាំងនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា អង្គជំនុំជម្រះបានទទួលនូវសេចក្តីសន្និដ្ឋានរបស់យើង ដែលបានធ្វើឡើងកាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២។ មានន័យថា បើទោះកាលៈទេសៈនៃការផ្លាស់ប្តូរទាក់ទងទៅនឹងស្ថានភាពរបស់ អៀង ធីរិទ្ធ ទំនងជាមិនមានការផ្លាស់ប្តូរច្រើនយ៉ាងណាក៏ដោយ ក៏មិនមែនមានន័យថា ការបន្តតាមដានត្រូវតែបញ្ចប់នោះទេ។

[១០:១៤:៣៣]

ជាសង្ខេប ជាជំហរបច្ចុប្បន្នគឺថា បើទោះជា អៀង ធីរិទ្ធ មិនមានលទ្ធភាពនៃការចូលរួមសវនាការដ៏ពេញលេញណាមួយ ដែលអាចមើលឃើញបានទៅថ្ងៃអនាគតក៏ដោយ គាត់នៅមានសមត្ថភាពខាងសតិបញ្ញាមួយចំនួន ព្រមទាំងលទ្ធភាពនៃការជាសះស្បើយឡើងវិញ បើទោះជាមានតិចតួចយ៉ាងណាក៏ដោយ ក៏ការបន្តការធ្វើសវនាការមិនអាចបញ្ចប់ទាំងស្រុងនេះដែរ។ ដោយមានសំអាងនេះជាមូលដ្ឋាន ខ្ញុំនឹងនិយាយអំពីទឡ្ហីករណ៍ចំនួនពីរនៃបណ្តឹងសាទុក្ខ ដែលលោក លោកស្រី បានស្នើសុំឲ្យយើងលើកឡើងនាពេលនេះ។

ដូចដែលលោក លោកស្រីចៅក្រមបានចាំថា នៅក្នុងទឡ្ហីករណ៍ទី១នៃបណ្តឹងសាទុក្ខរបស់យើងតាមយុត្តិសាស្ត្រអន្តរជាតិដែលអនុវត្តន៍ជាធរមាន ការដែលបានបង្គាប់ឲ្យមានការផ្អាកកិច្ចដំណើរការនីតិវិធី ដែលអាចសម្រេចត្រឡប់បានវិញនេះ គេបានតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណាថាតើមានវិធានការណា ដែលមានកម្រិតណាមួយត្រូវបានដាក់លើការដោះលែង អៀង ធីរិទ្ធ ដែរឬទេ?

[១០:១៥:៤៤]

ទឡ្ហីករណីទី៣ របស់យើងបានលើកឡើងក្នុងបណ្តឹងសាទុក្ខមានមូលដ្ឋាននៅលើចំណុចនេះ។

យើងសូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងត្រូវមានកាតព្វកិច្ចធ្វើការវាយតម្លៃ និងថ្លឹងថ្លែងអំពីសិទ្ធិ និងផលប្រយោជន៍ដែលមានជាប់ទាក់ទងទៅនឹងការសម្រេច ថាតើមានលក្ខខណ្ឌណាមួយដែលមានលក្ខណៈសមស្របឬទេ?

អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការ ដែលបានបដិសេធមិនព្រមធ្វើការថ្លឹងថ្លែងអំពីសិទ្ធិ និងផលប្រយោជន៍ទាំងនេះ។ តែផ្ទុយទៅវិញ បែរជារកឃើញថា ខ្លួនពុំមានមូលដ្ឋានតាមផ្លូវច្បាប់ដើម្បីដាក់វិធានការដែលមានកម្រិតឲ្យអនុវត្តបានទៅវិញ។ សេចក្តីសម្រេចនេះ មានមូលដ្ឋានមួយផ្អែកទៅលើអ្វីដែលមានក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ។ គឺជាការបកស្រាយមិនត្រឹមត្រូវនូវករណីយុត្តិសាស្ត្រអន្តរជាតិដែលមានជាធរមាន។

[១០:១៦:៤៥]

ខ្ញុំនឹងនិយាយអំពីករណីពាក់ព័ន្ធផ្សេងៗចំនួនបី ដែលអង្គជំនុំជម្រះសាលាដំបូងបានពិចារណា។ សេចក្តីសម្រេចរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងករណី ថាលិក (Talic) និង ជូគិក (Djukic) ហើយនិងសេចក្តីសម្រេចរបស់គណៈកម្មាធិការពិសេស នៅប្រទេសទីម័រខាងកើត សម្រាប់បទល្មើសធ្ងន់ធ្ងរនៅក្នុងករណី ណាហាក។ អង្គជំនុំជម្រះសាលាដំបូងបានស្វែងរកពីការខុសគ្នានៃករណីទាំងនេះទៅនឹងករណី អៀង ធីរិទ្ធ យើងខ្ញុំមិនឯកភាពត្រង់ចំណុចនេះនោះទេ។ ហើយសូមសន្និដ្ឋានថា គោល-ការណ៍នានាដែលបានដាក់ចេញមកពីករណីទាំងនេះ គួរតែត្រូវបានយកមកធ្វើជាគោលការណ៍ណែនាំសម្រាប់វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងករណីនេះ។

[១០:១៧:៣៣]

ថាលិក និង ជូគិក ទាំងពីរនាក់នេះ គឺមានជំងឺដែលមិនអាចព្យាបាលបាន។ អ្នកទាំងពីរត្រូវបានគេដោះលែង ខណៈដែលកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានផ្អាក។ នៅពេលដែលគេធ្វើការដោះលែងពួកគាត់ ជនជាប់ចោទទាំងពីរនាក់នេះ ពុំមានលទ្ធភាពទៅថ្ងៃខាងមុខថានឹងជាសះស្បើយនោះឡើយ។ ហើយទាំងពីរករណីនេះ គឺច្បាស់លាស់ណាស់ថា ការបន្តធ្វើសវនាការមួយប្រឆាំងនឹងជនជាប់ចោទទាំងពីរនាក់នេះ គឺជាក់ស្តែងមិនអាចទៅរួចស្មើរតែទាំងស្រុងតែម្តង។ ហើយបើទោះជាយ៉ាងនេះក៏ដោយ ក៏តុលាការ អាយ.ស៊ី.ធី.វ៉ាយ មិនបានដោះលែងពួកគេទាំងពីរនាក់ ដោយគ្មានលក្ខណៈនោះឡើយ គឺបានដាក់កម្រិតមួយចំនួន ទៅលើការដោះលែងជនជាប់ចោទនោះ។

អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានញែកករណី ថាលិក ឲ្យឃើញខុសគ្នា ដោយឈរ

លើមូលដ្ឋាននៅក្នុងករណីនេះថា មានការខ្វែងយោបល់គ្នា រវាងអ្នកជំនាញពីរឿង ថាតើជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមនៅក្នុងសវនាការដែរ ឬមួយយ៉ាងណា?

ចំណុចទី១ ភាពខុសគ្នារវាងអ្នកជំនាញនៅក្នុងករណី ថាលិក ដែលទាក់ទងតែទៅនឹងសម្បទារបស់ជនជាប់ចោទនៅក្នុងការចូលរួមសវនាការតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

ចំណុចទី២ ភាពខុសគ្នានៃគំនិតយោបល់ គឺមិនជាប់ទាក់ទងទេ ពីព្រោះសម្បទានៅក្នុងការចូលរួមសវនាការ គឺតុលាការជាអ្នកកំណត់ មិនមែនកំណត់ដោយអ្នកជំនាញនោះទេ។

[១០:១៩:១៩]

ចំណុចទី៣ និងជាចំណុចសំខាន់បំផុតនោះ គឺគ្រប់អ្នកជំនាញទាំងបីបានទទួលយកថា ថាលិកបានទទួលរងនូវទម្រង់នៃជំងឺមហារីកម្យ៉ាង ដែលមិនអាចព្យាបាលជាបានទេ ហើយថាគាត់នឹងស្លាប់នៅក្នុងរយៈពេលដ៏ខ្លីខាងមុខ ដោយជៀសមិនផុតឡើយ។

អង្គជំនុំជម្រះសាលាដំបូង អាយ.ស៊ី.ធី.វ៉ាយ បានសម្រេចចំណុចនេះ នៅក្នុងកថាខណ្ឌទី២៣ នៃសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២។ សូមដកស្រង់ “ការពិតជាក់ស្តែងនៃស្ថានភាពវេជ្ជសាស្ត្ររបស់ ថាលិក គឺថាសម្រាប់រូបគាត់ វាពុំមានការគេចរួចណាមួយពីផលវិបាកធម្មជាតិដែលជំងឺរបស់គាត់នឹងនាំយកមកជាចុងក្រោយ។ ពីព្រោះស្ថានភាពរបស់គាត់មិនអាចព្យាបាលបាន និងមិនអាចធ្វើការវះកាត់បាន ហើយមានតែខូចខាតទៅៗប៉ុណ្ណោះ ទោះជាមានឬពុំមានការព្យាបាលក៏ដោយ។ ហើយជាក់ស្តែងគឺថា ការដែលមានសង្ឃឹមថាគាត់នឹងមានជីវិតរស់នៅ១ឆ្នាំទៅមុខ ចាប់ពីឥឡូវនេះទៅ គឺពិតជាមានតិចតួចបំផុត”។ បញ្ចប់ការដកស្រង់។

[១០:២០:៤២]

មូលដ្ឋានមួយផ្សេងទៀត នៅក្នុងការវែកញែកករណីរបស់ ថាលិក ឲ្យខុសពីករណីរបស់ អៀង ធីរិទ្ធ គឺអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានថ្លែងថា “នៅក្នុងករណី ថាលិក តុលាការ អាយ.ស៊ី.ធី.វ៉ាយ បានបដិសេធមិនព្រមធ្វើការកំណត់ជាចុងក្រោយស្តីអំពីសម្បទានោះ។ តាមពិតគឺពុំមានការបដិសេធណាមួយនៅក្នុងការសម្រេចពីសម្បទានោះឡើយ ពីព្រោះពុំមានការដាក់ពាក្យសុំណាមួយចំពោះមុខអង្គជំនុំជម្រះដែលត្រូវសម្រេចអំពីសម្បទានោះទេ។ យោងទៅតាមសម្បទារបស់ជនជាប់ចោទការកំណត់អំពីសម្បទាគឺមិនចាំបាច់ទេ។ គាត់បានទទួលរងនូវជំងឺដែលមិនអាចព្យាបាលបាន ដែលជំងឺនោះមានការវិវត្តយ៉ាងឆាប់រហ័ស ដោយមិនសង្ឃឹមថា នឹងអាចរស់នៅបានយូរតទៅទៀតឡើយ”។

ក្រោយមកទៀត អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានធ្វើការបែងចែកករណី ថាលិក ឲ្យឃើញខុសគ្នាលើមូលដ្ឋានមួយដែលថា លក្ខខណ្ឌនានានៃការដោះលែង គឺត្រូវបានធ្វើយុត្តិកម្មដោយលទ្ធ-ភាពដែលថា នៅពេលក្រោយគាត់អាចនឹងចូលរួមសវនាការបាន នៅត្រង់កថាខណ្ឌទី៦២ នៃចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខ។ សហភាតាដែលជាក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ បានលើកឡើងនូវចំណុចមួយដែលស្រដៀងគ្នា គឺពួកគេបានលើកសំអាងថា ករណី ថាលិក គឺមានភាពខុសគ្នា ដោយសារមានការយោងនៅក្នុងសេចក្ដីសម្រេចរបស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ ទៅនឹងសវនាការរបស់គាត់ដែលកំពុងបន្តដំណើរការ។

[១០:២២:៣៤]

យើងសូមធ្វើសេចក្ដីសន្និដ្ឋានថា ការលើកឡើងដូច្នេះមិនមែនជាការយល់ឃើញដ៏ត្រឹមត្រូវអំពីសេចក្ដីសម្រេចនោះឡើយ។ ការយោងទៅដល់លទ្ធភាពនៃការបន្តដំណើរការនីតិវិធី និងសវនាការដែលកំពុងបន្តដំណើរការនៅក្នុងករណីរបស់ ថាលិក នេះ គួរតែបានយល់នូវអង្គហេតុនានាដូចតទៅ៖ ថាលិក ត្រូវបានចោទប្រកាន់រួមគ្នាជាមួយនឹងជនជាប់ចោទម្នាក់ផ្សេងទៀតគឺ ប៉ែនយ៉ានីន។ នៅខែកញ្ញា ឆ្នាំ ២០០២ សវនាការរបស់ពួកគេគឺកំពុងបន្តធ្វើ ក៏ប៉ុន្ដែ ថាលិក ត្រូវបានកំណត់រោគវិនិច្ឆ័យថា មានជំងឺមហារីកដំណាក់កាលចុងក្រោយ ហើយសេចក្ដីសម្រេចមួយត្រូវបានធ្វើឡើងដើម្បីដោះលែងគាត់ជាបណ្ដោះអាសន្ន។ តាមសេចក្ដីសម្រេចដាច់ដោយឡែកមួយ ដែលបានចេញនៅថ្ងៃជាមួយគ្នានោះ គឺថ្ងៃ ២០ កញ្ញា ឆ្នាំ២០០២ អង្គជំនុំជម្រះសាលាដំបូង អាយ.ស៊ី.ធី.វ៉ាយ បានបំបែកសំណុំរឿងនេះចេញពីសហជនជាប់ចោទរបស់គាត់គឺ ប៉ែនយ៉ានីន។ ជាប្រយោជន៍ដើម្បីឲ្យសំណុំរឿងទី២ អាចបន្តទៅមុខបាន សវនាការរបស់ ថាលិក ត្រូវបានផ្អាក ហើយគេមិនដែលបានធ្វើបន្តទៀតនោះឡើយ។

នៅពេលចេញសេចក្ដីសម្រេចទាំងនោះ ឱកាសក្នុងការបន្តធ្វើសវនាការលើករណី ថាលិក គឺស្ថិតនៅឆ្ងាយដាច់សង្វែង ជាងឱកាសក្នុងការបន្តធ្វើសវនាការក្នុងករណី អៀង ធីរិទ្ធ នេះទៅទៀត។ តាមពិត ថាលិក ត្រូវស្លាប់ក្នុងរយៈពេលចំនួន៩ខែ រាប់ពីថ្ងៃដែលគាត់ត្រូវបានដោះលែងមក។

[១០:២៤:០៣]

លោកប្រធានជាទីគោរព! យើងខ្ញុំសូមជូនជាយោបល់ថា ភាពខុសគ្នារវាងករណី ថាលិក នៅក្នុងរឿង និងរឿងក្ដីរបស់ អៀង ធីរិទ្ធ ដូចដែលបានលើកឡើងគឺជាការប្រឌិត និងមិនគួរឲ្យជឿឡើយ។ រាល់រឿងក្ដីទាំងអស់គួរតែត្រូវបានសម្រេចដោយផ្អែកលើអង្គសេចក្ដី នៃរឿងក្ដីនីមួយៗផ្ទាល់។ ប៉ុន្ដែ

គោលការណ៍លេចឡើងនៅក្នុងរឿងក្តីរបស់ ថាលិក មិនគួរធ្វើមិនដឹងមិនឮនោះឡើយ។ សវនាការជំនុំជម្រះរឿងក្តី ថាលិក មិនអាចធ្វើបន្តទៅទៀតបាន ហើយត្រូវផ្អាកដោយគ្មានកាលកំណត់។ ការពន្យារអំពីលទ្ធភាពក្នុងការបន្តសវនាការឡើងវិញ ត្រូវបានគេពិនិត្យឃើញថា គឺស្ថិតនៅក្នុងកម្រិតមួយយ៉ាងតិចតួចបំផុត ស្ទើរតែគ្មាន។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏តុលាការ អាយ.ស៊ី.ធី.វ៉ាយ នៅយល់ឃើញថា ជាការត្រឹមត្រូវ គួរតែដាក់ចេញនូវវិធានការមួយចំនួន ដើម្បីរក្សាការពារសុចរិតភាពនៃដំណើរការនីតិវិធី។

លោកប្រធាន លោក លោកស្រីចៅក្រមបានប្រឈមនឹងស្ថានភាពស្រដៀងគ្នានេះកំពុងប្រឈមនៅក្នុងស្ថានភាពដែលជនជាប់ចោទម្នាក់ត្រូវបានដោះលែង ដែលត្រូវបានគេមើលឃើញថាមិនមានលទ្ធភាពបន្តសវនាការក្នុងរយៈពេលដ៏ឆាប់ៗខាងមុខនេះទេ។ ខណៈដែលសវនាការប្រឆាំងនឹងសហជនជាប់ចោទដទៃទៀតរបស់គេកំពុងបន្តធ្វើ។

[១០:២៥:២៥]

មិនដូចគ្នានៅក្នុងករណីថាលីកនោះឡើយ អៀង ធីរិទ្ធ មិនមានជំងឺដែលមុន -- មុខជានឹងត្រូវស្លាប់នោះឡើយ។ តាមពិតភស្តុតាងដែលយើងបានស្តាប់នៅក្នុងសវនាការបានបង្ហាញថាសុខភាពផ្លូវកាយរបស់គាត់ គឺមានសភាពល្អប្រសើរណាស់សម្រាប់មនុស្សដែលមានវ័យដូចគាត់។ ហេតុដូចនេះនៅក្នុងខណៈដែលគាត់ត្រូវបានជួបប្រទះនឹងស្ថានភាពដូចដូច្នេះ ប្រឈមនឹងឱកាសតិចតួចក្នុងការវិលត្រឡប់ក្នុងកិច្ចដំណើរការនីតិវិធីវិញយ៉ាងណាក៏ដោយ ក៏ឱកាសនៅតែមានច្រើនជាងករណីថាលីកដែរ។ ហើយលើសពីនេះទៅទៀត និងជាចុងក្រោយ អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋមួយដែលមានស្ថានទម្ងន់ទោសធ្ងន់ជាងស្ថានទម្ងន់ទោសបទឧក្រិដ្ឋក្នុងករណីថាលិកត្រូវបានចោទប្រកាន់។ ករណីរឿងក្តី ជូគិក ក៏មានការជាប់ទាក់ទងនេះដែរ។ ដូចដែលខ្ញុំបានបញ្ជាក់កាលពីមុននេះ អង្គហេតុនៃករណីរឿងក្តីនេះគឺមានលក្ខណៈស្រដៀងគ្នាទៅនឹងអង្គហេតុនៅក្នុងករណីរបស់ថាលិក នៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធីមុនការជំនុំជម្រះក្តី។

[១០:២៦:៣៣]

ជនជាប់ចោទត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថា "មានជំងឺដែលស្ថិតនៅក្នុងដំណាក់កាលចុងក្រោយ ដែលស្ថិតក្នុងដំណាក់កាលជឿនលឿនវិវត្តទៅមុខជានិច្ច"។ ការជាសះស្បើយត្រូវបានប្រកាសថា "មិនអាចទៅរួចឡើយ"។ តាមការពិត គាត់បានស្លាប់នៅក្នុងរយៈពេលមិនដល់មួយខែផង បន្ទាប់ពី

ដោះលែងរូបគាត់។ ហើយទោះជាយ៉ាងនេះក៏ដោយក៏អង្គជំនុំជម្រះតុលាការ អាយ.ស៊ី.ធី.វ៉ាយ បានពិចារណាឃើញថា “ចាំបាច់ត្រូវតែតម្រូវនូវវិធានការរឹតត្បិតមួយចំនួនទៅលើការដោះលែងគាត់”។

ដោយញែកដាច់ពីគ្នានូវសេចក្តីសម្រេចនេះចេញពីករណីបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក គ្រាន់តែបានធ្វើការកត់សម្គាល់ថា “ករណីជូគិចត្រូវបានរៀបរាប់នៅក្នុងករណីថាលិក គឺថាការដោះលែងដែលតាមការអនុវត្តដោយគ្មានការដាក់លក្ខខណ្ឌនោះ”។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ រឿងក្តីនេះគឺមានភាពពាក់ព័ន្ធនឹងគ្នា។ ករណីជូគិក គឺត្រូវបានដាក់ឲ្យស្ថិតនៅក្នុងលក្ខខណ្ឌដែលសាមញ្ញជាងលក្ខខណ្ឌដែលគេបានប្រើនៅក្នុងករណីថាលិក ក៏ប៉ុន្តែនេះគឺគ្រាន់តែជាការឆ្លុះបញ្ចាំងមួយអំពីការពិតដែលប្រកាស ដែលករណីនីមួយៗចាប់ផ្តើមប្រើនូវកាលៈទេសៈរបស់ខ្លួន។ អង្គហេតុដែលមិនអាចជជែកតវ៉ានោះ គឺការដោះលែងជូគិចត្រូវបានស្ថិតនៅក្រោមលក្ខខណ្ឌនានាដែលអង្គជំនុំជម្រះនៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងរឿងក្តីនោះបានពិពណ៌នាថា “ការដាក់លក្ខខណ្ឌមានលក្ខណៈតឹងរ៉ឹង”។

[១០:២៨:១០]

ហើយករណីយុត្តិសាស្ត្រទី៣ ដែលអង្គជំនុំជម្រះសាលាដំបូងបដិសេធមិនអនុវត្ត គឺសេចក្តីសម្រេចចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០០៥ របស់គណៈកម្មាធិការពិសេសសម្រាប់ដោះស្រាយករណីរឿងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅទីម័រខាងកើត នៅក្នុងករណីរបស់ណាហាក។ នៅក្នុងរឿងក្តីនោះ ជនជាប់ចោទត្រូវបានរកឃើញថា “មិនមានសម្បទាគ្រប់គ្រាន់អាចចូលរួមនៅក្នុងសវនាការបានឡើយ ដោយមកពីស្ថានភាពខាងផ្នែកវិកលចរិតដែលអូសបន្លាយអស់រយៈពេលជាយូរមកហើយ”។ សវនាការជំនុំជម្រះក្តីរបស់គាត់ត្រូវផ្អាក ហើយរូបគាត់ត្រូវបានបញ្ជាឲ្យស្ថិតនៅក្រោមស្ថានភាពដែលមានការរឹតត្បិតមួយចំនួន។

អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានថ្លែងថា “គ្មានការធ្វើយុត្តិកម្មខាងផ្លូវច្បាប់ណាត្រូវបានផ្តល់សម្រាប់ការបញ្ហានោះឡើយ”។ យើងសូមជូនសេចក្តីសន្និដ្ឋានថា “នេះគឺជាការបកស្រាយដោយមិនត្រឹមត្រូវនូវសេចក្តីសម្រេចនោះ”។

[១០:២៩:០៥]

ចៅក្រមនៅក្នុងរឿងក្តីរបស់ណាហាក បានបញ្ជាក់យ៉ាងច្បាស់ថា “មូលដ្ឋានសម្រាប់ការបន្តដាក់វិធានការរឹតត្បិតនេះប្រឆាំងនឹងជនជាប់ចោទ គឺស្ថិតនៅក្នុងស្ថានភាពមួយដែលលទ្ធភាពតិចតួចបំផុតក្នុងការបន្តសវនាការអាចបន្តទៅទៀត”។ ចំណុចនេះអាចរកមើលឃើញនៅក្នុងកថាខណ្ឌ១៥៧ ដល់

១៦៤ នៃសេចក្តីសម្រេចនេះ។ លើសពីនេះទៅទៀត នៅក្នុងរបៀបមួយដែលស្រដៀងគ្នាទៅនឹងអ្វីដែលយើងបានស្នើនៅចំពោះមុខអង្គជំនុំជម្រះ លោកចៅក្រមនៅក្នុងរឿងក្តីរបស់ណាហាក់បានជម្រាបជូនអយ្យការក៏ដូចជាក្រុមមេធាវីការពារអាចស្នើសុំឲ្យមានការកែប្រែលក្ខខណ្ឌកម្រិតនោះ ប្រសិនបើកាលៈទេសៈណាមួយមានការផ្លាស់ប្តូរ។

អង្គសវនាការជាទីគោរព! នៅក្នុងខណៈដែលយុត្តិសាស្ត្រច្បាប់សម្រាប់ -- ច្បាប់ចាំបាច់ត្រូវមានព្រំដែនកំណត់ គេត្រូវតែពិនិត្យទៅលើខ្លឹមសារនៃករណីរឿងដែលមានស្រាប់មួយចំនួន ហើយពិចារណាថាតើនៅក្នុងនោះបានផ្តល់ការណែនាំអ្វីខ្លះ? នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង សេចក្តីសម្រេចទាំងនោះ គឺជាប្រភពអំណាចមួយយ៉ាងច្បាស់ សម្រាប់គោលការណ៍ដែលថា នៅក្នុងករណីមានឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ដែលការផ្អាកកិច្ចដំណើរការនីតិវិធី ត្រូវធ្វើសេចក្តីសម្រេចដោយផ្លាស់ប្តូរសេចក្តីសម្រេចមុន ទោះបីជាការចាប់ផ្តើមបើកសវនាការវិញមានលទ្ធភាពតិចតួចយ៉ាងណាក៏ដោយ ក៏ជាការសម្រេចសមស្រប គួរតែធ្វើការពិនិត្យពិចារណា ដើម្បីដាក់នូវវិធានការកំហិតមួយចំនួនទៅលើជនជាប់ចោទម្នាក់ ដែលកំពុងត្រូវបានគេដោះលែងនោះ។ តាមពិតវិធានការអ្វីខ្លះដែលសមស្រប និងចាប់ផ្តើមបង្ហាញពីអង្គហេតុនៅក្នុងករណីនីមួយៗ ហើយនៅក្នុងករណីរឿងក្តីខ្លះ វិធានការមានលក្ខណៈទូលំទូលាយ ដូចជានៅក្នុងរឿងក្តីរបស់ ថាលិក នេះ។ នៅក្នុងករណីផ្សេងទៀត ដូចជានៅក្នុងរឿងក្តីរបស់ ជូគិក និង ណាហាក។

[១០:៣០:៥២]

ក៏ប៉ុន្តែ មិនអាចនិយាយបាននៅពេលដែលមានការផ្អាកមួយ ត្រូវបានសម្រេចហើយ អង្គជំនុំជម្រះសាលាដំបូងថា មិនមានយុត្តាធិការ ដើម្បីពិនិត្យមើលលើដីកាសម្រេច ដែលមានការរឹតត្បិតណាមួយនោះឡើយ។ តាមពិត ករណីយុត្តិសាស្ត្រតាមច្បាប់អន្តរជាតិ បានកំណត់ថា វិធានការណាមួយដែលមានការរឹតត្បិតចំពោះសិទ្ធិ ឬសេរីភាពរបស់បុគ្គល តោងតែវាមានសមាមាត្រគ្នាជាមួយនឹងគោលបំណង ដែលស្វែងរក ដែលត្រូវធ្វើឲ្យបានសម្រេច។

នៅក្នុងសេចក្តីសម្រេចក្នុងករណីរបស់ ថាលិក តុលាការ អាយ.ស៊ី.ធី.វ៉ាយ បានសម្រេចនៅត្រង់កថាខណ្ឌទី២៣ ថា ដើម្បីឲ្យសមាមាត្រទៅនឹងវិធានតោងតែមានភាពសក្តិសម និងចាំបាច់ក្នុងការអនុវត្ត។ លើសពីនេះ កម្រិត និងទំហំនៃវិធាន តោងតែស្ថិតនៅក្នុងភាពទំនាក់ទំនងគ្នាឲ្យសមហេតុផលជាផងដែរ ដើម្បីប្រមើលមើលជាមុនអំពីគោលដៅដែលអាចអនុវត្តបាន។

នេះគឺជាសេចក្តីសន្និដ្ឋានរបស់យើង ដែលស្នើសុំវិធាន និងការកំហិតដ៏សាមញ្ញចំនួន៦ ដែលយើងខ្ញុំបានស្នើ គឺមានលក្ខណៈវិនិច្ឆ័យសមស្រប និងចាំបាច់។

ដំបូងខ្ញុំនឹងដោះស្រាយចំពោះគោលដៅនានា ដែលស្នើសុំដើម្បីធ្វើឱ្យបានសម្រេចតាមវិធានការដែលមានកំហិតមួយចំនួន។ ម្យ៉ាង ចាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមក គឺហាក់ដូចជាថា អង្គជំនុំជម្រះបានយល់ឃើញថា គោលដៅតែមួយប៉ុណ្ណោះដែលត្រូវរក្សាការពារ គឺការចូលរួមរបស់ជនជាប់ចោទនៅក្នុងសវនាការ នោះគឺត្រូវបានបង្កប់ន័យនៅក្នុងការវែកញែកហេតុផលរបស់អង្គជំនុំជម្រះថា គ្មានវិធានការណាដែលអាចត្រូវបានដាក់តម្រូវទៅលើជនជាប់ចោទណាម្នាក់ឡើយ បើសិនជាមិនមានគោលគម្រោងសម្រាប់អនាគតណាមួយ ដែលមានភាពសមហេតុផលថា ជនជាប់ចោទនឹងត្រូវធ្វើការជំនុំជម្រះក្តី នៅពេលអនាគតណាមួយ ដែលគេអាចទាយទុកជាមុនបាននោះ។

[១០:៣២:៥៦]

កថាខណ្ឌទី៣៣ តាមពិត នេះគឺពិតជាការបកស្រាយច្បាប់ ដែលមានលក្ខណៈចង្អៀតហួសហេតុ ជាពិសេស គឺតាមស្មារតីនៃវិធាន៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ដែលចែងអំពីផលប្រយោជន៍ជារួមទាំងមូល ដែលអាចបង្កើតបានទៅជាមូលដ្ឋានសម្រាប់ដីកាសម្រេចក្នុងការឃុំខ្លួន។ ក៏ប៉ុន្តែការដាក់ចេញនូវវិធានការមួយចំនួន ដែលមិនមានលក្ខណៈចាប់បង្ខំឱ្យអនុវត្ត ដូចជាសំណើឬការស្នើសុំទៅកាន់ជនជាប់ចោទនោះ អង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាកំពុងតែព្យាយាមការពារនូវផលប្រយោជន៍មួយចំនួនដល់ដ៏ទូលំទូលាយពេក។ បន្ថែមពីលើការស្នើសុំឱ្យជនជាប់ចោទស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវជូនព័ត៌មានដល់ អ.វ.ត.ក បើសិនមានការផ្លាស់ប្តូរអាសយដ្ឋាន។ អង្គជំនុំជម្រះសាលាដំបូងបានរំឭកដល់ជនជាប់ចោទអំពីកាតព្វកិច្ចរបស់ខ្លួន ដែលមិនត្រូវជ្រៀតជ្រែកនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ ហើយស្នើឱ្យគាត់មិនត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មាននានា ពាក់ព័ន្ធអំពីដំណើរការនីតិវិធីទាំងឡាយនោះ។

[១០:៣៤:០៣]

សំណើទាំងនេះ បានជួយឱ្យងាយស្រួលដល់ការបំពេញបានសម្រេចនូវគោលដៅនានាដូចគ្នាចំពោះរាល់វិធានការនានា ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា ដើម្បីធ្វើឱ្យបានសម្រេចនៅក្នុងគោលដៅ ការការពារសាក្សី និងជនរងគ្រោះ កិច្ចការការពារសន្តិសុខដល់ជនជាប់ចោទ រក្សាសណ្តាប់ធ្នាប់សាធារណៈ ហើយជាក់ស្តែងក៏ដើម្បីធានាវត្តមានជនជាប់ចោទនៅក្នុងពេលបើកសវនាការណាមួយ

នាពេលអនាគត។ អង្គជំនុំជម្រះសាលាដំបូងជាក់ស្តែងបានទទួលស្គាល់អំពីភាពចាំបាច់ ត្រូវការពារនូវផលប្រយោជន៍ទាំងនេះ ដោយដាក់ចេញនូវវិធានការ ដែលមិនអាចអនុវត្តបាន ដូចដែលខ្ញុំបាននិយាយខាងដើមរួចមកហើយ។

ខ្ញុំកត់សម្គាល់ថា ត្រង់កថាខណ្ឌទី៦១ នៃសេចក្តី -- នៃចម្លើយតប នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីអៀង ធីរិទ្ធ បានទទួលស្គាល់ថា ការពិចារណាដូចគ្នា តម្រូវឲ្យមានការការពារជនរងគ្រោះ និងការពារសាក្សី បង្កើតជាមូលដ្ឋានក្នុងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

តុលាការជាទីគោរព! យើងខ្ញុំសូមជូនសេចក្តីសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានអំណាចក្នុងការការពារនូវផលប្រយោជន៍ទាំងនេះ បានដោយវិធាន -- ដោយវិធីដាក់ចេញនូវសេចក្តីសម្រេចដែលអាចអនុវត្តបាន។ វិធានការដែលយកមកអនុវត្តបានមួយចំនួនដែលយើងខ្ញុំបានស្នើ គឺមិនមានការជ្រៀតជ្រែកធំដុំដល់សិទ្ធិក្នុងការទទួលបានសេរីភាពរបស់ជនជាប់ចោទនោះឡើយ។ មិនមានសំណើណាមួយដែលស្នើសុំដាក់ឲ្យជនជាប់ចោទរូបនេះ ក្រោមការឃុំខ្លួននៅក្នុងលំនៅដ្ឋាននោះឡើយ។ គ្មានអាសយដ្ឋានដោយឡែកណាមួយត្រូវបានកំណត់ថា ត្រូវឲ្យជនជាប់ចោទស្នាក់ជាអចិន្ត្រៃយ៍នោះឡើយ។

[១០:៣៥:៣៧]

គាត់មានសិទ្ធិក្នុងការដើរហើរ ឲ្យតែគាត់ស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ពោលគឺមិនមានការរារាំងគាត់នោះឡើយ ហើយការធ្វើការត្រួតពិនិត្យសន្តិសុខប្រចាំសប្តាហ៍គឺមិនមែនមានភាពស្មុគស្មាញនោះទេ។ ហើយនឹងអាចរៀបចំសម្រួលក្នុងលក្ខណៈមួយដែលធ្វើឲ្យមានការរំខានដ៏តិចតួចបំផុត ចំពោះសេរីភាពក្នុងការដើរហើររបស់ជនជាប់ចោទ។ ការតម្រូវហាមមិនឲ្យមានការទំនាក់ទំនងជាមួយនឹងសហជនជាប់ចោទផ្សេងទៀត លើកលែងតែស្វាមីរបស់គាត់ចេញ។ ក៏ដូចជាជាមួយនឹងជនរងគ្រោះ សាក្សី ឬអ្នកជំនាញនានា គឺជាវិធានការដ៏សមហេតុសមផលមួយដែលមានភាពចាំបាច់សម្រាប់ធានាប្រឆាំងនឹងការជ្រៀតជ្រែកដ៏មានសក្តានុពលនៅក្នុងកិច្ចដំណើរការនីតិវិធី។

[១០:៣៦:២៥]

យើងខ្ញុំគួរតែធ្វើការរំឭកដោយសេចក្តីគោរពដល់តុលាការថា រហូតដល់ពេលដោះលែងគាត់ ជនជាប់ចោទត្រូវបានដាក់ឲ្យស្ថិតនៅក្នុងមន្ទីរឃុំឃាំង ដើម្បីរក្សាការពារគាត់ប្រឆាំងនឹងហានិភ័យផ្សេងៗដែលអាចកើតមានចំពោះគាត់តែប៉ុណ្ណោះ។

ការតម្រូវឲ្យ អៀង ធីរិទ្ធ ត្រូវឆ្លងកាត់ការពិនិត្យសុខភាពជាប្រចាំ គឺវាមិនមានការខុសប្លែកគ្នាពី

អ្វី ឬខចែងរបស់អង្គជំនុំជម្រះដែលបានធ្វើការពិគ្រោះប្រចាំឆ្នាំជាមួយនឹងអ្នកជំនាញនានា នៃផ្នែកវេជ្ជសាស្ត្រនោះឡើយ។

អស់លោក លោកស្រីចៅក្រមជាទីគោរព! យើងខ្ញុំសូមជូនជាមតិថា ការដាក់នូវវិធានការទាំងនោះ គឺសមហេតុផល និងធ្វើឲ្យមានតុល្យភាពដោយសារម្យ៉ាងការពារសិទ្ធិ និងផលប្រយោជន៍ផ្សេងទៀតរបស់ជនជាប់រងគ្រោះ និងដើម្បីឲ្យសហព្រះរាជអាជ្ញាអាចមើលឃើញថា យុត្តិធម៌ត្រូវបានបំពេញរួចរាល់ និងម្យ៉ាងទៀតភាពចាំបាច់ក្នុងការដាក់កំហិតទៅលើសេរីភាពរបស់ អៀង ធីរិទ្ធ គឺដាក់កំហិតត្រឹមកម្រិតតិចតួចបំផុត។

[១០:៣៧:៣០]

ដូចដែលយើងខ្ញុំបានដាក់ជូននៅពេលសវនាការកាលពីថ្ងៃទី៣១ ខែសីហា រួចហើយ យើងខ្ញុំមិនបានស្នើបន្តនូវវិធានការទាំងនោះ ដោយគ្មានពេលកំណត់នោះឡើយ។ យើងខ្ញុំបានទទួលស្គាល់ថា ចំណុចនៃពេលវេលាអាចនឹងមកដល់ ដែលនៅពេលនោះវិធានការនោះអាចនឹងត្រូវបានបញ្ចប់លែងអនុវត្តបន្តទៀត។ ការធ្វើៗការពិនិត្យឡើងវិញជាប្រចាំរាល់ឆ្នាំ រៀងរាល់៦ខែម្តង ហើយនៅគ្រប់ករណីទាំងអស់ការពិនិត្យឡើងវិញមួយនៅក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់សំណុំរឿង ០០២/០១ មុខជានឹងធានាឲ្យប្រាកដថា អៀង ធីរិទ្ធ មិនត្រូវបានដាក់ឲ្យស្ថិតនៅក្នុងភាពដែលមិនប្រាកដប្រជានោះឡើយ។

ចំណែកឯបញ្ហាចុងក្រោយ ដែលលោក លោកស្រីចៅក្រមបានស្នើឲ្យយើងខ្ញុំលើកឡើងនៅថ្ងៃនេះ គឺការអនុវត្តវិធាននានា ដែលបានស្នើ។ នៅត្រង់កថាខណ្ឌទី៣៧ អង្គជំនុំជម្រះសាលាដំបូងបានសួរសំណួរអំពីការអនុវត្តទៅបានតាមការអនុវត្តជាក់ស្តែង និងការចាប់បង្ខំតាមច្បាប់ឲ្យអនុវត្តនូវវិធានការទាំងនោះ។

[១០:៣៨:៣៧]

អង្គជំនុំជម្រះមានមន្ទិលសង្ស័យថា តើជនជាប់ចោទនឹងមានលទ្ធភាពអាចបង្កើតនូវចេតនាក្នុងការរំលោភបំពានលើលក្ខខណ្ឌទាំងនោះ ឬថាតើទោសបញ្ញត្តិគួរបានដាក់តម្រូវលើរូបគាត់ នៅក្នុងករណីមានការប្រព្រឹត្តដែរឬទេ។

យើងខ្ញុំសូមជូនជាសេចក្តីសន្និដ្ឋានដោយគោរពថា អង្គជំនុំជម្រះបានប្រព្រឹត្តនូវកំហុសមួយទាក់ទងទៅនឹងឆន្ទានុសិទ្ធិ ដែលបានប្រើប្រាស់ជាវិធីសាស្ត្ររបស់ខ្លួនចំពោះបញ្ហានេះ។ ទោះបីជាជនជាប់ចោទនៅទីបំផុតអាចត្រូវបានដាក់ទណ្ឌកម្ម ចំពោះការបំពាននឹងដីកាសម្រេចរបស់តុលាការនោះក៏ដោយ

ក៏វាមិនមែនជាការកំណត់ថា លក្ខណៈដែលជាការបង្គាប់របស់តុលាការមិនអាចដាក់ចេញបាននោះឡើយ។

[១០:៣៩:១៩]

គោលបំណងដំបូង និងមុនគេបំផុតនៃការចេញសេចក្តីសម្រេច គឺដើម្បីការពារដល់ផលប្រយោជន៍ទាំងឡាយដែលអង្គជំនុំជម្រះបានទទួលស្គាល់ថា ត្រូវតែមាន និងត្រូវតែការពារ។ ដីកាបង្គាប់ណាមួយរបស់តុលាការ ដែលផ្ញើជូនដល់ជនជាប់ចោទបានភ្ជាប់នូវឯកសារដ៏សំខាន់មួយអំពីអាកប្បកិរិយា ដែលជនជាប់ចោទត្រូវតែប្រព្រឹត្តតាម។

ដូចដែលខ្ញុំបានបញ្ជាក់រួចពីដើមខាងលើស្រាប់។ អង្គជំនុំជម្រះបានរកឃើញថា អៀង ធីរិទ្ធ ខ្វះនូវសមត្ថភាពខាងបញ្ញាស្មារតី។ មកដល់ត្រង់ចំណុចនេះ មិនមានហេតុផលអ្វីដែលធ្វើឲ្យជឿជាក់ថា អៀង ធីរិទ្ធ មិនអាចមានសមត្ថភាពក្នុងការគោរពការអនុវត្តដីកាសម្រេចនោះឡើយ ទោះក្នុងករណីណាក៏ដោយ ក៏នៅក្នុងរឿងនេះ អៀង ធីរិទ្ធ មុខជានឹងមានជំនួយពីអាណាព្យាបាលរបស់គាត់ ដែលបច្ចុប្បន្ននេះត្រូវបានតែងតាំងដោយមានការទទួលស្គាល់ដោយតុលាការរាជធានីភ្នំពេញ។ មានតែនៅពេលដែល អៀង ធីរិទ្ធ បានបំពានលើលក្ខខណ្ឌទាំងឡាយនៃការដោះលែងគាត់ ឲ្យគាត់មានសេរីភាពប៉ុណ្ណោះដែលតុលាការ ចាំបាច់ត្រូវធ្វើការពិចារណាអំពីផលវិបាកទាំងឡាយនៃការតម្រូវឲ្យជនជាប់ចោទរូបនេះគោរពតាម។ ប្រសិនបើបញ្ហានេះកើតឡើងមានពិតមែន វិធីដោះស្រាយមួយចំពោះការបំពាននេះ គឺមានចែងនៅក្នុងវិធាន៣៥ ដែលតម្រូវឲ្យពិនិត្យថា តើមានចេតនា និងឆន្ទៈនៅក្នុងការប្រព្រឹត្តអំពើនោះឬអត់? ការបំពានមួយនេះ ក៏អាចត្រូវបានដោះស្រាយតាមរយៈការពិនិត្យឡើងវិញ និងការពង្រឹងនូវលក្ខខណ្ឌកម្រិតនានាដែលមានចែងស្រាប់។

[១០:៤០:៥២]

នៅក្នុងកាលៈទេសៈណាក៏ដោយ ការសម្រេចមិនដាក់លក្ខខណ្ឌណាមួយនៅក្នុងពេលនេះ ដោយសំអាងលើមូលហេតុថា វាអាចជាឧបសគ្គក្នុងការដាក់ទណ្ឌកម្មចំពោះការបំពានរបស់គាត់នោះ គឺអង្គជំនុំជម្រះសាលាដំបូងមិនបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានត្រឹមត្រូវនោះទេ ចំពោះបញ្ហានេះ។

ត្រឡប់ទៅនិយាយអំពីបញ្ហាពីតួនាទីរបស់អាណាព្យាបាលទូទៅ យើងកត់សម្គាល់ឃើញថា ពាក្យសុំរបស់អាណាព្យាបាលត្រូវបានដាក់នៅថ្ងៃទី១៣ ខែសីហា ទាំងតំណាងអយ្យការនៃតុលាការរាជធានីភ្នំពេញ ទាំងលោកស្រី អៀង វិជីដា កូនស្រីរបស់ អៀង ធីរិទ្ធ។ តាមខ្លឹមសារពាក្យសុំរបស់

លោកស្រី អៀង វិជីដា បានស្នើសុំធ្វើការថែរក្សាម្តាយរបស់គាត់នៅលំនៅដ្ឋាន និងបានយល់ព្រមគោរពតាមលក្ខខណ្ឌនានាដែលបានបង្គាប់ដោយតុលាការ។ សហភាតាដែលជាមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធបានស្នើឡើងថា យើងបានស្នើសុំឲ្យជៀសវាងនៅក្នុងការប្រើប្រាស់យុត្តាធិការរបស់តុលាការនេះ ដើម្បីបន្តដាក់លក្ខខណ្ឌរឹតត្បិតតាមរយៈវិធីអាណាព្យាបាលនេះ។

[១០:៤១:៥១]

ខ្ញុំអាចដោះស្រាយបញ្ហានេះ ដោយប្រើពាក្យពេចន៍យ៉ាងសង្ខេបខ្លីដូចតទៅៈ

ទី១ ច្បាស់ណាស់ថា ការិយាល័យសហព្រះរាជអាជ្ញានៅ អ.វ.ត.ក នេះជាស្ថាប័នដាច់ដោយឡែកពីស្ថាប័នអយ្យការនៃតុលាការរាជធានីភ្នំពេញ។

ទី២ អ្នកស្រី អៀង វិជីដា ខ្លួនឯងទេ ដែលបានស្នើសុំឲ្យមានការចាត់តាំងអ្នកអាណាព្យាបាលសម្រាប់ម្តាយរបស់គាត់។ ហើយអ្នកស្រីគឺជាបុគ្គលម្នាក់ដែលបានរៀនសូត្រចេះដឹងជ្រៅជ្រះ ដែលមានសមត្ថភាពពេញលេញនៅក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនតាមច្បាប់ និងអាចទទួលបាននូវការជូនដំណឹងដ៏ត្រឹមត្រូវថែមទៀត។ អ្នកស្រី អៀង វិជីដា បានយល់ព្រមគ្រប់លក្ខខណ្ឌតម្រូវដែលបានដាក់ដោយតុលាការរាជធានីភ្នំពេញ និងទី៣ តាមការស្វែងយល់របស់ខ្ញុំ គឺមេធាវីការពារក្តី អៀង ធីរិទ្ធ ក៏បានចូលរួមនៅក្នុងការពិគ្រោះយោបល់អំពីដំណើរការនេះផងដែរ។

ដូច្នេះ វាមិនអាចទៅរួចទេដែលថា ការស្នើសុំឲ្យមានចំណាត់ការនេះដោយតំណាងអយ្យការអមតុលាការរាជធានីភ្នំពេញ គឺមេធាវីការពារក្តី អៀង ធីរិទ្ធ មិនបានដឹងអ្វីទាល់តែសោះនោះឡើយ។ និងជាចុងក្រោយសេចក្តីសម្រេចរបស់តុលាការរាជធានីភ្នំពេញ អាចជាកម្មវត្ថុក្នុងការប្តឹងជំទាស់ យើងមិនឃើញអ្នកស្រី អៀង វិជីដា ធ្វើបណ្តឹងជំទាស់ណាមួយចំពោះបញ្ហានេះរហូតមកដល់ពេលនេះនោះឡើយ។

[១០:៤៣:១០]

អាស្រ័យហេតុនេះ សូមជម្រាបតុលាការថា មិនមានការស្នើសុំឲ្យមានចេតនាមិនត្រឹមត្រូវពីការិយាល័យយើងខ្ញុំ ដើម្បីស្វះស្វែងឲ្យមានការដាក់វិធានការរឹតត្បិតដល់ស្ថាប័នតុលាការផ្សេងនោះឡើយ។ បន្ទាប់ពីបានអានពាក្យពេចន៍នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចប់ភ្លាម យើងបានធ្វើបណ្តឹងសាទុក្ខភ្លាមនៅចំពោះមុខអង្គជំនុំជម្រះនៃតុលាការកំពូល។ យើងមិនបានប្រើប្រាស់យន្តការនៃតុលាការក្នុងស្រុកឡើយ ហើយក៏មិនបានស្នើសុំឲ្យមានការពិចារណាលើបណ្តឹងសាទុក្ខរបស់

យើងដោយប្រើនីតិវិធីនៃស្ថាប័នតុលាការដទៃទៀតនោះឡើយ។

គាប់ជួនណាស់ដែលយើងកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារបានស្នើឲ្យចៅក្រមតុលាការកំពូលបដិសេធចោលនូវវិធានដែលបានបង្គាប់ឲ្យតុលាការរាជធានីភ្នំពេញ ដែលផ្នែកមួយនៃដីកាសម្រេចតែងតាំងអាណាព្យាបាល។ ពិតណាស់ ថាតើសេចក្តីសម្រេចរបៀបនេះ គឺមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការនោះទេ។ ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០០៧ លើបណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នមួយ អ.វ.ត.ក មិនមានអំណាចក្នុងការពិនិត្យមើលសេចក្តីសម្រេចរស់តុលាការកម្ពុជានោះទេ។

ប្រសិនបើ អៀង ធីរិទ្ធ ឬអាណាព្យាបាលចង់កែប្រែចំពោះលក្ខខណ្ឌកំណត់ដោយតុលាការរាជធានីភ្នំពេញ ពួកគាត់មានជម្រើសក្នុងការស្នើសុំឲ្យមានការកែប្រែលក្ខខណ្ឌអាណាព្យាបាលនោះតាមរយៈការធ្វើបណ្តឹងជំទាស់។

[១០:៤៤:៣៧]

នៅក្នុងដីកាសម្រេចរបស់តុលាការរាជធានីភ្នំពេញ ក៏បានប្រាប់ពួកគាត់អំពីសិទ្ធិក្នុងការធ្វើបណ្តឹងជំទាស់នោះ យោងមាត្រា៣៩ ដល់៤២ នៃច្បាប់ស្តីអំពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ហើយពួកគេ ក៏មានសិទ្ធិនៅក្នុងការដាក់ពាក្យបណ្តឹងឧបាស្រ័យទៅតុលាការសាលាឧទ្ធរណ៍ផងដែរ ដើម្បីប្រឆាំងនឹងសេចក្តីសម្រេចរបស់តុលាការសាលាដំបូង ក្នុងអំឡុងពេល ២សប្តាហ៍ដោយគិតចាប់ពីថ្ងៃទទួលការជូនដំណឹងអំពីសេចក្តីសម្រេច។

នៅត្រង់កថាខណ្ឌ៧៩ នៃបណ្តឹងឧទ្ធរណ៍របស់គេ ក្រុមមេធាវីការពារ អៀង ធីរិទ្ធ ក៏បានលើកឡើងថា ការប្រមើល៍មើលអំពីការដាក់ទណ្ឌកម្មលើអាណាព្យាបាលចំពោះការឆ្លើយតបមិនគ្រប់គ្រាន់លើលក្ខខណ្ឌដែលគេបង្គាប់ឲ្យបំពេញ គឺពុំមានមូលដ្ឋានច្បាប់នោះទេ។

[១០:៤៥:២៤]

យើងយល់ថា ការព្យាករខាងលើ គឺវាជ្រុលហួសហេតុពេក។ អាណាព្យាបាលមានកាតព្វកិច្ចជួយដល់ជនជាប់ចោទឲ្យអនុវត្តតាមផ្លូវច្បាប់ និងកាតព្វកិច្ចរបស់ខ្លួន។ ប្រសិនបើមិនគោរពកាតព្វកិច្ចនោះ ពិតណាស់មិនមានទណ្ឌកម្មណាមួយលើអាណាព្យាបាល សម្រាប់ការខកខានរបស់ អៀង ធីរិទ្ធ មិនបានគោរពតាមការបង្គាប់បញ្ជារបស់តុលាការនោះទេ។ គោលបំណងនៃការចាត់តាំងអាណាព្យាបាល គឺដើម្បីជួយជនជាប់ចោទនៅក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន គឺមិនមែនជាការបង្កើតនូវ

ជម្រើសណាមួយផ្សេង ដើម្បីអនុវត្តទណ្ឌកម្មនោះឡើយ។

ចុងបញ្ចប់ការស្នើរបស់យើងខ្ញុំមានការចាត់តាំងអាណាព្យាបាល និងជួយសម្រួលដល់ការអនុវត្តនូវរាល់វិធានការដែលបានស្នើឡើង។ អាណាព្យាបាលមិនត្រឹមតែជួយ អៀង ធីរិទ្ធ ក្នុងការបន្ថយនូវសិទ្ធិ និងកាតព្វកិច្ចទូទៅនោះទេ ប៉ុន្តែថែមទាំងជួយ អៀង ធីរិទ្ធ នៅក្នុងការអនុវត្តវិធានរឹតត្បិតណាមួយដែលបង្គាប់ដោយតុលាការថែមទៀត។ ហើយវាក៏អាចជួយធានាឲ្យបានថា ការណែនាំទាំងឡាយអាចត្រូវបានផ្តល់ជូនមេធាវីការពារក្តី អៀង ធីរិទ្ធ នៅពេលដែល អៀង ធីរិទ្ធ ខ្លួនឯងមិនចេះធ្វើដូច្នេះ។

[១០:៤៦:៣៤]

យើងកត់សម្គាល់ឃើញថា ដីកាកោះហៅ អៀង ធីរិទ្ធ មកចូលសវនាការនៅពេលនេះក៏ត្រូវបានចុះហត្ថលេខាដោយ អៀង វិជីដា ដែលជាអាណាព្យាបាលរបស់គាត់។ ហើយនៅថ្ងៃនេះពេលនេះ យើងឃើញថា អៀង ធីរិទ្ធ បានគោរពតាមដីកាកោះហៅរបស់តុលាការ ហើយអ្នកស្រី អៀង វិជីដា ក៏បានចូលរួមនៅក្នុងសវនាការ ដើម្បីជាជំនួយដល់តុលាការផងដែរ។ នេះប្រហែលជាការបង្ហាញឲ្យឃើញយ៉ាងល្អបំផុតនូវវិធីដែលអាណាព្យាបាលអាចដំណើរការ ប្រកបដោយប្រសិទ្ធភាពបំផុតនៅក្នុងការជួយសម្រួលដល់ការអនុវត្តនូវវិធានទាំងឡាយដែលបានស្នើឡើង។

ជាសេចក្តីសន្និដ្ឋាន ផ្អែកតាមភស្តុតាងដែលមាននៅពេលនេះ យើងទទួលស្គាល់ថា លទ្ធភាពនៃការដំណើរការឡើងវិញនូវសវនាការប្រឆាំងនឹង អៀង ធីរិទ្ធ គឺមានតិចតួចបំផុត។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ លទ្ធភាពខាងលើនេះមិនអាចត្រូវបានបដិសេធចោលនោះឡើយ ដរាបណាស្ថានភាពនីតិវិធីរបស់តុលាការមានការប្រែប្រួល តុលាការមានយុត្តាធិការក្នុងការចេញការបង្គាប់តាមការចាំបាច់ ដើម្បីការពារនូវសុចរិតនៃនីតិវិធីរបស់ខ្លួន។ ការបង្គាប់នោះរួមបញ្ចូលទាំងវិធានការទាំងឡាយ ដើម្បីរឹតត្បិតសិទ្ធិសេរីភាពរបស់ជនជាប់ចោទតាមរបៀបមួយសមហេតុផល និងអាចទទួលយកបាន។

[១០:៤៧:៥១]

ក្នុងករណីរឿងក្តីកម្រិតនេះ នៅពេលដែលជនជាប់ចោទទទួលរងនូវការចោទប្រកាន់ នូវបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុតមួយចំនួនកម្រិតមនុស្សជាតិ ដែលយើង -- ដែលធ្វើឲ្យប៉ះពាល់ដល់មនុស្សរាប់លាននាក់។ វាជាប្រយោជន៍សាធារណៈ ក្នុងការដែលតុលាការរក្សាការគ្រប់គ្រងរបស់ជនជាប់ចោទរហូតទាល់តែមានភាពច្បាស់លាស់បំផុត ឬមានភាពប្រាកដប្រជាយ៉ាងច្បាស់បំផុតថា នឹងមិនមានសវនាការប្រឆាំងនឹងជនជាប់ចោទត្រូវបានធ្វើឡើងវិញ។ វាជាការសមស្របផងដែរ ក្នុងការរក្សាគ្រប់

គ្រងរបស់ -- គ្រប់គ្រងរបស់តុលាការដើម្បីផ្តល់នូវភាពប្រាកដប្រជាសម្រាប់ជនជាប់ចោទ។

យើងខ្ញុំយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវកំហុស ដោយសន្និដ្ឋានថា ខ្លួនមិនមានយុត្តាធិការ ឬមិនអាចដាក់វិធានរឹតត្បិត និងខកខានមិនបានថ្លឹងថ្លែងនូវសិទ្ធិរបស់ អៀង ធីរិទ្ធ ជាមួយនឹងសិទ្ធិផលប្រយោជន៍ផ្សេងទៀត ដែលទទួលរងពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ។

[១០:៤៨:៥៣]

យើងខ្ញុំយល់ឃើញថា លក្ខខណ្ឌដែលមានកម្រិតនានា ដែលយើងស្នើឡើង នឹងជួយការពារយ៉ាងមានប្រសិទ្ធភាពបំផុតនូវសិទ្ធិ និងផលប្រយោជន៍របស់ជនរងគ្រោះ និងសុចរិតភាពនៃនីតិវិធី បើទោះជាមានការរឹតត្បិតសិទ្ធិសេរីភាពរបស់ អៀង ធីរិទ្ធ បន្តិចបន្តួចក៏ដោយ។

អស់លោក លោកស្រីចៅក្រមជាទីគោរព! អង្គសវនាការជាគោរព! យើងសូមស្នើទៅអង្គជំនុំជម្រះតុលាការកំពូលធ្វើការកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយស្នើឲ្យមានការដាក់លក្ខខណ្ឌនានា ដែលស្នើឡើងដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃ៣១ ខែសីហា ឆ្នាំ២០១២។

សូមបញ្ចប់សេចក្តីសន្និដ្ឋានផ្ទាល់មាត់។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអន្តរជាតិអត់មានបន្ថែមទេ ឬក៏យ៉ាងណាបាទ?

[១០:៥០:០០]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំមិនមានទេលោកប្រធាន គឺខ្ញុំបានរួមបញ្ចូលសេចក្តីសន្និដ្ឋានរបស់ខ្ញុំរួមគ្នារួចមកហើយ ដូច្នេះហើយយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងច្រើនដល់លោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្ត សូមអញ្ជើញសហមេធាវីការពារក្តីជនជាប់ធ្វើសេចក្តីសន្និដ្ឋាន អំពីសារណាតបរបស់ខ្លួន។ សូមអញ្ជើញ!

**លោក ផាត់ ពៅស៊ាង៖**

ជាបឋម ខ្ញុំបាទសូមគោរពអង្គជំនុំជម្រះតុលាការកំពូល សូមគោរពអង្គសវនាការទាំងមូល! ក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់មេធាវីការពារក្តីឲ្យជនជាប់ចោទនេះ គឺខ្ញុំបាទសូមចែកចេញជាពីរផ្នែក។

គឺផ្នែកទី១ ធ្វើឡើងដោយខ្ញុំបាទជាមេធាវីជាតិ និងផ្នែកទី២ ធ្វើឡើងដោយមេធាវីសហមេធាវីអន្តរជាតិ។ គឺខ្ញុំបាទសូមអនុញ្ញាតធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ឆ្លើយតបទៅនឹងហៅថា “សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា” ដូចតទៅៈ

[១០:៥១:២៣]

មេធាវីចុងបណ្តឹងសាទុក្ខសូមលោក លោកស្រីចៅក្រមមេត្តាបដិសេធចោលនូវបណ្តឹងសាទុក្ខភ្លាមៗរបស់ម្ចាស់បណ្តឹងសាទុក្ខ និងសេចក្តីសម្រេចរបស់អង្គជំនុំ -- លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការវាយតម្លៃឡើងវិញអំពីសម្បទារបស់អ្នកស្រី អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ។ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ និងសូមបដិសេធទាំងស្រុងនូវសារណាបន្ថែមរបស់សហព្រះរាជអាជ្ញា ព្រមទាំងសូមតម្កល់នូវសេចក្តីស្នើ -- នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ បន្ថែមៗពីនេះទៀតគឺចុងបណ្តឹងសាទុក្ខស្នើសុំអង្គជំនុំជម្រះសាលាដំបូងដកចេញនូវលក្ខខណ្ឌបង្គាប់នានា ដែលភ្ជាប់ជាមួយនឹងការដោះលែងចុងបណ្តឹងសាទុក្ខខណៈគាត់រង់ចាំសវនាការលើបណ្តឹងសាទុក្ខ។

មេធាវីចុងបណ្តឹងសាទុក្ខយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសនៃអង្គច្បាប់ និងកំហុសអង្គហេតុដែលនាំឲ្យសេចក្តីសម្រេចនោះមិនមានយុត្តិធម៌ ឬការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់បណ្តឹង -- ម្ចាស់បណ្តឹងសាទុក្ខឡើយ។

[១០:៥៣:២២]

ពោលគឺអង្គជំនុំជម្រះសាលាដំបូងបានសម្រេចត្រឹមត្រូវហើយ ក្នុងការបង្គាប់ឲ្យដោះលែងចុងបណ្តឹងសាទុក្ខដោយគ្មានលក្ខខណ្ឌ។ នាពេលនេះ ខ្ញុំបាទមិនចាំបាច់លើកអំណះអំណាងលម្អិតឡើងវិញដែលមានចែងនៅក្នុងសារណាឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗ និងសារណាបន្ថែមរបស់សហព្រះរាជអាជ្ញាដែលដាក់នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ នោះទេ។ គោលការណ៍ និងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធទៅនឹងសេរីភាពរបស់ជនជាប់ចោទ មានចែងយ៉ាងពេញលេញនៅក្នុងសារណាឆ្លើយតបរបស់យើងខ្ញុំ។

យើងខ្ញុំយល់ឃើញថា បើទោះបីជាមានការត្រួតពិនិត្យតាមផ្លូវតុលាការ មិនសូវធ្ងន់ធ្ងរជាងការឃុំខ្លួន រង់ចាំការជំនុំជម្រះក៏ដោយក៏ វារឹតត្បិត ដោយមិនចាំបាច់លើសិទ្ធិទទួលបានសេរីភាពរបស់បុគ្គលដែរ។ ហេតុដូច្នេះការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវអនុវត្តតែក្នុងករណីណាដែលមានមូលដ្ឋានច្បាប់

ត្រឹមត្រូវតែប៉ុណ្ណោះ។

ម៉្យាងទៀត ខ្ញុំស្នើសុំឱ្យពិចារណា អង្គជំនុំជម្រះនៅ អ.វ.ត.ក ត្រូវតែអនុវត្តទៅតាមគោលការណ៍នានាដែលត្រូវបានគេទទួលស្គាល់ ហើយដែលត្រូវបានគេបង្កើតឡើងដើម្បីធានាថា “សិទ្ធិរបស់ចុងបណ្តឹងសាទុក្ខក្នុងការទទួលបានសេរីភាព មិនត្រូវបានដកហូត ឬដាក់កំហិត ដោយមិនមានមូល-ហេតុត្រឹមត្រូវតាមច្បាប់ឡើយ។

បទប្បញ្ញត្តិដែលពាក់ព័ន្ធនៅក្នុងករណីនេះ គឺវិធាន៦៣, ៦៥ និងវិធាន៨២ នៃវិធានផ្ទៃក្នុង និងមាត្រា២២៣ និងមាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចុងបណ្តឹងសាទុក្ខមិនមានសម្បទាជាអចិន្ត្រៃយ៍ក្នុងការចូលរួមសវនាការ។ ចុងបណ្តឹងសាទុក្ខទទួលរងនូវការវង្វេងស្មារតីធ្ងន់ធ្ងរ ដែលអាចបង្កឡើងដោយជំងឺ អាល់ហ្សៃមើ ដែលត្រូវបានរកឃើញនៅឆ្នាំ២០១១ ប៉ុន្តែវាបានវិវត្តន៍អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ អ្នកជំនាញវេជ្ជសាស្ត្រជាច្រើនរូបដែលត្រូវបានចាត់តាំងដោយតុលាការ បានសម្រេចជាឯកច្ឆន្ទថា លក្ខខណ្ឌរបស់ចុងបណ្តឹងសាទុក្ខមិនមានការប្រសើរសោះ ចាប់តាំងពីអស់លោក លោកស្រីចៅក្រម បង្គាប់ឱ្យគេព្យាបាលគាត់បន្ថែមទៀត តែផ្ទុយទៅវិញ គេបានរកឃើញស្ថានភាពរបស់គាត់កាន់តែអាក្រក់ឡើងៗ។

[១០:៥៦:១៥]

តាមពិតស្ថានភាពរបស់ចុងបណ្តឹងសាទុក្ខ គឺមុខងារនៃការចងចាំរបស់គាត់កាន់តែយាប់យឺនឡើងៗ ទៅតាមពេលវេលា។ គាត់មិនអាចចូលរួមសវនាការ ហើយគាត់ក៏មិនមាន -- នឹងមិនមានសម្បទា ក្នុងការចូលរួមសវនាការបានទេ។ ពុំមានមូលដ្ឋានភស្តុតាងដែលសំអាងថា ចុងបណ្តឹងសាទុក្ខមិនមានសម្បទាក្នុងការចូលរួមសវនាការនោះទេ។ នៅក្នុងការទទួលស្គាល់អង្គហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បានផ្អាកដំណើរការនីតិវិធីដោយគ្មានកំណត់ និងគាំទ្រសេចក្តីសម្រេចឆ្នាំ២០១១ ដើម្បីបំបែកការចោទប្រកាន់ប្រឆាំងនឹងចុងបណ្តឹងសាទុក្ខ ពីករណី ០០២/១។

ម្ចាស់បណ្តឹងសាទុក្ខទទួលស្គាល់ថា ចុងបណ្តឹងសាទុក្ខមិនមានសម្បទាក្នុងការចូលរួមសវនាការនៅពេលសហព្រះរាជអាជ្ញាលើកឡើងថា សេចក្តីសម្រេចដែលរងការជំទាស់នេះ បានបំពេញបទប្បញ្ញត្តិនៃវិធាន១០៤(៤)(ក) ដោយសារសេចក្តីសម្រេចនេះ មានអានុភាពបញ្ចប់នីតិវិធី។ សហព្រះរាជអាជ្ញាបានលើកឡើងយ៉ាងច្បាស់នៅក្នុងអំណះអំណាងខែសីហា ឆ្នាំ២០១២ ថា ចុងបណ្តឹងសាទុក្ខមិនទំនងជាអាចប្រឈមនឹងការជំនុំជម្រះក្នុងពេលវេលាកំណត់ខាងមុខបានទេ។

[១០:៥៧:៥១]

ចុងបណ្តឹងសាទុក្ខគាំទ្រការអះអាងនេះ ដោយសារមានការបញ្ចប់នីតិវិធី បើទោះបីជាពុំមានយន្តការច្បាប់ផ្លូវការសម្រាប់ការបញ្ចប់នីតិវិធី ក្នុងករណីមិនមានសម្បទាក្នុងការចូលរួមសវនាការ នៅក្នុងយុត្តាធិការនេះ មិនដូចយុត្តាធិការជាច្រើននៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូឡើយ។ ប្រសិនបើមានវិធានការដែលនាំឲ្យមានការរឹតត្បិតសេរីភាពរបស់ចុងបណ្តឹងសាទុក្ខ គឺមិនមានមូលដ្ឋានផ្នែកច្បាប់ និងករណីយុត្តិសាស្ត្រឡើយ។

អនុលោមតាមបទប្បញ្ញត្តិនៃវិធាន៦៥(១) នៃវិធានផ្ទៃក្នុង លក្ខខណ្ឌអាចត្រូវបានដាក់ បន្ទាប់ពីការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ខណៈដែលលក្ខខណ្ឌបែបនេះ គឺចាំបាច់ដើម្បីធានាវត្តមានរបស់ជនជាប់ចោទ ក្នុងកិច្ចដំណើរការនីតិវិធី និងដើម្បីការពារអ្នកដទៃទៀត។ ដូច្នេះវាមិនមែនមានន័យថា ចាំបាច់ត្រូវតែដាក់លក្ខខណ្ឌដោយខានមិនបានឡើយ។

វិធានការនានាដែលបានធ្វើឡើងក្នុងដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធី ត្រូវតែជាវិធានដែលមានផលប៉ះពាល់តិចតួចបំផុតដល់ជនត្រូវចោទ។ គោលការណ៍នេះគឺពាក់ព័ន្ធទៅនឹងគោល-ការណ៍នៃការសន្មតទុកជាមុនថា គ្មានទោស។

ដូច្នេះ តុលាការ គួរតែគាំទ្រដល់ការដោះលែងដែលសមហេតុផល និងឲ្យបានឆាប់បំផុត អមដោយលក្ខខណ្ឌ ដែលមានផលប៉ះពាល់តិចតួចបំផុត ដែលចាំបាច់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៦៣ នៃវិធានផ្ទៃក្នុង។

[១០:៥៩:៤៧]

បើពិចារណាទៅលើកាលៈទេសៈពាក់ព័ន្ធនានា លក្ខខណ្ឌតម្រូវនៃភាពចាំបាច់នេះ មិនអាចត្រូវបានចាត់ទុកថា បានបំពេញក្នុងករណីបច្ចុប្បន្ននេះឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវ គឺវាគ្មានមូលដ្ឋានផ្លូវច្បាប់ណាដែលបន្តការឃុំខ្លួនចុងបណ្តឹងសាទុក្ខឡើយ។ ដោយផ្អែកលើការរកឃើញរបស់អ្នកជំនាញដែលថា ចុងបណ្តឹងសាទុក្ខនឹងមិនមានកាយសម្បទា និងសតិបញ្ញាស្មារតីគ្រប់គ្រាន់អាចចូលរួមសវនាការបានក្នុងពេលអនាគតដែលគេអាចកំណត់ទុកជាមុនបាននោះទេ។

ដូចគ្នានេះដែរ វាគ្មានមូលដ្ឋានផ្លូវច្បាប់ណាមួយដើម្បីដាក់លក្ខខណ្ឌដែលមានការបង្ខិតបង្ខំ ឬក៏ទម្រង់ណាមួយនៃការត្រួតពិនិត្យតាមផ្លូវតុលាការ លើការដោះលែងចុងបណ្តឹងសាទុក្ខនោះឡើយ។ ដោយសារតែគ្មានការរំពឹងថា នឹងមានការជំនុំជម្រះក្តីណាមួយដែលនឹងត្រូវធ្វើឡើងនាពេលខាងមុខនោះ

ការដាក់លក្ខខណ្ឌទាំងប្រាំមួយនេះ នឹងក្លាយទៅជាការរឹតត្បិតលើសិទ្ធិទទួលបានសេរីភាពឡើងវិញរបស់ចុងបណ្ដឹងសាទុក្ខដែលច្បាប់មិនបានកំណត់។

[១១:០១:១៣]

វិធាន៦៥ នៃវិធានផ្ទៃក្នុងបានផ្ដល់នូវមូលហេតុពីរក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ១. ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងដំណើរការនីតិវិធី និងដើម្បីការពារអ្នកដទៃទៀត។

មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌក៏បានសន្មតជាមុនផងដែរថា វានឹងអាចមានលទ្ធភាពដ៏សមហេតុផលមួយនៃការជំនុំជម្រះក្ដីនាពេលខាងមុខ។ ក្នុងរឿងក្ដីតាលិក អង្គជំនុំជម្រះបានលើកឡើងថា ក្នុងការសម្រេចរឿងក្ដីជាលក្ខណៈបុគ្គលទាំងនេះ ស្នើសុំឲ្យមានការដោះលែងបណ្ដោះអាសន្ន គេចាំបាច់ត្រូវចាំទុកអំពីមូលហេតុនៃការស្នើសុំឲ្យមានការដោះលែងជាបណ្ដោះអាសន្ន ដែលមានទំនងជាមួយនឹងមូលហេតុនៃការស្នើសុំឲ្យមានការឃុំខ្លួនក្នុងពន្ធនាគារ។

[១១:០២:២១]

អាស្រ័យហេតុនេះការដាក់លក្ខខណ្ឌទាំងនេះ គឺជាការសន្មតទុកជាមុនថា នឹងមានការជំនុំជម្រះក្ដី និងមានហានិភ័យពិតប្រាកដមួយដែលថា ជនជាប់ចោទនឹងខកខានមិនបានចូលរួមសវនាការ និង/ឬថា អ្នកដទៃទៀត ត្រូវការការពារ។ បើពិនិត្យមើលស្ថានភាពជាក់ស្ដែងនៃការបញ្ចប់កិច្ចដំណើរការនីតិវិធី លក្ខខណ្ឌតម្រូវទាំងពីរខាងលើនេះមិនត្រូវបានបំពេញឡើយ។

ការយល់ឃើញរបស់ដើមបណ្ដឹងសាទុក្ខដែលថា ការដាក់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការលើចុងបណ្ដឹងសាទុក្ខគឺចាំបាច់ដើម្បីធានាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងដើម្បីបម្រើគោលបំណងសាធារណៈគួរតែត្រូវបានបដិសេធចោល ដោយសារគ្មានមូលដ្ឋានច្បាប់។ វាជាការរំលោភសិទ្ធិរបស់ចុងបណ្ដឹងសាទុក្ខក្នុងការទទួលបាននូវការជំនុំជម្រះមួយ ក្នុងពេលវេលាសមស្របនៅពេលដែលចុងបណ្ដឹងសាទុក្ខ ត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយគ្មានពេលវេលាកំណត់។ នៅពេលដែលរឿងក្ដីគ្មានដំណើរការ និងនៅពេលដែលគ្មានរំពឹងទុកថា នឹងមានការជំនុំជម្រះនាពេលខាងមុខនោះ។

តទៅនេះខ្ញុំសូមជូននាទីទៅឲ្យសហភាតាអន្តរជាតិខ្ញុំ ដើម្បីលើកឡើងឲ្យបានច្បាស់លាស់ជាងនេះអំពីលក្ខខណ្ឌចាំបាច់ទាំងប្រាំមួយ ដែលដាក់ដោយដើមបណ្ដឹងសាទុក្ខ។ សូមអរគុណ។

[១១:០៤:២២]

**លោកស្រី ដាយអាណា អេលីស៖**

សូមគោរពលោក លោកស្រីចៅក្រម! ជាដំបូងខ្ញុំសូមធ្វើការកែតម្រូវចំណុចមួយដែលបានដាក់ដោយម្ចាស់បណ្តឹងសាទុក្ខ គឺជាសារណារបស់យើងដែលថា មិនមានលក្ខខណ្ឌណាមួយត្រូវបានដាក់ទៅលើចុងបណ្តឹងសាទុក្ខ ហើយលក្ខខណ្ឌទាំងអស់នេះដែលត្រូវដាក់ដោយតុលាការ អ.វ.ត.ក នៅពេលដែលគាត់ត្រូវបានដោះលែងហ្នឹងក៏គួរតែត្រូវបានលើកលែងចេញផងដែរ។ នៅក្នុងការឆ្លើយតបរបស់យើង យើងមិនចង់ ឬក៏យើងមិនបានស្នើសុំដល់តុលាការថាមានយុត្តិសាស្ត្រក្នុងការជ្រៀតជ្រែកទៅលើសេចក្តីសម្រេច ដែលធ្វើឡើងដោយតុលាការរាជធានីភ្នំពេញនោះឡើយ។ ហើយយើងក៏មិនបានលើកយកនូវទឡ្ហីករណ៍បែបនេះដាក់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលផងដែរ។

ខ្ញុំសូមឆ្លើយតបជាក់លាក់ទៅលើសំណើរបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលបានចែងនៅក្នុងបណ្តឹងសាទុក្ខបន្ទាន់បង្ខំចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ នៅត្រង់កថាខណ្ឌទី២ ដែលក្នុងនោះរួមមានបណ្តឹង -- ចុងបណ្តឹងសាទុក្ខត្រូវស្នាក់នៅក្នុងអាសយដ្ឋានជាក់លាក់មួយ ដែលសហមេធាវីការពារក្តីរបស់គាត់ត្រូវប្រាប់ពីអាសយដ្ឋាន ដើម្បីធានាទៅដល់សិទ្ធិ ក៏ដូចជាដើម្បីការពារនៅពេលដែលគាត់ត្រូវបានគេដោះលែង។ ក្នុងទាំងអស់នេះ គឺពាក់ព័ន្ធទៅលើចំណុចចំនួនបីដាច់ពីគ្នា គឺលក្ខខណ្ឌដែលត្រូវបានដាក់ ព្រមទាំងសំអាងហេតុ ដែលត្រូវធ្វើយុត្តិកម្មចំពោះការដាក់លក្ខខណ្ឌទាំងអស់នេះ ព្រមទាំងវិធីសាស្ត្រដែលត្រូវបានស្នើឡើងដោយម្ចាស់បណ្តឹងសាទុក្ខ ដើម្បីឲ្យចុងបណ្តឹងសាទុក្ខឆ្លើយតបទៅតាម ឬក៏គោរពទៅតាមលក្ខខណ្ឌទាំងអស់នេះ ព្រមទាំងវិធីសាស្ត្រនៅក្នុងអនុវត្ត ក៏ដូចជាការបង្ខំឲ្យមានការអនុវត្តនូវវិធានការកម្រិតទាំងអស់នេះ។

[១១:០៦:៥៣]

មុនពេលដែលខ្ញុំនិយាយអំពីបញ្ហាទាំងបីចំណុចទាំងអស់នេះ ខ្ញុំសូមលើកឡើងថា វាជាការសំខាន់ដែលអង្គជំនុំជម្រះគួរចងចាំផងដែរថា ហេតុអ្វីបានជាយើងមកទីនេះ? យើងមកទីនេះ ពីព្រោះថាយើងក្នុងនាមជាចុងបណ្តឹងសាទុក្ខ គឺចុងបណ្តឹងសាទុក្ខ គាត់មានវ័យ៨០ឆ្នាំ ហើយគាត់មិនមាន -- គាត់អសមត្ថភាពផ្នែកសម្បទា។ ដូច្នេះ គាត់មិនអាចប្រឈម មិនអាចផ្តោតទៅលើចំណុចទាំងអស់នេះបានឡើយ។

ដូច្នេះហើយ ដោយផ្អែកទៅលើទស្សនៈរបស់អ្នកជំនាញជាឯកច្ឆន្ទ ទាំងអ្នកជំនាញជាតិ និងអន្តរ-

ជាតិបានលើកឡើងនៅគ្រប់ករណីទាំងអស់ដែលថា ចុងបណ្ដឹងបានទទួលរងនូវជំងឺដាយ ឌីមែនស្យា គឺ ជំងឺវង្វេងវង្វាន់ស្មារតី។

លោក លោកស្រីចៅក្រមប្រាកដជាបានពិនិត្យមើលទៅលើរបាយការណ៍ទាំងអស់នេះ ដែលរបាយការណ៍នេះបានធ្វើតាំងពីពេលមុន រហូតមកដល់ឥឡូវនេះ ដែលរបាយការណ៍នេះបានរៀបរាប់អំពីស្ថានភាពរបស់ចុងបណ្ដឹង ដែលរបាយការណ៍នេះមិនត្រឹមតែពឹងផ្អែកទៅលើការវាយតម្លៃរបស់វេជ្ជបណ្ឌិតប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងពឹងផ្អែកទៅលើការធ្វើតេស្ដប្រកបដោយបទដ្ឋានទៀតផង។

[១១:០៨:៣៦]

លក្ខខណ្ឌដែលបានចេញនៅក្នុងរបាយការណ៍ គឺថាស្ថានភាពរបស់ចុងបណ្ដឹងគឺមិនអាចព្យាបាលមិនអាចត្រឡប់ក្រោយវិញបាន និងមិនអាចធ្វើឲ្យប្រសើរឡើងវិញបានឡើយ។ នេះគឺជាស្ថានភាពពិតប្រាកដ មិនមែនជាស្ថានភាពដែលជាការបន្លំ ឬក៏ភូតភរនោះឡើយ។ ដូច្នេះ ខ្ញុំគិតថាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះកាលពីខែ -- ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ដែលតម្រូវឲ្យមានការធ្វើការព្យាបាលបែបសតិបញ្ញា និងផ្នែកសម្បទាទាំងអស់នោះ គឺបានជួយលុបបំបាត់នូវលក្ខខណ្ឌដែលអាចនឹងធ្វើឲ្យប្រសើរឡើង ប៉ុន្ដែមិនបានជួយអ្វីនោះឡើយ។ ដូចដែលវេជ្ជបណ្ឌិតបានបញ្ជាក់នៅក្នុងរបាយការណ៍ខែតុលាឆ្នាំនេះ បានបញ្ជាក់ថា ស្ថានភាពរបស់គាត់គឺបានថមថយនៅក្នុងស្ថានភាពទាំងអស់នេះ។ ហើយរបាយ-ការណ៍បានបញ្ជាក់ថា ទាំងការចងចាំរយៈពេលខ្លី និងការចងចាំរយៈពេលវែង គឺមិនអាចស្ដារឡើងវិញឡើយ។

ដូច្នេះហើយ ដើមបណ្ដឹងសាទុក្ខមិនមាន -- មិនបានលើកឡើងដោយខុសដែលថា ចុងបណ្ដឹងអាចធ្វើការប្រាស្រ័យទាក់ទងដោយសមត្ថភាពជាមួយនឹងអ្នកណាម្នាក់។ ប៉ុន្ដែភស្ដុតាងបានបញ្ជាក់ផ្សេងពីនេះដែលថា គាត់មិនទាំងស្គាល់អ្នកជិតខាង ឬក៏សាច់ញាតិជិតស្និទ្ធរបស់គាត់ថែមទៀតផង។ គាត់មិនអាចបង្កាប់បញ្ជាទៅលើខ្លួនឯង ហើយមិនអាចផ្ដោត និងមិនអាចឆ្លើយតបទៅនឹងសំណួរនានាបានឡើយ។ នេះ គឺជាការពិតជាក់ស្ដែង។

[១១:១០:៣៨]

មិនមានយន្ដការណាមួយនៅក្នុងយុត្តិសាស្ត្ររបស់តុលាការ អ.វ.ត.ក ក្នុងការទទួលស្គាល់នៅពេលដែលបុគ្គលណាមួយត្រូវបានរកឃើញថា មិនមានសម្បទាក្នុងការចូលរួមសវនាការ ហើយអនុញ្ញាតឲ្យកិច្ចដំណើរការនីតិវិធីត្រូវបានបញ្ចប់នោះឡើយ។ ទាំងអស់នេះ គឺបានបញ្ជាក់នៅក្នុងលក្ខខណ្ឌនានា

ដែលបានអនុញ្ញាតឲ្យមានស្ថានភាពបែបនេះ។ មិនមានការនិយាយយោងអំពីអសមត្ថភាពផ្នែកសតិបញ្ញានោះឡើយ។ ហេតុដូច្នេះ យើងសូមស្នើដោយផ្អែកលើហេតុផលទាំងអស់នេះថា អង្គជំនុំជម្រះសាលាដំបូង គឺមានគោលជំហរ បានពឹងផ្អែកគោលជំហរទៅលើយន្តការមួយដែលអាចបន្តនូវកិច្ចដំណើរការនីតិវិធីដោយមិនមានពេលកំណត់ -- ដោយផ្អាកកិច្ចដំណើរការនីតិវិធីមិនមានពេលកំណត់។

ហេតុដូច្នេះ ហើយ សម្រាប់តុលាការមួយនេះ ឬក៏សម្រាប់តុលាការនានា សូមយើងធ្វើការពិចារណា ថាតើវាមានលទ្ធភាពក្នុងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសតិបញ្ញារបស់ចុងបណ្ដឹង ដើម្បីឲ្យចុងបណ្ដឹងអាចមានលទ្ធភាពមកប្រឈមនៅក្នុងកិច្ចដំណើរការនីតិវិធីដែរឬអត់?

[១១:១២:០៥]

យើងមានភស្តុតាងនៅក្នុងតុលាការសាលាដំបូងដែលថា មិនមានមធ្យោបាយណាមួយដែលអាចព្យាបាលនោះឡើយ។ ដូច្នេះហើយវាធ្វើឲ្យស្ថានភាពនោះវាកាន់តែធ្លាក់ចុះ។ ហើយតាមការបង្ហាញគឺថាក្រុមហ៊ុនដែលផលិតឱសថដើម្បីព្យាបាលជំងឺវង្វេងវង្វាន់ស្មារតី បានបញ្ឈប់នូវការផ្ដល់មូលនិធិដល់ការផលិតឱសថ ព្រោះថា ឱសថនោះមិនមានលទ្ធភាព -- មិនមានលទ្ធភាពតិចតួចបំផុតនៅក្នុងការព្យាបាលជំងឺវង្វេងវង្វាន់ស្មារតី។

ដូច្នេះហើយ ផ្អែកទៅតាមការពិនិត្យមើលទៅលើចុងបណ្ដឹងដែលមានអាយុ៨០ឆ្នាំ ហើយនិងការដែលលើកឡើងដោយធ្វើការពិចារណាថា ជន ចុងបណ្ដឹងអាចនឹងមានលទ្ធភាពដឹង មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួម នៅក្នុងការកិច្ចដំណើរការនីតិវិធី គឺជាការមិនពិតទាល់តែសោះ។ ប្រសិនបើយើងពិនិត្យមើលទៅលើស្ថានភាព ដែលនិយាយអំពីលក្ខខណ្ឌកម្រិតដែលមានចេតនាដាក់ចុង បណ្ដឹងឲ្យស្ថិតក្រោមការគ្រប់គ្រង ការត្រួតពិនិត្យតាមផ្លូវតុលាការនោះ គឺយើងសូមលើកឡើងថា ដើមបណ្ដឹងដឹងច្បាស់ថា នឹងមិនមានការជំនុំជម្រះនោះឡើយ ពីព្រោះផ្អែកទៅលើយុត្តិកម្មនៃការបណ្ដឹងសាទុក្ខគឺផ្អែកទៅលទ្ធផលរបស់អង្គជំនុំជម្រះសាលាដំបូង គឺខាងម្ចាស់បណ្ដឹងសាទុក្ខមិនបានជំទាស់ទៅបញ្ហាទាំងអស់នេះឡើយ។ ដូច្នេះហើយវាអាចនឹងមានលទ្ធភាពនៃការបញ្ចប់កិច្ចដំណើរនីតិវិធី។

[១១:១៤:០៥]

នេះគឺជាគោលជំហរប្រកបដោយប្រសិទ្ធភាពមួយ ដែលយើងសូមលើកឡើងថា ប្រសិនបើយើងបន្តដោយពិនិត្យមើលទៅលើស្ថានភាពពិតប្រាកដដែលគេបានស្នើសុំ លក្ខខណ្ឌដែលបានពណ៌នាថាជាការកម្រិត កំណត់ និងការបង្ខំ លក្ខខណ្ឌបង្ខំ និងកម្រិតកំណត់ ដូចដែលបានបញ្ជាក់រួចទៅហើយ ដែល

មាននៅក្នុងកថាខណ្ឌទី១០ នៃបណ្តឹងសាទុក្ខបន្ទាន់បង្ខំចុះថ្ងៃទី១៤ ខែ៩ ឆ្នាំ២០១២ គឺបង្ហាញអំពីលក្ខខណ្ឌដែលត្រូវដាក់ ដើម្បីត្រួតពិនិត្យ និងតាមដានទៅលើការដើរហើររបស់បុគ្គល ហើយនិងដើម្បីធានាថានឹងមិនមានការជ្រៀតជ្រែកជាមួយនឹងកិច្ចការរដ្ឋបាលតុលាការ។

លក្ខខណ្ឌទាំងអស់នេះ គឺមិនអាចដាក់បាននោះឡើយ ដោយផ្អែកទៅលើមាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ផងដែរ គឺនៅត្រង់វិធាន៦៥ និយាយអំពីការដាក់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការ ដែលបញ្ហាទាំងអស់នេះគឺមានបានបញ្ជាក់ច្បាស់នៅក្នុងលក្ខខណ្ឌដែលបានស្នើឡើង។

[១១:១៥:៤៩]

ដូច្នេះហើយវាជាការដែលមិនពិត ដែលម្ចាស់បណ្តឹងសាទុក្ខព្យាយាមស្វែងរក ដោយបង្កើតនូវទឡ្ហីករណ៍ ក៏ដូចជាដាក់នូវសារណាបន្ថែម ដែលបង្ហាញនៅក្នុងឯកសារចុះថ្ងៃទី២៨ ខែ៩ ឆ្នាំ២០១២ នៅត្រង់កថាខណ្ឌទី៥។ ម្ចាស់បណ្តឹងសាទុក្ខបានលើកឡើងថា ជាដំបូងលក្ខខណ្ឌទាំងអស់នេះគឺដើម្បីធានាទៅដល់លទ្ធភាពក្នុងការជំនុំជម្រះនៅពេលអនាគតទៅលើចុងបណ្តឹងសាទុក្ខ ក៏ដូចជាការបញ្ជាក់អំពីទីតាំងរបស់ចុងបណ្តឹងសាទុក្ខ ហើយក៏ដើម្បីធានានូវសុចរិតភាពរបស់កិច្ចដំណើរការនីតិវិធី ព្រមទាំងដើម្បីការពារទៅដល់បុគ្គលដទៃទៀត ហើយនិងការពារទៅលើសម្ពាធដែលអាចកើតឡើងទៅលើសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏បុគ្គលនានា ដែលអាចក្លាយទៅជាសាក្សី ហើយក៏ដូចជាការដើម្បីការពារ និងរក្សានូវសន្តិសុខ -- សុវត្ថិភាពសាធារណៈ។ ទាំងអស់នេះគឺមានលក្ខខណ្ឌជាអត្តនោម័តិ ព្រោះថាមិនមានចែងនៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុងនោះឡើយ។ គឺនៅត្រង់ចំណុចដែលសម្រេចអំពីជនជាប់ចោទ ឬក៏ជនត្រូវចោទ ដែលត្រូវឃុំឃាំងដើម្បីការពារ។

[១១:១៧:៣៩]

ហេតុដូច្នេះហើយនៅក្នុងទឡ្ហីករណ៍របស់សហមេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ដែលបានលើកឡើងរួចមកហើយ គឺថាការធ្វើបែបនេះគឺដើម្បីធានាទៅដល់លទ្ធភាពនៃការនាំយកចុងបណ្តឹងដើម្បីមកធ្វើការសវនាការជាបន្តទៅទៀតនេះ។

ប្រសិនបើមានគោលបំណងបែបនេះ យើងមិនឃើញមានភស្តុតាងណាមួយដែលបង្ហាញឲ្យឃើញថា ចុងចម្លើយចាំបាច់ត្រូវការការពារ ទទួលការការពារពីបុគ្គលរូបផ្សេងនោះឡើយ។ ចុងបណ្តឹងនៅពេលនេះគឺកំពុងរស់នៅ ស្នាក់នៅជាមួយនឹងគ្រួសាររបស់ខ្លួនក្នុងរយៈពេលជាច្រើន ហើយគាត់មិន

ជួបប្រទះនូវបញ្ហាអ្វីឡើយ។ ហើយក៏ពុំមានភស្តុតាងណាមួយ ឬក៏ក៏ពុំមានឃើញការដាក់សម្ពាធទៅលើបុគ្គលដទៃទៀត ដែលមានផលប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធី ហើយក៏មិនមានការព្យាយាមទាក់ទងជាមួយនឹងសហជនជាប់ចោទ លើកលែងតែប្តីរបស់គាត់នោះឡើយ។ ហើយក៏មិនមានភស្តុតាងដែលបង្ហាញនូវការព្រួយបារម្ភក្នុងដំណាក់កាលនេះ ដែលថាវាប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ។ សាធារណជន សណ្តាប់ធ្នាប់សាធារណៈគឺមានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់សាលាដំបូងពាក់ព័ន្ធទៅនឹងការដោះលែងចុងបណ្តឹង ហើយបានលើកឡើងដោយមានលក្ខណៈសុភវិនិច្ឆ័យ និងត្រឹមត្រូវ។

[១១:១៩:៣៣]

ដូច្នេះហើយគ្មានមូលដ្ឋានណាមួយដែលអាចសម្រេចផ្ទុយពីនោះនោះទេ។ តុលាការត្រូវតែមានភស្តុតាងច្បាស់លាស់ គឺត្រូវយោងទៅលើយុត្តិសាស្ត្រអន្តរជាតិ ក្នុងករណីដែលខ្លួនចង់ធ្វើការបំពេញគោលបំណង និងលក្ខខណ្ឌដូចដែលខ្ញុំបានលើកឡើងនេះ។ ជាការពិត គោលបំណងចម្បងពាក់ព័ន្ធទៅនឹងការជូនដំណឹងអំពីអាសយដ្ឋាននោះ ជាការពិតទៅ យើងឃើញថាវាជាការបង្គាប់មួយដោយមិនមានលក្ខណៈជាក់ស្តែងតាមការលើកឡើងរបស់យើងខ្ញុំ។ ហើយការបង្គាប់ឲ្យផ្តល់ ជូនដំណឹងអំពីអាសយ-ដ្ឋាននេះ គឺវាហាក់ដូចជាចង់បង្ហាញថា នឹងមានជំនុំជម្រះនាពេលអនាគត។

[១១:២០:៣១]

យើងឃើញថាយុត្តាធិការរបស់តុលាការ គឺមិនមានក្នុងការកំណត់ដាក់លក្ខខណ្ឌទៅលើចុងបណ្តឹងនោះទេ ដែលថាការដាក់លក្ខខណ្ឌនេះដើម្បីធានានូវការជំនុំជម្រះដោយយុត្តិធម៌នោះ។ ជាការពិតទៅ យើងមិនចាំបាច់ដាក់លក្ខខណ្ឌនេះទេ ពលរដ្ឋទាំងអស់នៅក្នុងប្រទេសនេះដូចនៅក្នុងប្រទេសដទៃទៀត មានកាតព្វកិច្ចធានាមិនធ្វើការជ្រៀតជ្រែកនៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ។

ដូច្នេះ ប្រសិនបើមានការរំលោភកិច្ចការរដ្ឋបាលតុលាការនោះ ចារី អ្នកប្រព្រឹត្តខុសគឺនឹងត្រូវទទួលទោសទណ្ឌតាមច្បាប់ព្រហ្មទណ្ឌជាមិនខាន។ ដូច្នេះ យើងខ្ញុំសូមលើកឡើងថា ចុងបណ្តឹងគឺគាត់មានសិទ្ធិរបស់គាត់ ហើយគាត់បានគោរពទៅតាមវិធានផ្ទៃក្នុងនៃតុលាការនេះ ដែលវិធាននេះគឺបានចែងឲ្យបានយ៉ាងច្បាស់លាស់ ដែលថាមានបទប្បញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាមានចែងនៅក្នុងក្រមនីតិវិធីរបស់បារាំងផងដែរ។ លក្ខខណ្ឌដែលបានស្នើឡើងនេះគឺមានន័យថា ដើម្បីឲ្យចុងចម្លើយនោះមានវត្តមាននៅក្នុងការជំនុំជម្រះ និងមិនមានការជ្រៀតជ្រែកពីចុងចម្លើយ។

[១១:២២:០០]

យើងខ្ញុំសូមលើកឡើងថា វាជាកំហុសមួយទាំងស្រុងពីខាងដើមបណ្តឹងសាទុក្ខដែលបានលើកឡើងអំពីស្ថានភាព ដែលកំពុងជួបប្រទះដោយអង្គជំនុំជម្រះនៅពេលនេះ។ នេះគឺជាការអនុវត្តសិទ្ធិស្មើគ្នារវាងផលប្រយោជន៍ដែលវាអាចទទួលនូវគ្រោះថ្នាក់។ វាមិនមែនជាការអនុវត្តតុល្យភាពសិទ្ធិនៅក្នុងពេលនេះនេះទេ។ ស្ថានភាពនេះគឺជាស្ថានភាពមួយដែលជនជាប់ចោទ ឬក៏យើងហៅថា "ចុងចម្លើយ" មិនមានលទ្ធភាពចូលរួមនៅក្នុងការជំនុំជម្រះក្តីនេះទេ គឺគាត់មិនអាចចូលរួមក្នុងន័យ -- ក្នុងនាមខ្លួនគាត់ផ្ទាល់តែម្តង។ ដូច្នេះដោយសារហេតុផលនេះ ប្រសិនបើមានការដាក់លក្ខខណ្ឌណាមួយទៅលើចុងចម្លើយនោះ គឺការដាក់លក្ខខណ្ឌនេះ គឺត្រូវតែបង្ហាញថា វាមានការរំលោភបំពានពីខាងចុងចម្លើយ។ ហើយការបំពាននោះគឺត្រូវតែបំពានដោយចេតនាទៀត។ ហើយត្រូវតែបង្ហាញថា ចុងចម្លើយគឺបានគេចវេះពីកាតព្វកិច្ចត្រួតពិនិត្យរបស់តុលាការ។ បើសិនជាក្នុងករណីនេះមែន យោងតាមមាត្រា២៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមអាចធ្វើការបង្គាប់ឲ្យឃុំខ្លួនបាន។

[១១:២៣:៤៩]

ប្រសិនបើមានការបំពានដោយចេតនាណាមួយនៅក្នុងប្រព័ន្ធយុត្តិធម៌នេះ គឺតុលាការអាចដាក់ទោសដោយសមស្របបាន។ ដូច្នេះហើយវាជាកិច្ចមួយមិនត្រឹមត្រូវនៅក្នុងប្រព័ន្ធយុត្តិធម៌ ដែលតម្រូវឲ្យមានការដាក់លក្ខខណ្ឌទៅលើចុងចម្លើយ ដែលលក្ខខណ្ឌទាំងអស់នេះមិនបានបំពេញផងនោះ។ ជាពិសេសនៅក្នុងករណីដែលមិនបានគិតពីការព្រួយបារម្ភរបស់បុគ្គលម្នាក់ឲ្យបានពេញលេញ។ ហើយការរំលោភបំពាននោះមិនបានឃើញប្រព្រឹត្តឡើងហើយមានការដាក់ទណ្ឌកម្មផងនោះ។ ករណីនេះគឺមិនមានកើតឡើងនោះទេ។ ជាការពិតណាស់ គឺប្រសិនបើឆ្លងតាមរយៈភស្តុតាង វាបានបង្ហាញឲ្យយើងឃើញថា ចុងចម្លើយមិនបានដឹង និងយល់អំពីលក្ខខណ្ឌនេះផងនោះ ហើយគាត់មិនដឹងថាតើត្រូវគោរពតាមរបៀបណាផងនោះ។ ដូច្នេះហើយចំណុចនេះ គឺចុងចម្លើយនេះ គឺគាត់ដើរតាមផ្លូវគាត់មិនដឹងថាត្រូវទៅណា ហើយគាត់វង្វេងវង្វាន់នោះ។ ការដាក់ទណ្ឌកម្ម ដាក់លក្ខខណ្ឌទៅលើគាត់នោះ គឺវាជាការធ្វើឡើងដោយអមនុស្សធម៌ទៅលើកិច្ចការ និងការងាររបស់បុគ្គលរូបនេះ។

[១១:២៥:២៣]

គ្មានតុលាការណាមួយ ដែលមានសិទ្ធិ និងមានលទ្ធភាព ដាក់វិធានការដោយបង្ខំទៅលើចុងចម្លើយ ដែលភស្តុតាងបានបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ថា ចុងចម្លើយពុំអាចមានលទ្ធភាពគោរព

តាមលក្ខខណ្ឌនេះ។ ការដាក់លក្ខខណ្ឌ គឺជាការមាក់ងាយទៅលើប្រព័ន្ធយុត្តិធម៌ទៅវិញទេ ប្រសិនបើធ្វើឡើង។

ស្ថានភាពរបស់ចុងចម្លើយក្នុងពេលនេះ គឺបង្ហាញឲ្យយើងឃើញថា ចុងចម្លើយទោះបីជាគាត់ទទួលរងចោទប្រកាន់ក៏ដោយ ក៏គាត់នៅតែជាជនគ្មានទោសនៅឡើយ។ នេះជាសិទ្ធិរបស់គាត់។ ចុងចម្លើយមានសិទ្ធិសេរីភាពដើរហើររបស់ខ្លួន។ សិទ្ធិនេះគឺអាចកម្រិត និងរឹតត្បិតបាន ប្រសិនបើមានហេតុផលត្រឹមត្រូវ និងសមរម្យ។

[១១:២៦:២៧]

វិធានផ្ទៃក្នុងបានបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ថា ទោះបីជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរយ៉ាងណាក៏ដោយវិធានផ្ទៃក្នុងគឺមានន័យថា ទាល់តែមានការរំលោភបំពានទៅលើលក្ខខណ្ឌ ទើបមានការដាក់លក្ខខណ្ឌបាន។ វិធានចែងអំពីការឃុំខ្លួននោះ គឺអាចធ្វើទៅឡើងបាន ក្នុងករណីដែលវាគោរពទៅតាមវិធាន៦៣ នៃវិធានផ្ទៃក្នុង និងការដោះលែងឲ្យនៅក្រៅឃុំតាមវិធាន៦៥ នៃវិធានផ្ទៃក្នុង ដែលវាករណីមួយចំនួនពុំចាំបាច់ឲ្យមានការឃុំខ្លួននោះទេ។ ហើយយើងក៏ត្រូវគោរពទៅលើការដោះលែងឲ្យមានសេរីភាពក្នុងករណីដែលមានហេតុផលសមរម្យផងដែរនោះ។ ប្រសិនបើតុលាការយល់ឃើញថា ខ្លួនយល់ឃើញថាមានលក្ខណៈសមហេតុផល ក្នុងការដាក់លក្ខខណ្ឌ ដើម្បីសម្រេចគោលបំណងនោះដូច្នេះយើងត្រូវពិចារណាជាចាំបាច់ ថាតើការអនុវត្តទៅលើ -- តាមលក្ខខណ្ឌនោះអាចគោរពបានដែរឬទេ ដោយចុងចម្លើយ។

ប្រសិនបើអាចគោរពទៅបានតាមលក្ខខណ្ឌ ដូចដែលយើងបានរៀបរាប់ថា ចុងចម្លើយគឺមិនអាចគោរពទៅតាមលក្ខខណ្ឌ ដោយសារតែគាត់អសមត្ថភាព និងអលទ្ធភាពនោះ។ ដូច្នេះហើយ គឺការដាក់លក្ខខណ្ឌនេះ គួរតែត្រូវបង្គាប់ឲ្យមានអាណាព្យាបាលទូទៅ។ សាលាដំបូងរាជធានីភ្នំពេញ គឺមានយុត្តាធិការដោយឡែក ហើយអង្គជំនុំជម្រះនេះ ពុំមានយុត្តាធិការកំណត់លក្ខខណ្ឌដែលត្រូវធ្វើឡើងចំពោះអាណាព្យាបាលនោះទេ។

[១១:២៨:២១]

អាណាព្យាបាលគឺមិនត្រូវមានកាតព្វកិច្ច ៗក្នុងការធានាឲ្យចុងចម្លើយគោរពតាមលក្ខខណ្ឌនេះទេ។ វិធានបទប្បញ្ញត្តិចែងយ៉ាងច្បាស់ថា មិនមែនតតីយជនជាអ្នកត្រូវធ្វើយ៉ាងណាធានាការគោរពលក្ខខណ្ឌនោះទេ ក៏ប៉ុន្តែបុគ្គលខ្លួនឯងដែលទទួលរងលក្ខខណ្ឌនោះ គឺត្រូវតែធ្វើយ៉ាងណាមានលទ្ធភាព

យល់ដឹង និងអាចគោរពទៅតាមលក្ខខណ្ឌនោះបាន។

យើងខ្ញុំសូមលើកឡើងមតិមួយចំនួនពាក់ព័ន្ធទៅនឹងបញ្ហាអាណាព្យាបាលនេះ។ អាណាព្យាបាល មានអំណាចតាមផ្លូវច្បាប់ ដើម្បីថែទាំថែរក្សាផលប្រយោជន៍ ឯកជន និងទ្រព្យសម្បត្តិរបស់បុគ្គលមួយរូបទៀត ដែលចាំបាច់ត្រូវការការពារចំពោះគាត់។ នៅពេលដែលមានករណីចាំបាច់ ត្រូវមានការតែងតាំងអាណាព្យាបាលចំពោះបុគ្គលមួយរូប ដែលមិនមានលទ្ធភាពក្នុងការធានាផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ខ្លួន ដោយសារតែគាត់មានវិបល្លាស ស្មារតី អសមត្ថភាព។ នេះគឺជាអត្ថន័យពាក់ព័ន្ធទៅនឹងនិយមន័យនៃពាក្យថា អាណាព្យាបាល។

ដូច្នេះ គឺការតែងតាំងដើម្បីការពារដំណើរការមុខងាររបស់បុគ្គលមួយរូប ហើយមិនមែនដើម្បីធានាឱ្យធ្វើយ៉ាងណាបុគ្គលម្នាក់គោរពលក្ខខណ្ឌដោយបង្ខំរបស់តុលាការនោះទេ។ នេះគឺជាករណីផ្ទុយទៅវិញនោះ។ អាណាព្យាបាលទូទៅ គឺអាចធ្វើឡើងទៅបាន គឺដើម្បីធ្វើយ៉ាងណាឱ្យ អៀង ធីរិទ្ធ ថែទាំម្តាយរបស់ខ្លួន។ វាជាវិធានការដើម្បីការពារ និងថែទាំចុងចម្លើយដែលគាត់មិនមានលទ្ធភាពថែទាំខ្លួនឯង។

យោងតាមមាត្រា២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ -- នៃក្រមរដ្ឋប្បវេណីគឺវាអាចពាក់ព័ន្ធទៅនឹងស្ថានភាពដែលបុគ្គលមួយរូបមិនអាចមានសមត្ថភាពយល់ ឬក៏ថែទាំខ្លួនឯង មិនអាចយល់អំពីសកម្មភាពការទទួលខុសត្រូវរបស់គាត់ ដោយសារតែវិបល្លាសស្មារតី។ យោងតាមមាត្រា២៤នេះ ក្នុងករណីមានបញ្ហានេះកើតឡើងនោះ គឺថា ត្រូវតែមានការតែតាំងអាណាព្យាបាលទូទៅ។

[១១:៣០:៥៩]

ខ្ញុំដឹងថា អង្គជំនុំជម្រះមានមាត្រានេះនៅក្នុងដៃ។ ខ្ញុំសូមលើកឡើងថា ពាក់ព័ន្ធទៅនឹងការបង្គាប់អាណាព្យាបាលទូទៅនេះ យើងខ្ញុំសូមលើកឡើងថា យើងឃើញមានការសម្រេចនៅក្នុងលក្ខណៈមួយដែលវាមិនមានលក្ខណៈសមហេតុផល។ ពាក្យសុំដែលបានលើកឡើងនេះ គឺមិនមែនធ្វើការជំរុញពីលោកស្រី អៀង វិជីដា នោះទេ ដែលជាកូនស្រីរបស់ចុងចម្លើយ។ ពាក្យសុំនេះ គឺបានធ្វើឡើងក្រោយពីអនុ -- ក្រោយពីសហព្រះរាជអាជ្ញារងលោក យ៉េត ចរិយា បានធ្វើឡើង គឺលោកមានតួនាទីជាព្រះរាជអាជ្ញានៅក្នុងសាលាដំបូងរាជធានីភ្នំពេញ ហើយលោកក្នុងនាមជាសហព្រះរាជអាជ្ញា លោកបានធ្វើការដាក់ពាក្យសុំ ស្នើសុំតែងតាំងអាណាព្យាបាល។

យើងខ្ញុំទទួលស្គាល់ថា លោកសហព្រះរាជអាជ្ញានោះគឺគាត់បាននិយាយជាមួយនឹងកូន -- សហ

មេធាវីរបស់យើងខ្ញុំអំពីបញ្ហានេះ។ ក៏ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ថា ការស្នើសុំអាណាព្យាបាលទូទៅនេះ គឺធ្វើឡើងដោយសហព្រះរាជអាជ្ញានោះតែប៉ុណ្ណោះ។

[១១:៣២:៣៣]

ការដាក់ពាក្យសុំនេះធ្វើឡើងក្នុងពេលមួយមិនសមស្របនៅថ្ងៃទី១០ បានធ្វើឡើងនៅក្នុងថ្ងៃទី១០ ខែកញ្ញា តែប៉ុណ្ណោះ។ បន្ទាប់មកនៅថ្ងៃ១៣ ខែកញ្ញា សាលាដំបូងបានចេញសេចក្តីសម្រេចថា ការដោះលែងនេះគឺត្រូវធ្វើឡើង ដោះលែងដោយលក្ខខណ្ឌ ដោយគ្មានលក្ខខណ្ឌ ហើយនៅថ្ងៃដដែលនេះ គឺសហព្រះរាជអាជ្ញារងនៅទីនេះ គឺបានទៅសាលាដំបូងរាជធានីភ្នំពេញផ្តល់ជូនឯកសារនានា ដើម្បីស្នើសុំលោកស្រី អៀង វិជីដា ធ្វើជាអាណាព្យាបាល។

សេចក្តីសម្រេចតែងតាំងអាណាព្យាបាលនេះ គឺធ្វើឡើងដោយផ្អែកលើមូលដ្ឋានលើកឡើងដោយសហព្រះរាជអាជ្ញានៅទីនោះ។ ដោយលើកឡើងថា ចុងចម្លើយគឺគាត់មិនមានលទ្ធភាពយល់អំពីនីតិវិធីផ្លូវច្បាប់ កាតព្វកិច្ចផ្លូវច្បាប់។ ហើយដើម្បីដោះស្រាយលើបញ្ហាស្ថានភាពបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ដូច្នេះហើយសហព្រះរាជអាជ្ញាស្នើសុំឲ្យមានការតែងតាំង អៀង វិជីដា ដើម្បីធ្វើជាអាណាព្យាបាល។

[១១:៣៣:៥០]

សំណើរបស់ អៀង វិជីដា នោះមិនមានស្នើសុំអ្វីក្រៅពីតែការសុំថែទាំម្តាយរបស់ខ្លួននៅក្នុងគេហដ្ឋានផ្ទះរបស់ខ្លួនតែប៉ុណ្ណោះ។ ហើយដូច្នេះយើងឃើញថា មានការតែងតាំងអាណាព្យាបាលដូច្នេះមែន។ ហើយមិនមានការតម្រូវឲ្យមានការជូនដំណឹងអំពីអាសយដ្ឋាននោះទេ។ ហេតុដូច្នេះហើយយើងគិតថា សហព្រះរាជអាជ្ញាគាត់ត្រូវគោរពទៅតាមមាត្រា២៤ នៃក្រមរដ្ឋប្បវេណី ហើយត្រូវរង់ចាំសេចក្តីសម្រេចរបស់តុលាការកំពូលនេះសិន មុនពេលដែលយើងអនុវត្តវិធានការណាមួយ ដែលវាអាចលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការនេះត្រូវពិចារណា។ យើងខ្ញុំជឿជាក់ថា ទោះបីយ៉ាងណាក៏ដោយយើងខ្ញុំជឿជាក់ថា យើងគិតថា យើងត្រូវវាយតម្លៃស្ថានភាពនេះឲ្យបានត្រឹមត្រូវ។

យើងខ្ញុំសូមបញ្ជាក់ថា យើងមានអាណាព្យាបាលមែន នៅពេលដែលមានអាណាព្យាបាលនេះមិនមែនឲ្យប្រើប្រាស់របបអាណាព្យាបាលនេះ ដើម្បីដាក់លក្ខខណ្ឌទៅលើចុងចម្លើយនោះទេ។ តុលាការនេះត្រូវតែជឿជាក់ថា ចុងចម្លើយគាត់បានយល់អំពីលក្ខណៈ ឬប្រភេទនៃលក្ខខណ្ឌនេះ កាតព្វកិច្ចដែលដាក់ចំពោះខ្លួន ហើយនិងផលវិបាកដែលអាចកើតចេញពីការមិនគោរពតាមលក្ខខណ្ឌនេះ ដោយចុងចម្លើយ។

[១១:៣៥:៣៤]

យើងអាចនិយាយក្នុងន័យសម្មតិកម្មថា អសមត្ថភាពរបស់ចុងចម្លើយនៅក្នុងស្ថានភាពជាក់ស្តែងនោះ គឺថាគាត់មិនអាចនឹងគោរពតាមលក្ខខណ្ឌនោះឡើយ។ ដូច្នេះក្នុងករណីនេះយើងមិនអាចដាក់លក្ខខណ្ឌនោះឡើយ។

យើងខ្ញុំសូមលើកឡើងថា យើងត្រូវពិនិត្យមើលគោលការណ៍មូលដ្ឋានានា គោលការណ៍ទាំងអស់នោះត្រូវពិនិត្យមើលការរកឃើញរបស់សាលាដំបូងនៅទីនេះដែលបានបញ្ជាក់ថា ចុងចម្លើយគ្មានសមត្ថភាព--

**ប្រធានអង្គជំនុំ៖**

សូមៗលោកស្រីមេធាវីផ្អាកបន្តិច! ដើម្បីឲ្យខាងរៀបចំ ខាងឌីវីឌីបន្ថែម ដោយសារឌីវីឌីត្រូវអស់ហើយ។ សូមអញ្ជើញ ផ្អាកបន្តិចសិនបាទ!

*(សម្រាករយៈពេលខ្លី)*

[១១:៣៧:០០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកសហមេធាវីបន្ត។ បាទសូមអញ្ជើញ!

**លោកស្រី ដាយអាណា អេលីស៖**

ដើមបណ្តឹងសាទុក្ខបាននិយាយយោងទៅលើសំណុំរឿងចំនួនបី។ យើងសូមលើកឡើងថា រឿងក្តីទាំងបីនេះមិនមាន ឬក៏មិនមានចែងនៅក្នុងយុត្តាធិការអន្តរជាតិ ហើយដែលមានចែងនៅក្នុងយុត្តិ-សាស្ត្រអន្តរជាតិហ្នឹងមិនពាក់ព័ន្ធទៅនឹងស្ថានភាពបច្ចុប្បន្ននេះឡើយ។

មូលហេតុដែលយើងលើកឡើងបែបនេះ គឺថារឿងក្តីទាំងអស់នោះដែលខាងដើមបណ្តឹងសាទុក្ខបានលើកឡើងយកមកនិយាយនោះ គឺពាក់ព័ន្ធទៅនឹងករណីចំនួនពីរ គឺការបញ្ចប់សំណុំរឿង ហើយនិងសំណុំរឿងទី៣ គឺនិយាយអំពីជំងឺសតិបញ្ញា។ ជំនឿទី៣ គឺមិនអាចរស់ -- ហើយនិងករណីទី៣ គឺនិយាយអំពីជំងឺដែលមិនអាចព្យាបាលជាបាន ហើយដែលឈានទៅដល់ការមរណភាព។ ប៉ុន្តែចំពោះភាពមិនជាក់ស្តែងគឺថា គាត់នឹងអាចរស់បានទៅដល់ពេលណា។

[១១:៣៨:២៩]

ការផ្អែកទៅលើសេចក្តីសម្រេចទាំងអស់នេះ គឺនៅក្នុងរឿងថាលិក និង ជូគិក គឺថាជនជាប់ចោទ

មិនមានសមត្ថភាពក្នុងការយល់ ហើយជនជាប់ចោទមិនសមត្ថភាព ឬក៏មិនមានលទ្ធភាពក្នុងផ្នែករូបរាងកាយដែលធ្វើឲ្យជនជាប់ចោទអាចទទួលរងនូវការជំនុំជម្រះបាន។

ស្ថានភាពដែលកើតឡើងចំពោះរឿងក្តី ណាហាក គឺនិយាយអំពីជំងឺធ្ងន់ធ្ងរ។ ប៉ុន្តែចំពោះជំងឺធ្ងន់ធ្ងរនេះ គឺមិនមែនជាជំងឺដែលដូចគ្នានឹងជំងឺវង្វេងវង្វាន់ស្មារតីនោះឡើយ។ ជំងឺនៅក្នុងរឿងក្តី ណាហាក គឺជាជំងឺដែលមានតែការវិវត្តទៅមុខ ហើយនិងធ្វើឲ្យសុខភាពជនជាប់ចោទធ្លាក់ធ្ងន់ធ្ងរទៅៗ ដែលមិនមានការព្យាបាល ឬក៏មិនមានមធ្យោបាយណាមួយ។

ដូច្នេះអានេះគឺជាអ្វីដែលបានលើកឡើង ហើយវាបង្កឲ្យតុលាការសម្រេចដែលថា មិនមានលទ្ធផលណាមួយដែលយើងមិនអាចទាយស្មានមុនបាន។

ដូច្នេះខ្ញុំសូមលើកឡើងថា មិនមានរឿងក្តីណាមួយដែលមានលក្ខណៈប្រហាក់ប្រហែល ដែលមាននៅក្នុងយុត្តិសាស្ត្រ ដែលថារឿងក្តីទាំងអស់នោះនិយាយអំពីសម្បទាក្នុងការចូលរួមសវនាការ។ ហើយរឿងក្តីដែលលើកឡើងនោះ គឺវាផ្អែកទៅលើអង្គហេតុផ្សេងៗគ្នា នៅក្នុងរឿងក្តីផ្សេងៗគ្នា។ ដូច្នេះជាចុងក្រោយ យើងសូមលើកឡើងថា គោលការណ៍ជាមូលដ្ឋាន -- គោលការណ៍សំខាន់សម្រាប់អង្គជំនុំជម្រះគឺធ្វើការគោរព -- ធ្វើតាមគោរព -- ធ្វើការគោរពទៅតាមច្បាប់ដើម្បីគោរពទៅលើគោលការណ៍សច្ចធារណ៍នៃនិរទោស ហើយនិងទទួលស្គាល់នូវសិទ្ធិក្នុងការមានសេរីភាពដើរហើរ ហើយនិងការទទួលយកនូវការពិត ទោះបីថាទំហំនៃឧក្រិដ្ឋកម្មមានទំហំធំធេងយ៉ាងណាក៏ដោយ។

យើងមិនអាចទទួលយកបានទេ ហើយវាជាការមិនត្រឹមត្រូវនៅក្នុងសង្គមបែបស៊ីវិល័យ ដែលយើងធ្វើការដាក់នូវលក្ខខណ្ឌរឹតបន្តឹង និងដោយបង្ខំទៅលើបុគ្គលមួយ ដែលបុគ្គលនោះមិនមានសមត្ថ-ភាពយល់ ដឹង ថាតើលក្ខខណ្ឌដែលបានដាក់មកលើរូបគាត់ហ្នឹងគឺជាលក្ខខណ្ឌអ្វី។ ហើយយើងក៏មិនត្រូវដាក់ទៅលើបុគ្គលដែលគាត់មិនដឹងថា តើធ្វើយ៉ាងណាដើម្បីគោរពទៅតាមលក្ខខណ្ឌទាំងអស់នោះ។

ហេតុដូច្នេះយើងសូមស្នើថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ដោះលែងដោយគ្មានលក្ខខណ្ឌគួរត្រូវបានរក្សាទុកដោយអង្គជំនុំជម្រះតុលាការកំពូល។

នេះគឺជាសារណារបស់យើងហើយ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គជំនុំជម្រះដែលបានផ្តល់ឱកាសដល់យើងខ្ញុំ។ សូមអរគុណ។

[១១:៤១:៥០]

**ប្រធានអង្គជំនុំ៖**

ជាបន្តតុលាការកំពូលត្រូវសួរជនជាប់ចោទ ប៉ុន្តែដើម្បីបញ្ជាក់ឲ្យបានច្បាស់ ខ្ញុំសូមសហមេធាវីការពារក្ដីបញ្ជាក់ឡើងវិញឡើងវិញ អំពីតើអាចឲ្យជន -- តើជនជាប់ចោទនេះអាចឆ្លើយនូវសំណួរខ្លះរបស់អង្គជំនុំជម្រះតុលាការកំពូលបាននាពេលនេះដែរឬទេ?

**លោកស្រី ដាយអាណា អេលីស៖**

លោកប្រធានជាទីគោរព! យើងយល់ទៅលើចំណុចនេះ។ យើងយល់ដែលថា អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវសួរសំណួរទៅកាន់ចុងចម្លើយសាទុក្ខ។ ដោយសារតែលោកស្រី គាត់មកក្នុងព្រឹកនេះ ហើយប្រសិនបើគាត់អាចវិលត្រឡប់មកវិញនោះគឺ យើងខ្ញុំគិតថាគាត់នឹងអាចមក ត្រឡប់មកវិញដើម្បីត្រៀមឆ្លើយខ្លួន -- ឆ្លើយសំណួរទៅនឹងសំណួររបស់អង្គជំនុំជម្រះតុលាការកំពូល ហើយក្រៅពីនេះ គឺយើងខ្ញុំក៏មិនដឹងថា តើគាត់មានសមត្ថភាពឆ្លើយតបប៉ុនណាផងដែរ។

[១១:៤៣:១៥]

ដូច្នេះប្រសិនបើមានបង្គាប់នោះគឺថា គាត់ "ចុងចម្លើយ" នេះអាចត្រូវបាននាំមកទីនេះដោយវេជ្ជបណ្ឌិតដើម្បីជួយជ្រោមជ្រែងគាត់ក្នុងពេលឆ្លើយចម្លើយ -- ឆ្លើយសំណួរ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមអញ្ជើញសន្តិសុខនាំជនជាប់ចោទ ដើម្បីចូលមកសវនាការ!

*(មន្ត្រីសន្តិសុខនាំជនជាប់ចោទចូលក្នុងបន្ទប់សវនាការ)*

[១១:៥០:០០]

**ប្រធានអង្គជំនុំ៖**

បាទ សូមបន្តទៅទៀត។ ដោយសារស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ គឺមានការលំបាកក្នុងការនាំមកអង្គុយនៅកន្លែងក្រចកសេះនេះ ហើយក៏នាពេលនេះដែរ គឺយើងមិនធ្វើការសួរដេញដោល អំពីបញ្ហាភស្តុតាងទាក់ទិននឹងបណ្ដឹងសាទុក្ខទេ។ ដូច្នេះហើយគឺ អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកស្រីអង្គុយនៅក្បែរអ្នកអាណាព្យាបាលរបស់លោកស្រីបាន។ ហើយយើងខ្ញុំសូមបញ្ជាក់រំឭកបន្ថែមទៀតថា លោកស្រីគឺ ប្រាកដជាមានការនឿយហត់ណាស់ ដោយសារស្ថានភាពជំងឺរបស់លោកស្រីនេះគឺមានភាពឈឺចាប់ខ្លាំង ហើយនិងមានការនឿយ -- មានស្ថានភាពនេះគឺថា វាមានលក្ខណៈទន់ផង។ លោកស្រីអាចមានសិទ្ធិសុំទៅសម្រាកនៅបន្ទប់រង់ចាំ នៅពេលណាដែលស្ថានភាពសុខភាពលោកស្រី

00860796


ហ្នឹងមិនអាចដំណើរការទៅបាននៅពេលនេះ ហើយដែលជាកន្លែងមួយសម្រាប់តាមដានកិច្ចដំណើរការរហូតដល់ចប់។ ហើយដោយមានលោកស្រីពីររូប ដែលគាត់បាននាំអំមិញនេះគឺ ខាងផ្នែកសន្តិសុខសវនាការដែលអាចសម្រួលជួយលោកស្រី ក្នុងការនាំទៅវិញទៅមក និងតម្រូវការផ្សេងៗ។ ហើយម្យ៉ាងទៀតគឺខាងចៅក្រមគឺមានបំណងនឹងសួរសំណួរខ្លះទៅដល់លោកស្រី ហើយបើសិនជាលោកស្រីអាចឆ្លើយបាន គឺលោកស្រីអញ្ជើញលោកស្រីឆ្លើយ ប៉ុន្តែលោកស្រីក៏នៅមានសិទ្ធិថាមិនចាំបាច់ឆ្លើយ។ អាហ្នឹងគឺជាសិទ្ធិរបស់លោកស្រី ហើយសំណួរដែលពាក់ព័ន្ធហ្នឹង អាចនឹងសួរទៅលើកូនរបស់លោកស្រីដែរ។

[១១:៥១:៥៧]

**ប្រធានអង្គជំនុំ៖**

ចំពោះសំណួរទី១ ដែលខ្ញុំចង់សួរនេះគឺ តើបច្ចុប្បន្ននេះ លោកស្រី អៀង ធីរិទ្ធ ហ្នឹងមានសុខសប្បាយយ៉ាងម៉េច?

**លោកស្រី អៀង ធីរិទ្ធ៖**

ចាស។

**ប្រធានអង្គជំនុំ៖**

លោកស្រីអាចស្តាប់បានទេ? លោកស្រី តើលោកស្រីសុខសប្បាយជាទេបច្ចុប្បន្ននេះ?

**លោកស្រី អៀង ធីរិទ្ធ៖**

ខ្ញុំអត់អីទេ។ ខ្ញុំសុខសប្បាយជាទេចាស។

**ប្រធានអង្គជំនុំ៖**

បាទ ចាប់តាំងពីលោកស្រីវិលត្រឡប់ទៅផ្ទះរបស់លោក -- ខ្លួនវិញនោះ តើលោកស្រីបានប្រសើរជាងមុនដែរឬទេយ៉ាងណា?

**លោកស្រី អៀង ធីរិទ្ធ៖**

ល្អជាងមុន។ ព្រោះអ្នកដែលគេទទួលខ្ញុំហ្នឹង គេម្ចាស់ផ្ទះផង គេម្ចាស់ទឹកដីផង ឲ្យខ្ញុំនៅឲ្យបានស្រួលឲ្យឆាប់ជា។ ចាស ដូច្នេះ គាត់ជួយ។ គាត់ជួយច្រើន ព្រោះគេមើលឃើញយើងត្រូវការថ្នាំអីៗហ្នឹង គេរកគ្រូមកឲ្យបាន។ ធ្វើឲ្យខ្ញុំបានឆាប់ជាគ្រាន់បើឥឡូវហ្នឹង។

**ប្រធានអង្គជំនុំ៖**

ហើយជាបន្ត សូមអញ្ជើញលោកចៅក្រម ដែលមានបំណងសួរលោកស្រី អៀង ធីរិទ្ធ សូមអញ្ជើញ!

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណលោកប្រធាន។

លោកស្រី អៀង ធីរិទ្ធ តុលាការធ្វើយ៉ាងណាឲ្យលោកស្រីនេះ ត្រឡប់មកតុលាការវិញ។ ប្រសិនបើតុលាការស្នើឲ្យលោកស្រី វិលត្រឡប់មកតុលាការវិញក្នុងពេលអនាគតនោះគឺថា យើងខ្ញុំនឹងស្នើសុំពីលោកស្រី។ សំណួរដំបូងរបស់យើងខ្ញុំនោះគឺថា តើលោកស្រីត្រៀមខ្លួនជាស្រេចក្នុងការត្រឡប់មកកាន់តុលាការវិញដែរឬទេ ប្រសិនបើតុលាការស្នើឲ្យលោកស្រី មកកាន់តុលាការវិញនាពេលអនាគតនោះ?

[១១:៥៤:២៦]

**លោកស្រី អៀង ធីរិទ្ធ៖**

ចាស។ ខ្ញុំក៏អរគុណច្រើនដែរ ក៏ប៉ុន្តែសភាពការណ៍ដែលខ្ញុំមករស់នៅមួយរយៈពេលធំនោះ គឺខ្ញុំមានជំងឺ។ លោកគ្រូនោះក៏ឃើញដែរខ្ញុំឈឺ។ ខ្ញុំឈឺញ៉ើកញាប់ណាស់ ខ្ញុំមិនបាននៅក្នុងព្រៃ ឬនៅក្នុងកន្លែងផ្សេងនោះ ហើយវាបាត់ជំងឺ វាអត់បាត់ទេជំងឺ ជំងឺនៅតែមានដដែល។ ខ្ញុំគ្រាន់សុំជម្រាបប៉ុណ្ណឹងទេណា។

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណលោកស្រី។ តើលោកស្រីមានអាសយដ្ឋានជាអចិន្ត្រៃយ៍ នៅក្នុងប្រទេសកម្ពុជាដែរឬទេ?

**លោកស្រី អៀង ធីរិទ្ធ៖**

នៅភ្នំពេញមាន ហើយមកដល់កន្លែងថ្មីនេះ ដែលគេថាកន្លែង ដែលគេជួយព្យាបាលពួកខ្ញុំបាននោះ ខ្ញុំបាននោះ ខ្ញុំក៏បានមកៗតាមហ្នឹងដែរ។ មកតាមហ្នឹង ក៏តាំងពីស្តេចគេ តាំងពីអីគេ គេទទួលស្គាល់ជួយមើល។ ខ្ញុំចង់ជម្រាបប៉ុណ្ណឹង។

[១១:៥៥:៥៨]

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណ។ តើលោកស្រីមានមិត្តភក្តិ នៅក្រៅប្រទេសទេ? នៅក្រៅប្រទេសកម្ពុជាដែរឬទេ?

**លោកស្រី អៀង ធីរិទ្ធ៖**

មិត្តភក្តិនោះ ជាការធម្មតាទេខ្ញុំ មានមិត្តភក្តិនៅក្រៅប្រទេសកម្ពុជា តែងតែមានអ៊ីចឹងហើយ ប៉ុន្តែក្នុងឋានៈគ្នាជាសាស្ត្រាចារ្យក្តី ភាគច្រើនជាសាស្ត្រាចារ្យ ឬជាគ្រូបង្រៀនអីក្តីអ៊ីចឹង គាត់មានតែចិត្ត ៗគាត់ល្អមែនទែនតែម្តង គាត់នឹកឃើញ គាត់ការពារខ្ញុំច្រើនណាស់ ធ្វើឲ្យអ្នកជិតខាងហ្នឹងក៏គេគោរព គាត់ដែរ។ ព្រោះគាត់មិនដែលថា ខ្ញុំជាមនុស្សធ្វើផ្តេសផ្តាសម្នាក់អត់មានទេ គឺថាអត់ឃើញថាខ្ញុំ តាំងពីតូចរហូតដល់ធំ គឺថារៀនរហូតដល់ជាមួយបារាំងផ្ទាល់ក៏រៀនបាន ធ្វើឲ្យគ្រូបារាំងពេញចិត្តពេញថ្លើម ច្រើន។ ក្នុងបញ្ហានេះ គាត់គ្រាន់តែប្រាប់ប៉ុណ្ណឹង ថាអូនឯងកុំព្រួយ អូនឯងក៏មានការងារធ្វើហើយ ចាស។

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណ។ តើលោកស្រីគិតថា ចាំបាច់ដែលត្រូវធ្វើដំណើរទៅបរទេស ចេញពីក្រៅប្រទេស កម្ពុជាដែរឬទេ?

**លោកស្រី អៀង ធីរិទ្ធ៖**

ពេលនុ៎ង ខ្ញុំមិនទាន់មាន -- រហូតដល់ឥឡូវហ្នឹង ខ្ញុំមិនទាន់មានគំនិតអ៊ីចឹងទេ ព្រោះនៅផ្ទះហ្នឹងក៏ មានខ្មែរ គេអ្នកចេះអ្នកដឹងអីដែរ។ ហើយគេជួយយើង ខ្ញុំចង់បានអី គេចង់ធ្វើអី ខ្ញុំពន្យល់គេទៅ គេក៏ រៀបចំស្រួលបួលទៅ គេក៏ជួយច្រើនដែរក្នុងការហ្នឹង ក្នុងការធ្វើយ៉ាងណាកុំឲ្យយើងបាត់ចោលនូវភាសា បរទេស។ តាមរយៈហ្នឹង ក៏ខ្ញុំមិនឲ្យបាត់បង់ភាសាបរទេសដែលខ្ញុំបានចេះទេ ព្រោះទាំងអស់គ្នាគេ ឯកភាពគ្នា គេជួយៗយើងកុំឲ្យភ្លេច ព្រោះយើងជាប្រទេសមួយតូចទេ មនុស្សតិចទេ។ ខ្ញុំគ្រាន់ចង់ ជម្រាបប៉ុណ្ណឹង គាត់សប្បាយចិត្ត ដោយសារថាអ្វីដែលបានរៀនសូត្រជាមួយគាត់អីទាំងប៉ុន្មានហ្នឹង គឺ ថាយើងនៅចាំទាំងអស់ ហើយយើងអាចនិយាយបាន។ ខ្ញុំចង់ជម្រាបប៉ុណ្ណឹងទេ ការពិតគឺមានប៉ុណ្ណឹង។

[១១:៥៨:៤៧]

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណ។ តុលាការពិចារណាថា នឹងបន្តត្រួតពិនិត្យមើលស្ថានភាពសុខភាពរបស់លោក ស្រីបន្តទៀត។ តើលោកស្រីនាពេលបច្ចុប្បន្នមានបានទទួលការព្យាបាលខាងវេជ្ជសាស្ត្រដែរឬទេ?

**លោកស្រី អៀង ធីរិទ្ធ៖**

សព្វថ្ងៃហ្នឹងដែលកន្លែងខ្ញុំនៅហ្នឹងគឺ ខាងផ្នែកគេៗមាននេះរបស់គេ។ គេដឹងថា យើងឈឺស្អីៗ គេដឹងទាំងអស់។ ដូច្នេះ គេចេះតែនៅជួយៗរៀបចំឲ្យយើងធ្វើម៉េចកុំឲ្យ -- ព្រោះខ្ញុំពេលខ្លះខ្ញុំធ្វើការច្រើនទៅ ខ្ញុំថា ខ្ញុំមិនចង់ហូបបាយនេះ ៗ ខ្ញុំចេះតែលោតៗចោលទៅ ហើយអាហ្នឹងមួយហើយដែលគាត់ខំជួយណាស់។ គាត់ថា សុំអ្នកបងពិសាបាយឲ្យបានទៀងទាត់ទៅ អ្នកបងមុខជាបានជាឆាប់ហើយ។ ហើយការហ្នឹងក៏ គាត់ក៏ទាំងអស់គ្នា មានគ្រប់នេះទាំងអស់ហ្នឹងគេជួយគ្នា ដើម្បីឲ្យខ្ញុំបានទទួលទានបាយទៀងទាត់។ ដល់ឃើញទទួលទានបាយទៀងទាត់អ៊ីចឹងទៅ គាត់ឃើញថា ខ្ញុំមើលសៀវភៅបានច្រើនជាងមុន។ មិនត្រឹមតែមានសៀវភៅនេះជាងមុន ក៏ឃើញរីករាយរាក់ទាក់ជាមួយពួកគាត់ហ្នឹងបានច្បាស់លាស់ល្អណាស់។ គាត់សប្បាយចិត្តណាស់ ទាំងអស់គឺថា គាត់ធ្វើឲ្យខ្ញុំជាបាន។ គាត់និយាយបានតែប៉ុណ្ណឹងទេ ទាំងអស់ខំធ្វើឲ្យខ្ញុំជាបាន។ មានប៉ុណ្ណឹងទេ។

[១២:០០:៤៩]

**ចៅក្រម ផ្លូរិនស៍ ម៉ុមបា៖**

សូមអរគុណច្រើនលោកស្រី អៀង ធីរិទ្ធ ដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ សូមអរគុណ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំមានសំណួរមួយទៀតលោកស្រី។ ដោយមិនចាំបាច់ប្រាប់លម្អិតអំពីចម្លើយរបស់លោក តើលោកស្រីដឹងថា តើមានវត្តមានរបស់សន្តិសុខដែរឬទេនៅក្នុងទីនេះ? តើមានការប្រើប្រាស់នូវប្រព័ន្ធសន្តិសុខដែរឬទេ ដែលគេប្រើប្រាស់ជាមួយលោកស្រី?

**លោកស្រី អៀង ធីរិទ្ធ៖**

មើលទាំងអស់គ្នាមើល ដូចអត់មានទេណា។ ខ្ញុំពេលដែលខ្ញុំមកនៅប្រទេសអស់លោកនេះ គឺខ្ញុំរស់នៅតាមធម្មតាៗទេ គេមិនដែលបែងចែកថាខ្ញុំហ្នឹង ជាមនុស្សខាងសន្តិសុខខាងអី គេអត់ទេ។ ហើយអ្នកណាដែលគេចេះខ្មែររួចហើយ គេច្រើនតែមកនិយាយជាមួយខ្ញុំ ព្រោះខ្ញុំក្តាប់បានពាក្យអង់គ្លេសច្រើនបន្តិចៗអ៊ីចឹងទៅ ពាក្យអង់គ្លេសដែលលោកនេះគាត់អ្នកធ្វើនោះណា។ ដល់អ៊ីចឹងទៅគេៗគ្រាន់តែឃើញថា យើងអាចចេះភាសាបរទេសបាន។ ខ្ញុំគ្រាន់តែសូមជម្រាបប៉ុណ្ណឹងទេ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ហើយសូមអរគុណ។ យើងដឹងអំពីបញ្ហានេះ ប៉ុន្តែខ្ញុំចង់ដឹងថាតើវារំខានលោកស្រីដែរឬអត់

ដែលមានការត្រួតពិនិត្យផ្នែកសុវត្ថិភាព ផ្នែកសន្តិសុខ ដែលបានស្នើ ប្រសិនបើខាងព្រះរាជអាជ្ញាគាត់ស្នើឲ្យមានការត្រួតពិនិត្យសន្តិសុខហ្នឹង តើវារំខានដល់លោកស្រីដែរឬអត់?

**លោកស្រី អៀង ធីរិទ្ធ៖**

ទើបនឹងចាប់ផ្តើមទេពេលនោះ គឺបានធ្វើហើយ។ ខ្ញុំបានចាប់ផ្តើមធ្វើហើយ។ ដោយកន្លែងដែលយើងរស់នៅហ្នឹង មានសុទ្ធតែបរទេសៗ។ ហើយក៏យើងក៏អ្នកជិតខាងយើងទាំងអស់គ្នា ដែលគាត់ឃើញថា កូនចៅគាត់ក៏បានរៀនសូត្រស្អីៗច្រើនអ៊ីចឹង យើងជួយគាត់ គាត់លំបាកកន្លែងណា យើងជួយគាត់កន្លែងហ្នឹងអីហ្នឹង។ ខ្មែរយើងទាំងអស់គ្នាហ្នឹង គាត់ក៏ជួយយើងច្រើនណាស់ក្នុងបញ្ហានេះ។ ដល់អ៊ីចឹងទៅបងប្អូនខាងបារាំងនេះ ដែលនៅកន្លែងដែលខ្ញុំនៅនេះ គាត់ក៏ជួយអ្នកខ្មែរៗ ដែលមានជំងឺអីប៉ុន្មានគាត់ជួយទាំងអស់ ពេលដែលខ្ញុំនៅនោះ គាត់ជួយទាំងអស់តែម្តង គាត់ជួយៗច្រើនមែនទែនបញ្ហាហ្នឹង។

[១២:០៤:០៨]

**ចៅក្រម អាកនីស្កា ក្លូណ្ញវីកកា មីឡាត៖**

តើលោកស្រីចង់ឲ្យមានអ្នកទៅសួរសុខទុក្ខដែរឬទេ? តើលោកស្រីចង់ឲ្យមានការទៅសួរសុខទុក្ខដោយមនុស្សជាច្រើន ឬមួយក៏លោកស្រីចង់នៅស្ងាត់ស្ងៀមតែម្នាក់ឯងទេ?

**លោកស្រី អៀង ធីរិទ្ធ៖**

ខ្ញុំមិនចង់នៅស្ងាត់ស្ងៀមម្នាក់ឯងទេ ព្រោះពេលអង្កាល់ខ្ញុំនៅធ្វើការនៅកន្លែងខាងក្រោមហ្នឹងគឺបងប្អូនស្បែកសទាំងក្មេងទាំងចាស់ គាត់មកធ្វើការជាមួយខ្ញុំដែរ។ មិនអ៊ីចឹង? គាត់មកធ្វើការជាមួយយើងទាំងអស់ហ្នឹង។

**ចៅក្រម អាកនីស្កា ក្លូណ្ញវីកកា មីឡាត៖**

សូមអរគុណលោកស្រី។

**ប្រធានអង្គជំនុំ៖**

តុលាការកំពូលសូមប្រកាសសម្រាក១៥នាទី ដើម្បីចូលទៅពិភាក្សាគ្នាបន្តិចបាទ។ អ៊ីចឹងសូមអញ្ជើញខាងសន្តិសុខសវនាការ បើលោកស្រីចៅក្រម -- អ៎ូ! លោកស្រីជនជាប់ចោទនេះដែរអាចនៅហ្នឹងបាន គឺគាត់អាចសម្រាកនៅទីនេះ ប៉ុន្តែបើសិនជាគាត់មិនអាចនៅទីនេះបាន អាចត្រឡប់ទៅក្រោមអញ្ជើញគាត់ត្រឡប់ទៅក្រោមចុះបាទ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១២:១៨ នាទី)*

[១២:១៨:៣២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញអង្គុយ!

តុលាការប្រកាសបន្តសវនាការ។ ជាបន្ត -- ជាបន្តតុលាការកំពូលនឹងសួរសំណួរទៅដល់អ្នកអាណាព្យាបាលទូទៅ។

**ប្រធានអង្គជំនុំ៖**

លោកស្រី អៀង វិជីដា តើលោកស្រីស្នាក់នៅជាមួយ ឬមានភាពស្និទ្ធស្នាលជាមួយជនជាប់ចោទ អៀង ធីរិទ្ធ ដែរឬយ៉ាងណា?

**លោកស្រី អៀង វិជីដា៖**

ចាសៗ ខ្ញុំរស់នៅជាមួយគាត់ចាស។

**ប្រធានអង្គជំនុំ៖**

លោកស្រីរស់នៅជាគាត់នៅក្នុងផ្ទះតែមួយតែម្តង ឬក៏យ៉ាងណា?

**លោកស្រី អៀង វិជីដា៖**

រស់នៅជាមួយនៅក្នុងផ្ទះ តែខ្ញុំទៅមកទៅមកចាស។

[១២:២១:០៥]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹង ទាក់ទងនឹងទំនាក់ទំនងរវាងលោកស្រីជាមួយនឹងជនជាប់ចោទ តើក្នុង១សប្តាហ៍ហ្នឹងលោកស្រីទាក់ទងប៉ុន្មានពេល?

**លោកស្រី អៀង វិជីដា៖**

ជាទូទៅ១សប្តាហ៍ ខ្ញុំនៅជាប់ជាមួយគាត់ ២, ៣ថ្ងៃដែរចាស។

**ប្រធានអង្គជំនុំ៖**

ថាតើលោកស្រីមានសកម្មភាពអ្វីខ្លះនៅពេលបច្ចុប្បន្នហ្នឹងក្នុងការជួយដល់ជនជាប់ចោទ?

**លោកស្រី អៀង វិជីដា៖**

ជួយទំនុកបម្រុងគាត់នៅតាំងពីការហូបចុក ការព្យាបាល ហើយនិងពិនិត្យតាមដានជំងឺឲ្យគាត់ និងជួយឲ្យគាត់ធ្វើសកម្មភាពចលនាក្នុងការហាត់ប្រាណអីបានខ្លះចាស។

**ប្រធានអង្គជំនុំ៖**

ទាក់ទងនឹងបញ្ហាលោកស្រីវិញ តើលោកស្រីធ្លាប់បានធ្វើដំណើរទៅកន្លែងផ្សេងពីអាសយដ្ឋានរបស់លោកស្រីទៅជនបទ ឬក៏ទៅកន្លែងផ្សេង ឬក៏ត្រូវក្រៅប្រទេសយ៉ាងណាដែរ?

**លោកស្រី អៀង វិជីដា៖**

ខ្ញុំបានមានការធ្វើដំណើរចេញចូលទៅតាមខេត្ត ដែលខ្ញុំកន្លែងខ្ញុំធ្វើការចាស។ ទៅបរទេសអត់ដែលទៅទេចាស។

[១២:២២:១១]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ សូមអញ្ជើញលោកចៅក្រម បើមានសំណួរសូមអញ្ជើញសួរ!

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

អរគុណលោកប្រធាន។

លោកស្រី វិជីដា យើងមិនចង់ឲ្យលោកស្រីមានទំនាស់ផលប្រយោជន៍ក្នុងការជួយដល់ម្តាយរបស់លោកស្រី ហើយក្នុងពេលមួយគ្នាហ្នឹង ក្នុងនាមជាអាណាព្យាបាលដែលត្រូវប្រឈមមុខជាមួយនឹងការបង្គាប់បញ្ជារបស់តុលាការដែលដាក់ទៅលើម្តាយរបស់លោកស្រី។ ប៉ុន្តែយ៉ាងណាក៏ដោយ វាហាក់ដូចជាមាននូវគោលជំហរស្របគ្នារវាងសាលាដំបូង រវាងព្រះរាជអាជ្ញា ហើយក៏មានចែងនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះផងដែរ ដែលថាតុលាការអាចតម្រូវឲ្យមានវត្តមានរបស់ម្តាយរបស់លោកស្រីនៅពេលអនាគត ហើយនិងអាចមានការទាមទារឲ្យម្តាយរបស់លោកស្រីមកបង្ហាញវត្តមាននៅក្នុងតុលាការប្រសិនបើចាំបាច់។

[១២:២៣:២៧]

ដូច្នេះ ហើយយើងចង់ដឹងថាតើលោកស្រីអាចជួយដល់ម្តាយរបស់លោកស្រីដើម្បីត្រៀមខ្លួននៅ

ពេលដែលទទួលបានដីកាកោះហៅពីតុលាការ។ តើលោកស្រីបានត្រៀមខ្លួនរួចរាល់ហើយឬនៅ?

**លោកស្រី អៀង វិជីដា៖**

ចាស ខ្ញុំបានត្រៀមខ្លួនហើយ។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណ។ តើលោកស្រីគិតថា អាចមានស្ថានភាព ឬក៏មានស្ថានការណ៍ណាមួយដែលជនជាប់ចោទគាត់ត្រូវការចាំបាច់ទៅបរទេសដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

ដូចជាមិនមានហេតុផលដែលត្រូវទេ ព្រោះគាត់ចាស់ហើយ ហើយឥឡូវដើរដំណើរជិតៗហ្នឹងអត់ចង់បានផងចាស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តាមដែលលោកស្រីដឹង តើត្រឹមត្រូវដែរឬទេ ដែលថាម្តាយរបស់លោកស្រីបាននិយាយថា គាត់មានមិត្តភក្តិនៅបរទេស ដែលជួយការពារ ឬក៏ជួយទំនុកបម្រុងគាត់ ឬមួយគ្រាន់តែជាការដែលគាត់និយាយតែខ្លួនឯងនោះទេ?

[១២:២៤:៣៩]

**លោកស្រី អៀង វិជីដា៖**

គ្រាន់តែគាត់និយាយដោយខ្លួនឯងទេ អត់មានផងចាស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ដូច្នេះលោកស្រីបញ្ជាក់ថា មិនមានមិត្តភក្តិ ឬក៏សាច់ញាតិនៅបរទេសណាដែលនៅក្រៅប្រទេសហើយដែលអាចជួយគាត់ ជួយដល់ជនជាប់ចោទបានដែរឬទេ? តើលោកស្រីយល់ឃើញអ៊ីចឹងតើមែនដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

ចាស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

តើលោកស្រីអាចដឹងពីមូលហេតុដែលថាជនជាប់ចោទ គឺម្តាយរបស់លោកស្រីហ្នឹងអាចមានតម្រូវការក្នុងការផ្លាស់ប្តូរអាសយដ្ឋានទាំងជាការផ្លាស់ប្តូរអចិន្ត្រៃយ៍ ឬមួយក៏ជាការផ្លាស់ប្តូរបច្ចុប្បន្ន

តើលោកស្រីអាចដឹងថាមានបញ្ហានេះដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

អាចមានតម្រូវការពេលខ្លះដែលគាត់ធុញថប់ខ្លាំងនៅកន្លែងតែមួយកន្លែង អាចមានតម្រូវការផ្លាស់ប្តូរនៅក្នុងស្រុកហ្នឹងខ្លះអ៊ីចឹង។

[១២:២៦:១៣]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ដូច្នេះប្រសិនបើមានការផ្លាស់ប្តូរអាសយដ្ឋានហ្នឹង តើវាមានបញ្ហាអ្វីដែលចំពោះលោកស្រីក្នុងការជម្រាបមកតុលាការដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

ខ្ញុំគិតថាវាអាចមានផលវិបាកខ្លះក្នុងការធ្វើបែបបទ។ ដូច្នេះហើយខ្ញុំសម្រេចចិត្តថា ប្រហែលជាអត់មានការផ្លាស់ប្តូរអីទីណាទេ ព្រោះអីពិបាកអារឿងធ្វើបែបបទចុះឡើង។ ម្យ៉ាងពួកខាងខ្ញុំជាអ្នករវល់ការងារច្រើន ចាស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំមិនប្រាកដថាតើយើងយល់គ្នាច្បាស់លាស់ឬក៏អត់នោះទេ ខ្ញុំចង់សួរថាតើលោកស្រីមានបញ្ហាដែរឬទេក្នុងការជម្រាបមកតុលាការអំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ម្តាយលោកស្រី?

**លោកស្រី អៀង វិជីដា៖**

ចាស បើមានការផ្លាស់ប្តូរពិតប្រាកដ ខ្ញុំអត់មានបញ្ហាអីខ្ញុំត្រូវតែជម្រាបមកខាងតុលាការចាស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

នេះគឺជាអ្វីដែលខ្ញុំចង់សួរលោកស្រី។ ខ្ញុំមានសំណួរមួយទៀត គឺពាក់ព័ន្ធទៅនឹងតម្រូវការចាំបាច់របស់អត្តសញ្ញាណប័ណ្ណរបស់ម្តាយរបស់លោកស្រី។ យើងដឹងថាក្នុងពេលបច្ចុប្បន្នហ្នឹង គឺអត្តសញ្ញាណប័ណ្ណគឺត្រូវរក្សាទុកដោយតុលាការ។ តើម្តាយរបស់លោកស្រីអាចរស់នៅប្រចាំថ្ងៃដោយមិនចាំបាច់មានអត្តសញ្ញាណប័ណ្ណ តើមានស្ថានភាពយ៉ាងម៉េចដែរក្នុងករណីនេះ?

**លោកស្រី អៀង វិជីដា៖**

ចំពោះបច្ចុប្បន្នសព្វថ្ងៃ ដូចអត់មានស្ថានភាពអីទេ ពីព្រោះអីគាត់អត់មានត្រូវការអត្តសញ្ញាណប័ណ្ណអីដែរទេ។

[១២:២៨:១៦]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ខ្ញុំគិតថាប្រហែលជាគ្មានបញ្ហាបច្ចេកទេសទេ ប៉ុន្តែវាគ្រាន់តែជាការសន្មត ឬក៏ជាសម្មតិកម្ម គឺថាយើងក្នុងនាមជាចៅក្រមបរទេស យើងព្យាយាមយល់អំពីស្ថានភាពក្នុងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ តើលោកស្រីអាចគិតថាមានស្ថានភាពណាមួយដែលថា មានករណីណាមួយចាំបាច់ដែលទាមទារឲ្យម្ដាយរបស់លោកស្រីត្រូវការនូវអត្តសញ្ញាណប័ណ្ណដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

តាមស្ថានភាពក្នុងទេសកម្ពុជាសព្វថ្ងៃ ដោយអាយុគាត់ដូចជា អាយុ៨០ ហើយ ហើយដូចជាមិនមានរឿងអីពាក់ព័ន្ធដែលនេះច្រើនទេ អាចមានម្តងម្កាល តែខ្ញុំមិនគិតថាដូចជាមិនមានជាសារៈសំខាន់អីប៉ុន្មានដែរទេចាស។

[១២:២៩:១៣]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ចុះនៅពេលដែលគាត់ទៅពិនិត្យសុខភាព តើមិនចាំបាច់ឲ្យមានការបង្ហាញអត្តសញ្ញាណប័ណ្ណដែរឬទេ នៅពេលដែលគាត់ទៅពិនិត្យសុខភាព ឬក៏ទៅទទួលសេវាសុខាភិបាលនានានោះ?

**លោកស្រី អៀង វិជីដា៖**

ដោយហេតុឥឡូវហ្នឹងគឺគាត់ហាក់ដូចជាមិនទាន់ផុត ចេញផុតពីសាលាក្តីនេះនៅឡើយទេ អ៊ីចឹងការទទួលសេវាសុខាភិបាលផ្សេងៗ គឺខ្ញុំបានខំទំនាក់ទំនងទៅជាមួយគ្រូពេទ្យដែលធ្លាប់បានព្យាបាលគាត់នៅសាលាក្តីហ្នឹង ដែលបានស្គាល់ប្រវត្តិគាត់រួចមកហើយ។ អ៊ីចឹងក្នុងបច្ចុប្បន្ននេះ គាត់អត់មានត្រូវការទាមទាររកអត្តសញ្ញាណប័ណ្ណទេចាស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

ប៉ុន្តែក្នុងករណីដែលមានការផ្លាស់ប្តូរវេជ្ជបណ្ឌិត ឬក៏យើងនិយាយជាទូទៅ នៅពេលដែលជនជាតិកម្ពុជា នៅពេលដែលប្រជាជនកម្ពុជា ជាទូទៅគាត់ទៅពេទ្យហ្នឹង តើគាត់ចាំបាច់ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណដែរឬទេ តាមដែរលោកស្រីដឹងនោះ?

**លោកស្រី អៀង វិជីដា៖**

ចាស ជាទូទៅនៅក្នុងប្រទេសកម្ពុជាយើង ពេលដែលទៅប្រើប្រាស់សេវាសុខាភិបាល មិនទាន់

មានចាំបាច់ត្រូវការបង្ហាញអត្តសញ្ញាណប័ណ្ណទេចាស។

**ចៅក្រម អាកនីស្កា ក្លូណ្សវីកកា មីឡាត៖**

ចុះក្នុងករណីដែលមិត្តភក្តិគាត់នៅបរទេសផ្ញើនូវកញ្ចប់អីវ៉ាន់ ឬមួយក៏ជាអំណោយផ្សេងៗមកជូនគាត់ តើគាត់ចាំបាច់ត្រូវមានអត្តសញ្ញាណប័ណ្ណដើម្បីទៅបើក ឬក៏ដើម្បីទៅទទួលយកនូវបញ្ញើប្រៃសណីយ៍នោះដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

ការពិតណាស់ គឺត្រូវការអត្តសញ្ញាណប័ណ្ណ ប៉ុន្តែចំពោះពេលបច្ចុប្បន្ននេះគឺហាក់ដូចជាគ្មានមិត្តភក្តិនៅបរទេសណាដែលផ្ញើអីវ៉ាន់មកឲ្យគាត់ដែរទេ។

[១២:៣១:២៨]

**ចៅក្រម អាកនីស្កា ក្លូណ្សវីកកា មីឡាត៖**

នៅពេលដែលយើងនិយាយអំពីការដែលចាត់ចែងស្ថានភាពទូទៅរបស់ម្តាយរបស់លោកស្រី ក៏ដូចជាការចាត់ចែងទៅលើទ្រព្យសម្បត្តិ ឬក៏គេកេរដំណែល ជាកេរមរតកនានា តើលោកស្រីមិនត្រូវការអត្តសញ្ញាណប័ណ្ណរបស់គាត់ទេ? តើមែនដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

បញ្ហានេះ គឺជាកេរដំណែលដែលរបស់ម្តាយគឺវាមានតិចតួចណាស់ ដូចជាមិនមានអីដែលជំពាក់វ៉ាក់វិនអីច្រើនទេ ហើយបើសិនជាពេលដែលចាំបាច់ខ្លះ យើងអាចត្រូវការដែរចាស។

**ចៅក្រម អាកនីស្កា ក្លូណ្សវីកកា មីឡាត៖**

ដូច្នេះ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា ដែលមិនចាំបាច់ក្នុងការរក្សាទុកនូវលិខិតឆ្លងដែនរបស់ជនជាប់ចោទ។ តើលោកស្រីមិនចាំបាច់ត្រូវការលិខិតឆ្លងដែនរបស់គាត់ទេ? តើមែនដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

ចាស នេះជាការតម្រូវការរបស់ខាងតុលាការដែលបានចេញមក គឺមិនឲ្យត្រូវមានអត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែននៅតាមជាប់ខ្លួនរបស់គាត់។ ដូច្នេះ ខ្ញុំយល់ឃើញថា ការណ៍នេះគឺសម្រេចតាមតុលាការចុះ ចាស។

[១២:៣៣:០០]

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

នេះគឺជាដីកាបណ្ដោះអាសន្នដែលចេញដោយប្រធានអង្គជំនុំជម្រះ ហើយយើងកំពុងតែពិចារណាទៅលើមូលដ្ឋានក៏ដូចជាភាពចាំបាច់ដែលទាក់ទងទៅនឹងសំណើរបស់ព្រះរាជអាជ្ញា ទាក់ទងទៅនឹងការដាក់លក្ខខណ្ឌទាំងអស់នេះ។ ដូច្នេះសំណួររបស់ខ្ញុំ គឺថាតើលិខិតឆ្លងដែនហ្នឹងចាំបាច់ដែរឬទេ ដែលត្រូវការរក្សាទុក ប៉ុន្តែលោកស្រីបានឆ្លើយថា លោកស្រីគិតថា ប្រហែលមិនមានតម្រូវការក្នុងការធ្វើដំណើរទៅបរទេសទេ តើមែនដែរឬទេ? ហើយក៏ប្រហែលជាមិនមានការត្រូវការចាំបាច់ក្នុងការប្រើប្រាស់លិខិតឆ្លងដែននោះដែរ តើអ៊ីចឹងមែនទេ?

**លោកស្រី អៀង វិជីដា៖**

ចាស។

**ចៅក្រម អាកនីស្កា ក្លូណូវីកកា មីឡាត៖**

សូមអរគុណលោកស្រី ខ្ញុំសូមបញ្ចប់សំណួររបស់ខ្ញុំ។

**ចៅក្រម សោម សិរីវឌ្ឍ៖**

លោកស្រី អៀង វិជីដា តុលាការកំពុងពិចារណាក្នុងការតម្រូវឲ្យម្ដាយលោកស្រីទទួលបានការវាយតម្លៃផ្នែកវេជ្ជសាស្ត្រដោយទៀងទាត់ ដើម្បីវាយតម្លៃលើការវិវត្តនៃលក្ខណៈ លក្ខខណ្ឌខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ។ លោកស្រី អៀង ធីរិទ្ធ បានមានប្រសាសន៍អម្បាញ់មិញកន្លងមកនេះថា លោកស្រីនៅតែបន្តប្រើប្រាស់ថ្នាំព្យាបាល។ ខ្ញុំសំណួរលោកស្រីថា តើគាត់នឹងទទួលយកការព្យាបាលផ្នែកវេជ្ជសាស្ត្រណាមួយផ្សេងទៀតដែរឬទេ?

**លោកស្រី អៀង វិជីដា៖**

ចាស កន្លងមក គឺគាត់កំពុងស្ថិតនៅការព្យាបាលតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតដែលបានព្យាបាលគាត់តាមប្រចាំ ដែលបានជូនទៅមើលរៀងរាល់ខែ ចាស។

[១២:៣៤:៥១]

**ចៅក្រម សោម សិរីវឌ្ឍ៖**

បាទ អរគុណ។ សំណួរមួយទៀត តើលោកស្រីដឹងថានឹងមានបញ្ហាអ្វីកើតឡើងនៅពេលដែលតុលាការតម្រូវឲ្យ អៀង ធីរិទ្ធ ទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ដើម្បីបញ្ជាក់ឲ្យច្បាស់អំពីសម្បទាបញ្ញាស្មារតី?

**លោកស្រី អៀង វិជីដា៖**

ចាស ខ្ញុំអាច មិនអាចប៉ាន់ទស្សន៍ទាយមុនទេ ប៉ុន្តែនៅក្នុងស្មារតីរបស់គាត់រៀងរាល់ថ្ងៃនេះ គឺវាហៅថាមិនអាចប្រក្រតីបានធម្មតាទេ។ ពេលខ្លះគាត់អាចទទួលយកបាន ថ្ងៃខ្លះដែលយើងហៅគាត់ទៅពេទ្យទៅអីអ៊ីចឹង ថ្ងៃណាដែលគាត់ចង់គឺទៅៗ ថ្ងៃណាដែលគាត់មិននេះទេ គឺពិបាកនឹងការធ្វើឱ្យគាត់នេះណាស់ គឺតាមចិត្តរបស់គាត់។ អ៊ីចឹងការដែលវាយតម្លៃមួយៗរបស់គ្រូពេទ្យមួយ ខ្ញុំអាចថាបានឬមិនបាន គឺអាស្រ័យទៅលើគាត់ដែរ ពីព្រោះអីខ្ញុំអត់អាចកំណត់បានទេចាស។

**ចៅក្រម សោម សិរិវឌ្ឍ៖**

បាទ សំណួរមួយទៀត ថាតើលោកស្រីយល់ដឹងថា ក្នុងនាមជាអាណាព្យាបាល លោកស្រីមានកាតព្វកិច្ចជួយដល់ម្តាយលោកស្រីក្នុងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ប្រសិនបើមានការបង្គាប់ពីតុលាការ?

[១២:៣៦:០០]

**លោកស្រី អៀង វិជីដា៖**

ខ្ញុំអាចវាយតម្លៃបានទៅតាមស្ថានភាពជាក់ស្តែង ប៉ុន្តែដោយសារខ្ញុំមិនមានឯកទេសខាងចិត្តវិទ្យានេះទេ អ៊ីចឹងអាចការវាយតម្លៃនេះគឺមិនបានត្រឹមត្រូវ១០០ភាគរយ ដោយសារខ្ញុំជាវេជ្ជបណ្ឌិតក៏ពិតមែនប៉ុន្តែខាងឯកទេសទូទៅមិនមានឯកទេសខាងចិត្តវិទ្យាទេចាស។

**ចៅក្រម សោម សិរិវឌ្ឍ៖**

សូមអរគុណ។ ខ្ញុំអស់សំណួរហើយ។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

បាទ សូមអនុញ្ញាតសាកសួរទៅលោកស្រី វិជីដា ពីរបីសំណួរទេ។ ដូចលោកស្រីបានជម្រាបហើយថា នៅក្នុងការលើកឡើងរបស់សហព្រះរាជអាជ្ញាអម្បាញ់មិញអំពីបណ្តឹងសាទុក្ខរបស់ខ្លួនគឺថាទាក់ទងនឹងបញ្ហាហាមឃាត់ជនជាប់ចោទដែលត្រូវជាម្តាយរបស់លោកស្រីហ្នឹងមិនឱ្យមានការទាក់ទងជាមួយនឹងខាងសាក្សី ក៏ដូចជាជនជាប់ចោទដទៃទៀតនៅក្នុងសំណុំរឿង០០២នេះ ឬក៏ជនរងគ្រោះអីជាដើម។ អ៊ីចឹងក្នុងនាមលោកស្រីដែលកន្លងមកធ្លាប់ជាកូន ហើយចុងក្រោយនេះគឺជាអាណាព្យាបាលលើជនជាប់ចោទ ថាតើលោកស្រីបានដឹងច្បាស់ទេថាតើជនជាប់ចោទដែលត្រូវជាម្តាយរបស់លោកស្រីហ្នឹងមានទំនាក់ទំនងជិតស្និទ្ធប៉ុនណាជាមួយនឹងសហជនជាប់ចោទដទៃទៀត?

[១២:៣៧:១៣]

**លោកស្រី អៀង វិជីដា៖**

ចាស តាំងពីគាត់នេះមក ដូចជាគ្មានទំនាក់ទំនងអ្វីទេជាមួយជនជាប់ចោទដទៃទៀត ពីព្រោះអីឥឡូវហ្នឹងគឺគាត់ហាក់ដូចជាវង្វេងវង្វាន់ អត់ស្គាល់អ្នកណាច្បាស់លាស់ផងចាស។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

ប៉ុន្តែកន្លងមកហ្នឹង តើគាត់មានដែលបានប្រាប់លោកស្រីទេថា គាត់មានការនឹកនាជនជាប់ចោទណាមួយ ហើយចង់ទំនាក់ទំនងមកដោយផ្ទាល់អីជាដើម?

**លោកស្រី អៀង វិជីដា៖**

ចាស ក្រៅពីឪពុកខ្ញុំដែលគាត់អះអាងថាឪពុកខ្ញុំហ្នឹងជាម្តាយបង្កើតរបស់គាត់ហ្នឹង គឺអ្នកផ្សេងទៀត គាត់អត់ដែលមានទេចាស។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

ចុះចំពោះបញ្ហាសាក្សីវិញ តើ--

[១២:៣៧:៤៧]

**អ្នកបកប្រែ៖**

លោកអ៊ំប្រធាន សូមអនុញ្ញាតឲ្យលោកចៅក្រម ម៉ុង មុន្នីចរិយា ផ្អាកល្បឿនបន្តិចទាន។ ពេលដែលឆ្លើយឆ្លងសូមផ្អាកបន្តិច។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

ចុះទាក់ទងនឹងបញ្ហាសាក្សីនៅក្នុងសំណុំរឿង០០២វិញ សួរថាតើលោកស្រីដែលជាជនជាប់ចោទហ្នឹងមានបានដែលប្រាប់លោកស្រី វិជីដា ទេថាគាត់មានការខឹងសម្បានឹងរូបសាក្សីណាមួយឬក៏ជនរងគ្រោះណាមួយនៅក្នុងសំណុំរឿង០០២នេះ?

**លោកស្រី អៀង វិជីដា៖**

ចាស អត់ដែលមានទេចាស។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

អ៊ីចឹងក្នុងនាមជាអាណាព្យាបាលដូចជាចៅក្រមមុនៗបានជម្រាបជូនលោកស្រីហើយថា ជាអាណាព្យាបាល យើងនឹងមានកាតព្វកិច្ចមួយនៅក្នុងការជួយម្តាយហ្នឹង ក្នុងធ្វើយ៉ាងណាដើម្បីកុំឲ្យគាត់ហ្នឹងមានទំនាក់ទំនងជាមួយនឹងសាក្សី ក៏ដូចជាសហជនជាប់ចោទដទៃទៀត លើកលែងតែមានប្តីរបស់

គាត់។ តើអ្នកស្រីយល់ច្បាស់ទេបញ្ហានេះ បើសិនបើតុលាការសម្រេចលើបញ្ហានេះ?

[១២:៣៨:៥៣]

**លោកស្រី អៀង ធីរិទ្ធ៖**

ចាស ខ្ញុំយល់ច្បាស់។

**ចៅក្រម ម៉ុង មុន្នីចរិយា៖**

បាទ សូមអរគុណឯកឧត្តមប្រធាន។

**ចៅក្រម អាកនីស្កា ក្លូណ្ឌូវីកកា មីឡាត៖**

នៅមានសំណួរមួយទៀតដែលខ្ញុំត្រូវបានឲ្យសាកសួរ។ លោកស្រីបានដឹងហើយថាសហព្រះរាជអាជ្ញា គាត់ទាមទារឲ្យមានការត្រួតពិនិត្យផ្នែកសុវត្ថិភាពមួយអាទិត្យម្តង ឬក៏ជារៀងរាល់ខែទៅដល់ម្តាយរបស់លោកស្រី។ ថាតើគោរព តើគាត់គោរពបានលក្ខខណ្ឌដែរឬទេ? ហើយតម្រូវឲ្យរាយការណ៍អំពីអាសយដ្ឋានរបស់ចុងចម្លើយ របស់ម្តាយរបស់លោកស្រីផងដែរ តើមានបញ្ហាអ្វីដែរឬទេក្នុងការគោរពតាមតម្រូវការបែបនេះនោះ?

**លោកស្រី អៀង ធីរិទ្ធ៖**

ប្រហែលជាមិនអាចធ្វើបានទេ ពីព្រោះអីនាងខ្ញុំសូមជម្រាបថា ដូចខ្ញុំបានប្រាប់ហើយ គឺគាត់មិនដឹងប្រកតីនេះទេ គឺថាដូចឧទាហរណ៍ព្រឹកមិញអ៊ីចឹង ទម្រាំតែបានចេញពីផ្ទះមកមានការយឺតយ៉ាវ។ ពេលខ្លះគាត់ចង់ចេញ ចេញ ពេលខ្លះគាត់មិនចង់ចេញ គឺគាត់មិនព្រមចេញពីបន្ទប់ទេ។ អ៊ីចឹងក្នុងការរាយការណ៍១អាទិត្យម្តង ហើយនិងការនាំខ្លួនគាត់ទៅជួបនឹងគឺជាការលំបាកណាស់ចំពោះពួកខ្ញុំ។ ហើយម្យ៉ាងទៀត ដោយសារខ្ញុំមានការងាររវល់ជាច្រើន អ៊ីចឹងខ្ញុំមិនអាចបាននៅជាប់ជាមួយគាត់រៀងរហូតទេ គឺមានតែអ្នកដែលមិនមែនជាអាណាព្យាបាលហ្នឹង នៅជួយថែទាំជាមួយដែលជាកូនក្មួយឬជាចៅរបស់គាត់ហ្នឹង។ អ៊ីចឹងនាំចេញចូលរៀងរាល់អាទិត្យហ្នឹង គឺពិបាកណាស់។ ស្ថានភាពនេះគឺយើងមិនអាចធ្វើបានទេចាស។

[១២:៤១:១៦]

**ចៅក្រម អាកនីស្កា ក្លូណ្ឌូវីកកា មីឡាត៖**

សូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណអ្នកស្រីអាណាព្យាបាល។ សូមអញ្ជើញអង្គុយចុះ!

ជាបន្តសូមៗលោកសហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តី តើមានស្នើកត់សម្គាល់ទៅលើ សំណួរ និងចម្លើយដែលធ្វើឡើងដោយចៅក្រម និងចម្លើយរបស់ជនជាប់ចោទ និងអ្នកអាណាព្យាបាល ដែរឬយ៉ាងណា។ សូមអញ្ជើញ បើមាន!

សូមអញ្ជើញសហព្រះរាជអាជ្ញា!

[១២:៤២:០៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំរីករាយធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបផ្អែកពាក់ព័ន្ធទៅនឹង ព័ត៌មានបន្ថែម ដែលយើងបានស្តាប់ឮ ហើយប្រហែលជាចំណុចនេះគឺអាចឆ្លើយតបទៅនឹងបញ្ហាថ្មីៗ ផងដែរ។

**លោកស្រី ដាយអាណា អេលីស៖**

សូមលោកប្រធាន ខ្ញុំសូមអន្តរាគមន៍នៅក្នុងដំណាក់កាលនេះ។ យើងខ្ញុំឲ្យអង្គចៅក្រមពិចារណា ពិនិត្យឲ្យបានលម្អិតចំពោះចម្លើយដែលបានឆ្លើយ។ យើងខ្ញុំអាចស្នើថា វាជាគុណប្រយោជន៍ប្រសិនបើ យើងឲ្យ អៀង វិជីដា នៅទីនេះ មកទីនេះដើម្បីសួរគាត់អំពីចម្លើយនានាដែលបានឆ្លើយដោយចុង ចម្លើយ។ ថាតើចម្លើយដែលឆ្លើយចុងចម្លើយកន្លងមកនេះ ត្រឹមត្រូវឬក៏អាចយកជាការបានដែរឬទេ?

[១២:៤៣:១១]

ចម្លើយមួយពីលោកស្រី អៀង វិជីដា គឺបានបញ្ជាក់ថា ការឆ្លើយថាមានមិត្តភក្តិគ្រួសារនៅ បរទេសនោះគឺមិនត្រឹមត្រូវទេ តាមការឆ្លើយរបស់ចុងចម្លើយ។ ដូច្នេះតាមខ្លឹមសារចម្លើយទាំងឡាយ ដែលបានឆ្លើយនោះ គឺថាយើងមានចំណុចច្រើនណាស់ ដែលយើងមិនបានដឹងតាមការឆ្លើយ និងការចង ចាំរបស់ចុងចម្លើយ ដូចដែលលោកសាស្ត្រាចារ្យ ខាំប៉ែល បានបញ្ជាក់។ ដូច្នេះហើយគិតថា ពេលខ្លះទៅ គឺយើងគិតថាវាមិនសមស្របក្នុងការផ្អែកទៅលើចម្លើយមួយចំនួនដែលចុងចម្លើយបានឆ្លើយនោះទេ ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវរបស់ចុងចម្លើយនោះ។

ដូច្នេះហើយយើងខ្ញុំសូមឲ្យតុលាការនេះធ្វើការសួរបញ្ជាក់ទៅលោកស្រី អៀង វិជីដា ថាតើម្តាយ របស់គាត់នោះស្គាល់ដឹងអំពីទំនាក់ទំនងនានាដែរឬទេ? ហើយគាត់ដឹងថាគាត់មកតុលាការនេះដែរឬទេ?

ហើយគាត់ដឹងថាមានកិច្ចដំណើរការនីតិវិធីធ្វើឡើងចំពោះគាត់នោះដែរឬទេ?

ដូច្នេះហើយប្រសិនបើអង្គសវនាការវាយតម្លៃ និងផ្អែកទៅលើចម្លើយដែលជនជាប់ចោទចុងចម្លើយឆ្លើយអម្បាញ់មិញនេះ គួរតែពិចារណាអំពីមូលដ្ឋាន និងអ្វីដែលខ្ញុំបានលើកឡើងនៅក្នុងពេលនេះផងដែរ។ សូមអរគុណ។

[១២:៤៤:៥១]

**លោក អាប់ឌុលឡាក់ ថារីក៖**

អង្គសវនាការ យើងខ្ញុំសូមឆ្លើយតបទៅនឹងការលើកឡើងនេះ។ យើងមិនឯកភាពជាមួយនឹងការលើកឡើងនេះទេ។ អង្គសវនាការគឺមានលទ្ធភាពក្នុងការវាយតម្លៃទៅលើសមត្ថភាពរបស់ជនជាប់ចោទក្នុងការយល់អំពីសំណួររបស់អង្គសវនាការ។ ហើយអង្គសវនាការក៏មានលទ្ធភាពក្នុងការវាយតម្លៃទៅលើអ្វីដែល លទ្ធភាពនូវការឆ្លើយតបរបស់ចុងចម្លើយ។ ដូច្នេះហើយវាមិនសមស្របនោះទេ ប្រសិនបើយើងឲ្យកូនស្រីរបស់លោកស្រី អៀង ធីរិទ្ធ ធ្វើការផ្តល់សក្ខីកម្មលើភាពត្រឹមត្រូវនៃចម្លើយរបស់លោកស្រី អៀង ធីរិទ្ធ។ យើងបានឮចម្លើយរបស់គាត់ហើយ ហើយក៏ចម្លើយរបស់លោកស្រី វិជីដា ផងដែរ។

ដូច្នេះហើយ ហើយយើងដឹង ក៏ដឹងថាគាត់មិនមានសមត្ថភាពក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី ហើយគឺប្រហែលជាលោកស្រី អៀង ធីរិទ្ធ អាចធ្វើការទំនាក់ទំនងជាមួយនឹងបុគ្គលមួយចំនួនតាមការជួយជ្រោមជ្រែង។ ដូច្នេះហើយយើងមិនចាំបាច់ធ្វើការសួរបញ្ជាក់ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃសក្ខី-កម្ម ឬចម្លើយដែលបានឆ្លើយដោយជនជាប់ចោទនោះទេ។

[១២:៤៦:០៤]

**ប្រធានអង្គជំនុំ៖**

យើងខ្ញុំតុលាការកំពូលយល់ឃើញថាមិនចាំបាច់សួរទៅលើ អ្នកអាណាព្យាបាលរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ទេ។ ដោយហេតុថាបញ្ហានេះគឺតុលាការកំពូលគ្រាន់តែចង់ដឹងអំពីបញ្ហាមួយចំនួនទេ ហើយបញ្ហាដែលលោកស្រីជនជាប់ចោទដែលបានឆ្លើយអំពីបញ្ហាមិត្តភក្តិនោះ ហើយនិងមានការឆ្លើយបញ្ជាក់អះអាងអំពីទំនាក់ទំនងរវាងមិត្តភក្តិដោយអ្នកអាណាព្យាបាលទូទៅហ្នឹង គឺយើងនឹងយកមកធ្វើការពិចារណាបន្ថែមទៀត។ ហើយជាបន្តនេះគឺ បើជនជាប់ចោទលោកស្រី អៀង ធីរិទ្ធ មានបំណងនឹងធ្វើសម្តីចុងក្រោយ គឺសូមអញ្ជើញ សូមអញ្ជើញលោកអាចធ្វើសម្តី និយាយ សេចក្តីចុងក្រោយនេះជារយៈពេល ដែលមានអាចមានរយៈពេល១០នាទី។ បាទ សូមអញ្ជើញ! បើមានបំណងនឹងធ្វើសម្តីចុង

ក្រោយ។ សូម--

[១២:៤៧:៣៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:៤៨:២៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញជនជាប់ចោទ ហើយបើសិនជាលោកស្រីអាចមានប្រសាសន៍បាន សូមអញ្ជើញ!

**លោកស្រី អៀង ធីរិទ្ធ៖**

នរណាជនជាប់ចោទ?

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមបញ្ជាក់ម្តងទៀត លោកស្រី អៀង ធីរិទ្ធ តើលោកស្រីអាចធ្វើការថ្លែងជូនសវនាការនៅពេលបញ្ចប់នេះបានទេ ហើយបើបាន សូមអញ្ជើញធ្វើថ្លែងការណ៍។ បាទ សូមអញ្ជើញ!

**លោកស្រី អៀង ធីរិទ្ធ៖**

មិនបានទេ ខ្ញុំមានបានស្តាប់បញ្ហាហ្នឹងឯណា--

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រហែលជាយល់ថា លោកស្រីមិនអាចចាប់បាននូវចំណុចទាំងនេះ -- អស់ទាំងនេះទេ ហើយខ្ញុំយល់ថា លោកស្រីជាអ្នកអាណាព្យាបាល លោកស្រី អៀង វិជីដា សូមអញ្ជើញបើអាចធ្វើទៅបាន សូមអញ្ជើញថ្លែងជំនួសឲ្យម្តាយបានទេ? បាទ សូមអញ្ជើញ!

[១២:៤៩:៥៩]

**លោកស្រី អៀង វិជីដា៖**

ចាស នាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកប្រធាន ខ្ញុំក៏អត់មានអីវែងឆ្ងាយ គ្រាន់តែចង់ជម្រាបដល់អង្គជំនុំជម្រះថា សព្វថ្ងៃនេះគឺម្តាយខ្ញុំស្ថិតនៅក្នុងសភាពមួយដែលគាត់ហៅថា វង្វេងវង្វាន់ស្មារតីហើយមិនអាចចងចាំអ្វីបានទាំងអស់ សូម្បីតែជាកូនរបស់ខ្លួនគាត់ហ្នឹង ពេលខ្លះគាត់ហៅបងពេលខ្លះគាត់ហៅប៉ា ពេលខ្លះហៅម៉ាក់អីចឹងទៅ តាមតែគាត់នឹកឃើញ។ ហើយមួយទៀតគឺលទ្ធភាពដែលគាត់មកចូលរួមនៅកន្លែងនេះ ក៏គាត់បានខំប្រឹងប្រែងអូសទាញ អីអីចឹងគឺថាពេលណាគាត់ចង់ដើប

ពីសម្រាក ក៏ងើប ពេលណាអត់គឺថាវាពិបាកក្នុងការដែលនាំមកម្តងៗហ្នឹង គឺមានការពិបាក មិនមែនថាគេចវេះទេ តែដោយសារស្ថានភាពសុខភាពរបស់គាត់ គឺចុះខ្សោយទ្រុឌទ្រោមមែនទែន ហើយម្យ៉ាងអាយុវ័យរបស់គាត់ចាស់។

[១២:៥០:០៤]

ហើយក្នុងនាមជាកូនគឺទោះបីយ៉ាងណាក្តីក៏ខិតខំជួយជ្រោមជ្រែងនិងថែទាំ ហើយក៏សូមអរគុណដែរចំពោះអង្គជំនុំជម្រះ និងលោកប្រធានដែលបានអនុគ្រោះ ហើយបានយល់ដល់សុខភាពរបស់ម្តាយខ្ញុំដែលបានខំបាន គឺបានជួយសម្របសម្រួលក្នុងការដែលមកចូលរួមនេះគឺថា បានឱ្យសម្រាកពេលណាដែលគាត់មិនអាចអង្គុយបាន។ សូមថ្លែងអំណរគុណ ហើយដែលមានការយល់ចំពោះទុក្ខធុរះរបស់ម្តាយខ្ញុំ ហើយចំពោះខ្លួនខ្ញុំមិនមានស្អីដែលជាសេចក្តីសន្និដ្ឋានអីវែងឆ្ងាយទេ។ សូមអស់ប៉ុណ្ណឹងចាស។

**ប្រធានអង្គជំនុំ៖**

ជាចុងបញ្ចប់នេះ គឺអង្គជំនុំជម្រះតុលាការកំពូលប្រកាសថា តុលាការ -- អង្គជំនុំជម្រះតុលាការកំពូលនឹងចេញសេចក្តីសម្រេចរបស់ខ្លួន ដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរនៅពេលឆាប់ៗខាងមុខនេះ។ ហើយនៅពេលនេះគឺអង្គជំនុំជម្រះតុលាការកំពូល សូមប្រកាសបិទកិច្ចពិភាក្សាដេញដោលនាពេលនេះ។ បាទ សូមប្រកាសរំសាយ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១២:៥២ នាទី)*